ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ង៉ាន់ ណាត : សាក្សីប្រវត្តិសាស្ត្រ

◆ ហេតុអ្វីបានជាការអប់រំសំខាន់សម្រាប់ដំណើរការផ្លូវច្បាប់?

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤១ ខែកញ្ញា ឆ្នាំ២០១១

# ស្វែងរកការពិត

លេខ១៨១ ខែកញ្ញា ឆ្នាំ២០១១


# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆វ៉ាន់ ណាត ៖ សាក្សីប្រវត្តិសាស្ត្រ ..................................................១

**ផ្នែកឯកសារ**

◆អនាគតភ្លឺស្វាងនៃសេដ្ឋកិច្ចកម្ពុជាថ្មី ..................................................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ ................................៩

◆សារសំខាន់នៃវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រ ....................៣៦

◆សំណាងមួយ ..........................................................................៣៧

◆អ្នកទោសគុកខ្មែរក្រហម...........................................................៤០

◆ញ៉ឹក ឈុនឆាត ៖ ក្មេង១៧មេសា .............................................៤៣

**ផ្នែកច្បាប់**

◆ហេតុអ្វីបានជាការអប់រំសំខាន់សម្រាប់ដំណើរការផ្លូវច្បាប់? ...........៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ការវិភាគលើការទទួលខុសត្រូវខាងព្រហ្មទណ្ឌ................................៤៩

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆រឿងរ៉ាវពិតរបស់ខ្ញុំ ..............................................................៥៧




រូបគំនូរគូរដោយលោក វ៉ាន់ ណាត




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** សារ៉ុន គីម, ថេសា បៀឡេក, សារីតា គូប៊ីក, ទាវ សារៈមុនិន្ទ, អេនឌ្រូ ខេលី, អាណា ម៉ុមហូត, ឡៃ្ប ហួត **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ ៖** ទែន សុខស្រីនិត **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

# វ៉ាន់ ណាត : សាក្សីប្រវត្តិសាស្ត្រ

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១១ នេះ លោក វ៉ាន់ ណាត បាន លាចាកលោកចោលយើងទាំងអស់គ្នាជារៀងរហូតហើយ ។ ក្នុងនាមជាអ្នករស់រានមានជីវិតម្នាក់ក្នុងចំណោមអ្នកទោសប្រមាណត្រឹមតែដប់បួនរូបប៉ុណ្ណោះដែលរួចផុតពីការកាប់សម្លាប់នៅគុកទួលស្លែង លោក វ៉ាន់ ណាត គឺជាសាក្សីប្រវត្តិសាស្ត្រដ៏សំខាន់ម្នាក់ ។ លោក វ៉ាន់ ណាត បានបង្ហាញនូវកម្លាំងកាយនិងចិត្តយ៉ាងមាំមួនដើម្បីផ្តល់សក្ខីកម្មប្រវត្តិសាស្ត្រ ទោះបីជាលោកបានទទួលរងនូវអំពើឧក្រិដ្ឋដ៏ខ្លោចផ្សា និងទោះបីជាឋិតក្នុងស្ថានភាពមួយដែលអ្នកដែលធ្លាប់ធ្វើបាបលោកកំពុងតែរីករាយរស់នៅក្នុងនិទ្ទណ្ឌភាពអស់រយៈពេលជាងសាមសិបឆ្នាំយ៉ាងណាក៏ដោយ ។ នៅពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះរាប់លាននាក់ក្រោមរបបខ្មែរក្រហម លោក វ៉ាន់ ណាត បានសម្រេចចិត្តមិនដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទេ ។ លោក វ៉ាន់ ណាត បានជ្រើសយកជម្រើសបែបនេះ ដោយលោកយល់ថា ភារកិច្ចដ៏ចម្បងរបស់លោក គឺត្រូវផ្តល់សក្ខីកម្មសម្រាប់ក្មេងៗកម្ពុជាជំនាន់ក្រោយដើម្បីរៀនសូត្រពីប្រវត្តិសាស្ត្រ ។ ជម្រើសរបស់លោក វ៉ាន់ ណាត ឆ្លុះបញ្ចាំងឲ្យឃើញទស្សនៈយុត្តិធម៌ដែលសំដៅទៅលើអនាគតមនុស្សជាតិ ជាជាងក្តីបំណងដែលមានលក្ខណៈបុគ្គល និងមិនសូវឋិតថេរយូរអង្វែងដើម្បីទាមទារឲ្យមានការដាក់ទោសទណ្ឌ ការសងសឹក ឬសំណងផ្សេងៗ ។


វ៉ាន់ ណាត

ការបាត់បង់លោក វ៉ាន់ ណាត មុនពេលអ្នកឯទៀតដែលទទួលខុសត្រូវក្នុងការបង្កើតគុកទួលស្លែងឬមន្ទីរស-២១ ត្រូវបានវិនិច្ឆ័យទោស គឺជាសោកនាដកម្មមួយដែលបង្ហាញឲ្យឃើញនូវតម្លៃមិនអាចកាត់ថ្លៃបានចំពោះពេលវេលាដែលអាច និងបង្កឲ្យមានផលប៉ះពាល់ដល់ដំណើរស្វែងរកយុត្តិធម៌ ។ ដោយក្តីក្រៀមក្រំ សោកនាដកម្មនៃមរណភាពរបស់លោក វ៉ាន់ ណាត នៅតែបន្តកើតមានយ៉ាងស្ងៀមស្ងាត់ម្តងទៀតទូទាំងផ្ទៃប្រទេសកម្ពុជា ដោយសារតែពីមួយថ្ងៃទៅមួយថ្ងៃ ជនរងគ្រោះនៃរបបខ្មែរក្រហមបេះតែបាត់បង់ទៅៗ ដោយគ្មានបានផ្តល់ជូននូវយុត្តិធម៌ណាមួយដល់ជនរងគ្រោះទាំងនោះទាល់តែសោះ ។ អ្វីដែលជាសោកនាដកម្មធំជាងនោះទៅទៀតនោះគឺថា មរណភាពមួយចំនួនអាចនឹងធ្វើការទប់ស្កាត់បានប្រសិនបើប្រជាជនកម្ពុជាជាទូទៅអាចស្វែងរកសេវាថែទាំសុខភាពទំនើបបាន ។ នេះធ្វើឲ្យឃើញថា សេវាថែទាំសុខភាពលំដាប់ពិភពលោកដែលបានផ្តល់ឲ្យមេដឹកនាំខ្មែរក្រហមនៅឯតុលាការខ្មែរក្រហមមើលទៅហាក់បីដូចជាមិនស្មើភាពចំពោះជនរងគ្រោះសោះឡើយ ។ វាមានការលំបាកក្នុងការពន្យល់ឲ្យបានល្អអំពីគោលដៅដ៏ជាក់លាក់ណាមួយដូចជាការលើកកម្ពស់“នីតិរដ្ឋ”ចំពោះជនរងគ្រោះដែលមិនមានលទ្ធភាពសូម្បីតែឲ្យគ្រូពេទ្យពិនិត្យសុខភាពធម្មតាផង ។

ទោះជាយ៉ាងនេះក្តី តាមរយៈការផ្តល់សេវាថែទាំសុខភាពដល់មេដឹកនាំខ្មែរក្រហមដោយធ្វើតាមបទដ្ឋានតុលាការយុត្តិធម៌ និងគោលការណ៍សិទ្ធិមនុស្ស តុលាការខ្មែរក្រហមអាចផ្តល់នូវអ្វីមួយ





ផ្សេងទៀតដើម្បីជាសមានចិត្តដល់លោក វ៉ាន់ ណាត និងអ្នកដទៃទៀតដែលធ្លាប់បានទទួលរងការឈឺចាប់នៅគុកទួលស្លែងនិងគុកខ្មែរក្រហមដទៃទៀតទូទាំងប្រទេសដូចជា ភាពព្រៃផ្សៃ អំពើទារុណកម្ម និងការអាប់ឱនយសស័ក្តិនិងភាពថ្លៃថ្នូរជាមនុស្ស ។ ទោះបីជាការការពារសិទ្ធិរបស់មេដឹកនាំខ្មែរក្រហមជួនកាលអាចជាគ្រាប់ថ្នាំល្វីងដូចគ្រាប់ស្លែងដែលលំបាកក្នុងការលេបយ៉ាងណាក៏ដោយ សូម្បីតែមានការលំបាកទទួលយកនូវការមិនពេញចិត្តពីសំណាក់ជនរងគ្រោះក៏ការធ្វើបែបនេះបានផ្តល់មេរៀនមួយសម្រាប់អនាគតដែលធ្វើឲ្យលោក វ៉ាន់ ណាត មានមោទកភាពដែលត្រង់ថា រាល់ប្រជាជនទាំងអស់សុទ្ធតែមានសិទ្ធិក្នុងការទទួលបាននូវសេចក្តីថ្លៃថ្នូរនិងភាពស្មើគ្នាចំពោះមុខច្បាប់ ។

លោក វ៉ាន់ ណាត គឺជាមិត្តរបស់យើងទាំងអស់គ្នា ហើយការចាកចេញដ៏សែនឆ្ងាយរបស់លោកធ្វើឲ្យយើងទាំងអស់គ្នានៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានក្តីនឹករព្ញកយ៉ាងពន់ពេក ហើយអ្នកផ្សេងទៀតនៅក្នុងពិភពលោកក៏នឹងមានការនឹករព្ញកដល់រូបលោកដែរ ។ យើងទាំងអស់គ្នានឹងនឹករព្ញកដល់លោកជានិច្ច ហើយចេញពីទង្វើ និងទឹកចិត្តដែលលោកបានធ្វើជំរុញយើងឲ្យនឹកគិតដល់សន្តិភាពផ្លូវចិត្តដែលបានសម្តែងចេញពីទឹកចិត្តរបស់លោក ។ **ឆាំង យុ**














TSL 4758

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

លេខរៀង :
ទីផ្នែក :
មកពី :

១- ឈ្មោះដើម ហេង. ណាត. ឈ្មោះបដិវត្ត
២- អាយុ ៣៤ ឆ្នាំ ភេទ ប្រុស ជនជាតិ ខ្មែរ.
៣- ក្រសួងដឹកនាំ ចាប់ពីថ្ងៃចូលបដិវត្តដល់បច្ចុប្បន្ន
- មុនរកស៊ីគូររូប.
- ប្រជាជន សហករណ៍ ៥ ភូមិ ៤.
៤- ទីលំនៅរបស់ខ្លួនពីកំណើត ភូមិ វត្តសុភី ឃុំ ក្រយ៉ៅ
ស្រុក សង្កែ ខេត្ត ឬ តំបន់ បាត់ដំបង.
៥- របររកស៊ីរបស់ខ្លួនពីសង្គមចាស់
៦- ឪពុកឈ្មោះ ... ម្ដាយឈ្មោះ ...
៧- របររកស៊ីឪពុកម្ដាយពីមុនបដិវត្ត
៨- ប្ដី ឬ ប្រពន្ធ ឈ្មោះដើម ... ឈ្មោះបដិវត្ត
៩- ទីលំនៅកំណើត កើតនៅភូមិ វត្តសុភី ឃុំ ក្រយ៉ៅ
ស្រុក សង្កែ ខេត្ត ឬ តំបន់ បាត់ដំបង.
១០- ក្រសួង-ការងារ ដឹកនាំខ្លួនរបស់នៅបច្ចុប្បន្ន . សហករណ៍ ៥ ...
១១- មានកូនប្រុស ចំនួន ... នាក់ កូនស្រី ...
១២- ទីកន្លែងចាប់ខ្លួន ...
១៣- ចាប់ខ្លួននៅថ្ងៃទី 7 ខែ 1 ឆ្នាំ១៩៧៨
គិតការ : កំពស់ : 1ម75
ប្រវែងទំហំខ្លួន : 0ម93.

# អនាគតភ្លឺស្វាងនៃសេដ្ឋកិច្ចកម្ពុជាថ្មី

## ដកស្រង់ចេញពីឯកសារខ្មែរក្រហម D២១៣៨២

សង្គមជាតិនីមួយៗឬប្រទេសជាតិនីមួយៗមានការរីកចម្រើនលូតលាស់ក៏អាស្រ័យទៅលើសេដ្ឋកិច្ចនៃសង្គមជាតិឬប្រទេសជាតិនោះដែរ ។ បើសេដ្ឋកិច្ចមានការរីកចម្រើនលូតលាស់ សង្គមជាតិនោះឬប្រទេសជាតិនោះក៏មានការរីកចម្រើនលូតលាស់ ។ តែបើសេដ្ឋកិច្ចធ្លាក់ដុនដាបឬជួបនូវវិបត្តិធ្ងន់ធ្ងរជាបន្តបន្ទាប់ សង្គមជាតិនោះឬប្រទេសជាតិក៏រយីករយាកធ្លាក់ថយក្រោយវិញជាលំដាប់ ឬយ៉ាងហោចណាស់ក៏គ្មានការរីកចម្រើនលូតលាស់ទៅមុខដែរ ។ សេដ្ឋកិច្ចនៃប្រទេសជាតិនីមួយៗមានការរីកចម្រើនលូតលាស់ទៅមុខ ឬមិនចម្រើនលូតលាស់ ក៏វាអាស្រ័យទៅលើរបៀបផលិតកម្ម ។ បើរបៀបផលិតកម្មល្អចម្រើន សេដ្ឋកិច្ចក៏លូតលាស់ ។ តែបើរបៀបផលិតកម្មឱនថយ សេដ្ឋកិច្ចក៏រីកចម្រើនទៅមុខមិនរួចដែរ ។ ដើម្បីឲ្យដឹងថារបៀបផលិតកម្មចម្រើនឬឱនថយ យើងត្រូវពិនិត្យមើលការទាក់ទងផលិតកម្មនៅក្នុងសង្គមជាតិនៃប្រទេសនីមួយៗនោះ ។ ឯនៅប្រទេសកម្ពុជាយើងក៏ដូច្នោះដែរ ។

### *សេដ្ឋកិច្ចកម្ពុជាក្នុងសម័យសង្គមចាស់*

នៅក្នុងសង្គមចាស់ ប្រទេសជាតិនិងប្រជាជនកម្ពុជាត្រូវធ្លាក់ខ្លួនទៅជាអាណានិគមរបស់ចក្រពត្តិបរទេសជាបន្តបន្ទាប់មានចក្រពត្តិបារាំង ចក្រពត្តិជប៉ុន និងចក្រពត្តិអាមេរិក ។ ពួកចក្រពត្តិបរទេសទាំងនោះក្នុងគ្រប់យុគសម័យដែលវាចូលមករុករានទន្ទ្រានឈ្លានពានទឹកដីកម្ពុជាយើង ពួកវាបានឆក់ប្លន់ភោគផលរបស់ប្រជាជនកម្ពុជា ឆក់ប្លន់ទ្រព្យសម្បត្តិធនធានរបស់ប្រទេសជាតិយើងអស់រលីង ។ ព្រមជាមួយនេះ ពួកចក្រពត្តិបរទេសបានបំផ្លិចបំផ្លាញសេដ្ឋកិច្ចប្រទេសជាតិយើងតាមគ្រប់រូបភាព តាមគ្រប់មធ្យោបាយ ធ្វើឲ្យសេដ្ឋកិច្ចជាតិយើងត្រូវវិនាសហិនហោចខ្ទេចខ្ទីជាបន្តបន្ទាប់ ។

បន្ថែមពីលើនេះទៀត ពួកសក្តិភូមិនាយទុនប្រតិកិរិយានៅក្នុងស្រុកដែលជាបរិវារដាច់ថ្លៃរបស់ចក្រពត្តិបរទេសគ្រប់ជំនាន់ក៏បានឃុបឃិតគ្នាឆក់ប្លន់ទ្រព្យសម្បត្តិជាតិ ជិះជាន់ សង្កត់សង្កិនប្រជាជនកម្ពុជាយ៉ាងឃោរឃៅព្រៃផ្សៃបំផុត ។ ពួកវាមិនគ្រាន់តែមិនគិតគូរកសាងសេដ្ឋកិច្ចជាតិ មិនគ្រាន់តែគ្មានសមត្ថភាពកសាងសេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ តែពួកវានៅបានបំផ្លិចបំផ្លាញនិងជាន់ពន្លិចសេដ្ឋកិច្ចជាតិទៀតដោយអំពើក្បត់ជាតិ លក់ប្រទេសឲ្យចក្រពត្តិបរទេស និងអំពើឆក់ប្លន់ ពុករលួយ ពាលាអាវ៉ាសែសពុំបែបយ៉ាងរបស់ពួកវាទៀត ។

ដូច្នេះហើយបានជាសេដ្ឋកិច្ចកម្ពុជាយើងក្នុងរយៈពេលជាងមួយសតវត្សរ៍កន្លងទៅនេះត្រូវធ្លាក់ដុនដានវិនាសហិនហោច ខ្ទេចខ្ទីកាន់តែធ្ងន់ឡើងៗជាលំដាប់ ។ រហូតមកដល់សម័យសាធារណរដ្ឋក្បត់របស់អា លន់ នល់ ដែលជាអាណានិគមបែបថ្មីរបស់ចក្រពត្តិអាមេរិក សេដ្ឋកិច្ចកម្ពុជាត្រូវរលំរលាយទាំងស្រុង ។ នៅក្នុងសម័យសង្គ្រាមឈ្លានពានជាងប្រាំឆ្នាំចុងក្រោយនេះ ពួកអាក្បត់ លន់ នល់ រស់ផ្អឹកៗបានដោយសារតែជំនួយរបស់ចក្រពត្តិអាមេរិកប៉ុណ្ណោះ ។ រីឯកម្លាំងក្នុងខ្លួនវាដែលជាសេដ្ឋកិច្ចនៅក្នុងស្រុកគឺសូន្យគ្មានអ្វីទាំងអស់ ។

បើយើងពិនិត្យមើលការទាក់ទងផលិតកម្មនៅក្នុងសង្គមកម្ពុជាចាស់នេះ ឃើញថាជាការទាក់ទងផលិតកម្មជិះជាន់១០០ភាគរយ ។ មធ្យោបាយផលិតកម្មសំខាន់ៗទាំងប៉ុន្មានមានតាំងពីធនាគារ លុយកាក់ ដីធ្លី រោងចក្រ រហូតដល់ទន្លេ ស្ទឹង បឹងបួ និងព្រៃព្រឹក្សាទៀតឋិតនៅក្នុងកណ្តាប់ដៃចក្រពត្តិបរទេសក្នុងកណ្តាប់ដៃសក្តិភូមិនាយទុនប្រតិកិរិយាដែលជាបរិវារចក្រពត្តិបរទេសទាំងអស់ ។ រីឯប្រជាជាតិ និងប្រជាជនកម្ពុជាវិញគឺនៅនៅសល់តែបាតដៃទទេ ហើយគ្រាន់តែជាកម្លាំងពលកម្មយ៉ាងថោកមួយសម្រាប់ស៊ីឈ្នួលធ្វើការងារគ្រប់បែបយ៉ាងបម្រើផលប្រយោជន៍ពួកចក្រពត្តិបរទេស និងពួកសក្តិភូមិនាយទុនប្រតិកិរិយាឲ្យវាជិះជាន់ ហុតឈាម អង្កៀមឆ្អឹងប្រជាជាតិប្រជាជនកម្ពុជាយើងតាមទំនើងចិត្តវា ។ អាស្រ័យហេតុនេះហើយបានជាសេដ្ឋកិច្ចជាតិយើងកាលក្នុងសម័យសង្គមចាស់ក្នុងរយៈពេលជាងមួយសតវត្សរ៍

កន្លងទៅនេះ មិនត្រឹមតែមិនបានចម្រើនលូតលាស់ទៅមុខទាន់អារ្យប្រទេសនានាប៉ុណ្ណោះទេ តែថែមទាំងត្រូវរលំរលាយវិនាសហិនហោចជាបន្តបន្ទាប់ រហូតដល់ត្រូវរលំរលាយទាំងស្រុងនៅក្នុងសម័យអាសាធារណរដ្ឋក្បត់ដែលជាអាណានិគមថ្មីរបស់ចក្រពត្តិអាមេរិក ។

## សេដ្ឋកិច្ចនៅក្នុងនៅតំបន់រំដោះ

ចាប់ពីឆ្នាំ១៩៧០មកក្រោយដែលបានរំដោះទឹកដី៧០ភាគរយក្លាម អង្គការបដិវត្តន៍យើងបានចាប់អារម្មណ៍ជាខ្លាំងទៅលើកសាងគ្រឹះសេដ្ឋកិច្ចជាតិមួយដែលឯករាជ្យម្ចាស់អាចឧបត្ថម្ភខ្លួនបាន១០០ភាគរយក្នុងពេលសង្គ្រាមផង និងកែប្រែជីវភាពប្រជាជនបានជាបន្តបន្ទាប់ផង ។ ដើម្បីធ្វើឲ្យសេដ្ឋកិច្ចក្នុងតំបន់រំដោះមានការរីកចម្រើនទៅតាមទិស និងសំណូមពរដូចពោលខាងលើនេះ ចាប់ពីឆ្នាំ១៩៧៣ អង្គការបដិវត្តន៍យើងបានវាយរំលោះការទាក់ទងផលិតកម្មថ្មីដែលឯករាជ្យ ស្មើភាព និងសមូហភាពជាសន្សឹមៗ ។ ក្នុងការតស៊ូធ្វើបដិវត្តន៍សេដ្ឋកិច្ចក្នុងរយៈកាលជំហានដំបូងនេះ អង្គការបដិវត្តន៍យើងបានរឹបអូសយកដីធ្លី និងមធ្យោបាយផលិតកម្មផ្សេងៗដែលជារបស់ចក្រពត្តិបរទេស និងរបស់ពួកអាក្បត់ជាតិបរិវារចក្រពត្តិអាមេរិកមកចែកចាយជូនប្រជាជនក្រីក្រយើងដែលគ្មានមធ្យោបាយបង្កបង្កើនផល ។ ព្រមជាមួយនេះ អង្គការបដិវត្តន៍យើងក៏បានកំណត់បញ្ចុះតម្លៃឈ្នួលដីឈ្នួលគោក្របី និងកំណត់ការបែងចែកភាគផលក្នុងការប្រវាស់ដីនិងកម្លាំងមនុស្សឲ្យមានយុត្តិធម៌ និងសមស្របទៅតាមកម្លាំងពលកម្មរបស់ប្រជាជនក្រីក្រ ។ ដូច្នេះ ក្នុងរយៈកាលពីឆ្នាំ១៩៧០មកដល់ពាក់កណ្តាលឆ្នាំ១៩៧៣ ការទាក់ទងផលិតកម្មជិះជាន់នៅក្នុងតំបន់រំដោះត្រូវបានវាយរំលោះជាអតិបរមាហើយ តែការទាក់ទងផលិតកម្មនេះនៅមានរូបរាង នៅមានឥទ្ធិពល និងខ្លឹមសារនៅក្នុងតំបន់រំដោះយើងនៅឡើយ ។ ការនេះធ្វើឲ្យសេដ្ឋកិច្ចនៅក្នុងតំបន់រំដោះយើងមានការចម្រើនយឺត ពុំអាចសម្រេចសំណូមពរបម្រើសង្គ្រាមបដិវត្តន៍ដែលចេះតែរីវឌ្ឍលោតផ្លោះទៅមុខយ៉ាងឆាប់រហ័សបានឡើយ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៣ ដើម្បីធ្វើសេដ្ឋកិច្ចតំបន់រំដោះយើងអាចបម្រើសង្គ្រាមបដិវត្តន៍ដែលកាន់តែឆាបឆេះសន្ធោសន្ធៅខ្លាំងក្លាឡើងជារៀងរាល់ថ្ងៃបានផង និងដោះស្រាយជីវភាពប្រជាជននៅក្នុងតំបន់រំដោះ និងប្រជាជនដែលរត់ចេញពីតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្នដែលមានតែច្រើនឡើងៗឲ្យបានផង អង្គការបដិវត្តន៍យើងក៏បានសម្រេចលើកគោលការណ៍ធ្វើសហករណ៍ការរូបនីយកម្មនៅក្នុងតំបន់រំដោះប្រភេទទីមួយដែលមានសមាសភាពប្រជាជនជាកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម ហើយចាត់តាំងក្រុមប្រវាស់ដៃជាទូទៅនៅក្នុងតំបន់រំដោះប្រភេទទីពីរ ដើម្បីប្រមូលផ្តុំមធ្យោបាយផលិតកម្ម ប្រមូលផ្តុំកម្លាំងពលកម្មដែលមានទាំងប៉ុន្មាននៅក្នុងតំបន់រំដោះ វាយសម្រុកបង្កបង្កើនផលឲ្យបានច្រើនជាអតិបរមា និងឆាប់រហ័សទាន់ពេលវេលាទៀតផង ។ ចាប់តាំងពីពេលនោះមក បើយើងពិនិត្យមើលការទាក់ទងផលិតកម្មនៅក្នុងតំបន់រំដោះឃើញថា ការទាក់ទងផលិតកម្មចាស់ជិះជាន់ត្រូវវាយកម្ទាត់ជាមូលដ្ឋាន ហើយដូចជាការបុលបណ្តាក់ ការចងការ លក់បញ្ចាំ ឈ្នួលដីធ្លី គោក្របី ឬការជួលកម្លាំងពលកម្មប្រជាជនក្រីក្រត្រូវលុបបំបាត់ចោលទាំងអស់រលីង ។ ឯការទាក់ទងផលិតកម្មថ្មីដែលឯករាជ្យ ស្មើភាព សមូហភាព បានលេចចេញទាំងរូបរាង ទាំងខ្លឹមសារនៅទូទាំងតំបន់រំដោះយើង ។ មធ្យោបាយផលិតកម្មសំខាន់ៗមានដីធ្លី គោក្របី ទន្លេ ស៊ឹង បឹងបួ ជាដើម បានក្លាយទៅជាកម្មសិទ្ធិរួមរបស់សហករណ៍ប្រជាជន ។ រីឯប្រជាជនកម្ពុជា ពិសេសកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោមដែលធ្លាប់តែត្រូវគេជិះជាន់ សង្កត់សង្កិនមើលងាយមើលថោកជាងពីរពាន់ឆ្នាំមកហើយនោះ ក៏ត្រូវបានរំដោះទាំងស្រុង គឺរំដោះទាំងនយោបាយ រំដោះទាំងសេដ្ឋកិច្ច រំដោះទាំងស្មារតី ទាំងសម្ភារៈទៀតផង ។ កសិករក្រីក្រនៅក្នុងតំបន់រំដោះយើងបានឡើងទៅជាម្ចាស់ទឹកដី ម្ចាស់ស្រែចម្ការ ម្ចាស់គោក្របី និងម្ចាស់លើភោគផលរបស់ខ្លួនយ៉ាងពិតប្រាកដ ។ ប្រជាជននៅក្នុងតំបន់រំដោះយើងចេះរួបរួមសាមគ្គីគ្នាជួយគ្នាទៅវិញទៅមកដោយស្មោះស្ម័គ្រជួយឧបត្ថម្ភគ្នាទៅវិញទៅមក ទាំងសម្ភារៈ ដីធ្លី គោក្របី ពូជធាជួយឧបត្ថម្ភគ្នាទាំងខាងស្មារតីយ៉ាងសស្រាក់សស្រាំ នាំគ្នាលើកទំនប់ ជីកប្រឡាយ ជីកស្រះ ទាំងយប់ទាំងថ្ងៃ ដោះស្រាយបញ្ហាទឹកបង្កបង្កើនផល និងជំរុញចលនាបង្កបង្កើនផលបានខ្លាំងក្លាជាប់ជានិច្ច ។ ដូច្នេះ ប្រជាជននៅក្នុងតំបន់រំដោះទាំងមូល ទាំងអ្នកមាន

មធ្យោបាយច្រើន ទាំងអ្នកមានមធ្យោបាយតិច ទាំងអ្នកគ្មានមធ្យោបាយសុទ្ធតែអាចបង្កបង្កើនផលបានទាំងអស់គ្នា ។ អាស្រ័យហេតុនេះហើយបានជាកន្លងមក ទោះបីយើងឋិតនៅក្នុងសង្គ្រាមដែលចក្រពត្តិអាមេរិក និងបរិវាររវាខិតខំសាបព្រោះនូវមហាវិនាសកម្មបំផ្លិចបំផ្លាញប្រជាជនបដិវត្តន៍ និងតំបន់រំដោះយើងទាំងយប់ទាំងថ្ងៃ យ៉ាងណាក៏សេដ្ឋកិច្ចនៅក្នុងតំបន់រំដោះយើងនៅតែអាចចម្រើនលូតលាស់យ៉ាងឆាប់រហ័ស អាចសម្រេចសំណូមពរ ដោះស្រាយជីវភាពប្រជាជន និងបំរើសង្គ្រាមបដិវត្តន៍បានទាំងស្រុងដោយឯករាជ្យ ម្ចាស់ការ១០០ភាគរយ ។ ដូច្នេះសេដ្ឋកិច្ចតំបន់រំដោះយើងដែលមានលក្ខណៈឯករាជ្យ ម្ចាស់ការស្មើភាព និងសមូហភាព ពិសេសចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៣មកដល់ដើមឆ្នាំ១៩៧៥ បានរួមចំណែកយ៉ាងសកម្ម និងយ៉ាងស័ក្តិសិទ្ធបំផុតក្នុងការដណ្តើមយកជ័យជម្នះជាប្រវត្តិសាស្រ្តនាថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ ។ ពោលគឺអាស្រ័យអង្គការបដិវត្តន៍យើងបានកសាងនូវការទាក់ទងផលិតកម្មថ្មីដែលមានលក្ខណៈឯករាជ្យ ស្មើភាព សមូហភាពយ៉ាងនេះហើយ ទើបសេដ្ឋកិច្ចតំបន់រំដោះយើងទោះបីឋិតនៅក្នុងភ្លើងសង្គ្រាមយ៉ាងសន្ធោសន្ធៅក៏ដោយ ក៏មានការរីកចម្រើនលូលាស់ជាលំដាប់ ។ ហើយអាស្រ័យយើងមានសេដ្ឋកិច្ចចម្រើនលូតលាស់នេះហើយ ទើបសង្គ្រាមបដិវត្តន៍យើងអាចដណ្តើមបានជ័យជម្នះធំៗជាបន្តបន្ទាប់រហូតដល់ដណ្តើមបានមហាជ័យជម្នះជាប្រវត្តិសាស្រ្តទាំងស្រុង និងជាស្ថាពរនាថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នេះទៀត ។

## អានាគតភ្លឺស្វាងនៃសេដ្ឋកិច្ចកម្ពុជា

ឥឡូវ ប្រទេសកម្ពុជាប្រជាជាតិ និងប្រជាជនកម្ពុជាមានសុខសន្តិភាពហើយ ។ ទឹកដីកម្ពុជាទាំងមូល ព្រមទាំងមធ្យោបាយផលិតកម្មទាំងអស់របស់ប្រជាជាតិ និងប្រជាជនកម្ពុជាត្រូវបានរំដោះផុតពីកណ្តាប់ដៃចក្រពត្តិបរទេស និងពួកសក្តិភូមិនាយទុនប្រតិកិរិយាដែលជាបរិវារដាច់ថ្លៃរបស់ចក្រពត្តិបរទេសទាំងស្រុងហើយ ។ ដីធ្លី ស្រែចម្ការ ទន្លេស្ទឹង បឹងបួ និងព្រៃព្រឹក្សាផងនានាបានធ្លាក់មកក្នុងកណ្តាប់ដៃប្រជាជនសហករណ៍យើងទាំងស្រុង ។ រោងចក្រ កំពង់ផែ និងមធ្យោបាយដឹកជញ្ជូនជាយុទ្ធសាស្រ្ត



សកម្មភាពការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*សំខាន់ៗទាំងអស់ក៏ធ្លាក់មកក្នុងកណ្ដាប់ដៃរដ្ឋរបស់កម្មករ-កសិករដែរ ។ សរុបមក មធ្យោបាយផលិតកម្មសំខាន់ៗទាំងអស់ ទាំងខាងកសិកម្ម ទាំងខាងឧស្សាហកម្ម ទាំងខាងសិប្បកម្ម ទាំងខាងគមនាគមន៍ គឺឋិតនៅក្នុងកណ្ដាប់ដៃប្រជាជនសហករណ៍ និងរដ្ឋកម្មករ-កសិករទាំងស្រុង ។ ដូច្នេះ ក្រោយពេលរំដោះទូទាំងប្រទេស ការទាក់ទងផលិតកម្មចាស់ ជិះជាន់ត្រូវបានវាយកម្ទាត់ទាំងស្រុងហើយ ។ រីឯការទាក់ទងផលិតកម្មថ្មីដែលមានលក្ខណៈឯករាជ្យ ស្មើភាព សមូហភាពត្រូវបានពង្រឹងនិងពង្រីកឡើងកាន់តែខ្លាំងក្លាថែមទៀត ហើយមានតួនាទីគ្របដណ្ដប់នៅក្នុងសង្គមជាតិកម្ពុជាថ្មីបច្ចុប្បន្ននេះ ។ ការទាក់ទងផលិតកម្មថ្មីល្អ និងរីកចម្រើននេះហើយដែលជាគ្រឹះយ៉ាងរឹងមាំនៃសេដ្ឋកិច្ចជាតិយើង ហើយធានានូវអនាគតភ្លឺស្វាងដល់សេដ្ឋកិច្ចកម្ពុជាថ្មីក្នុងពេលបច្ចុប្បន្នក៏ដូចតទៅអនាគតទៀត ។ ក្រៅពីទុនជាមូលដ្ឋាន និងជាកត្តាកំណត់នូវទិសវិវឌ្ឍល្អរបស់សេដ្ឋកិច្ចកម្ពុជាថ្មីខាងលើនេះ យើងនៅមានទុនល្អធំៗជាច្រើនផ្សេងទៀត ។*

*១) យើងមានសន្តិភាព អាចមានពេលវេលាគ្រប់គ្រាន់បរិបូរដើម្បីស្ដារសេដ្ឋកិច្ចជាតិយើងដែលទើបចេញពីសង្គ្រាម ហើយកសាងសេដ្ឋកិច្ចជាតិយើងឲ្យរីកចម្រើនទៅមុខជានិច្ចយ៉ាងឆាប់រហ័ស ។*

*២) យើងមានមធ្យោបាយផលិតកម្មគ្រប់បែបយ៉ាង ទាំងខាងកសិកម្ម ទាំងខាងឧស្សាហកម្ម ទាំងខាងសិប្បកម្ម ។ ជាពិសេសគឺមធ្យោបាយផលិតកម្មខាងកសិកម្មជាដីធ្លីស្រែចម្ការ គោក្របី ទឹក ពូជធា ដីជាតិយ៉ាងច្រើនអាចវាយសម្រុកបង្កបង្កើនផលបានពេញទំហឹង និងបានច្រើនអតិបរិមាសម្រាប់បម្រើកិច្ចការពារប្រទេសផង និងការកសាងប្រទេសឲ្យបានឆាប់រហ័សផង ។*

*៣) យើងមានប្រជាជនអង់អាចក្លាហានធ្លាប់វាយឈ្នះចក្រពត្តិអាមេរិក ប្រជាជនឧស្សាហ៍ព្យាយាម និងមានទេពកោសល្យច្នៃប្រឌិត កសាងរស់រវើកជាប់ជានិច្ច ប្រជាជនដែលត្រូវបានរំដោះទាំងស្រុង ទាំងស្មារតី ទាំងសម្ភារៈ ។ ដូច្នេះ ជាប្រជាជនដែលមានការភ្ញាក់រឭកនយោបាយកម្រិតខ្ពស់ ។ ប្រជាជនបែបនេះជាកម្លាំងផលិតកម្ម និងកម្លាំងពលកម្មខ្លាំងក្លាមហិមាណាស់ដែលអាចពុះពារបានគ្រប់ឧបសគ្គ ទ្រាំទ្របាននូវការលំបាកវេទនាគ្រប់បែបយ៉ាង ហើយអាចប្រយុទ្ធសម្រេចភារកិច្ច កសាងសេដ្ឋកិច្ចជាតិដោយសន្ទុះលោតផ្លោះ ប្រកបដោយជោគជ័យទាំងស្រុងពុំខានឡើយ ។ ក្នុងពេលសង្គ្រាម ប្រជាជនកម្ពុជាយើងបានប្រយុទ្ធវាយកម្ទេចខ្មាំងដណ្ដើមបានមហាជ័យជម្នះដ៏ល្បីល្បាញខ្ទរខ្ទារពេញទាំងសកលលោក ។ ដូច្នេះ ក្នុងពេលសន្តិភាពបច្ចុប្បន្ន និងតទៅអនាគត ប្រជាជនកម្ពុជាដ៏មហិមានេះប្រាកដជានឹងប្រយុទ្ធការពារប្រទេសកសាងប្រទេស ពោលគឺកសាងសេដ្ឋកិច្ចកម្ពុជាថ្មីឲ្យបានរីកចម្រើនលូតលាស់ឆាប់រហ័សពុំខានឡើយ ។*

*៤) យើងមានរដ្ឋអំណាចបដិវត្តន៍ដែលជារដ្ឋអំណាចរបស់ប្រជាជន កម្មករ-កសិករ ហើយដែលរដ្ឋអំណាចការពារគិតគូរ និងបម្រើផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់ឧត្តមរបស់ប្រទេសជាតិទាំងមូល និងរបស់ប្រជាជនកម្ពុជា ពិសេសប្រជាជន កម្មករ-កសិករ និងពលករដែលជាស្រទាប់ប្រជាជនផលិតករនៅក្នុងសង្គមកម្ពុជាយើង ។ ដូច្នេះយើងអាចរៀបចំចាត់ចែង និងកសាងសេដ្ឋកិច្ចជាតិយើងសមស្របទៅតាមលក្ខណៈ និងផលប្រយោជន៍ដ៏ ពិសិដ្ឋរបស់ប្រទេសកម្ពុជា ប្រជាជាតិ និងប្រជាជនកម្ពុជាបានពេញទំហឹង ។*

*៥) ខាងចាត់តាំង យើងមានសហករណ៍ផលិតកម្មកម្រិតទាប កម្រិតខ្ពស់ និងសហគមន៍ដែលជាអង្គភាពផលិតសមូហភាពយ៉ាងរឹងប៉ឹង ខ្លាំងក្លានៅពាសពេញទូទាំងប្រទេសកម្ពុជាយើង ។*

*ទុនទាំងអស់នេះហើយដែលជាគ្រឹះសេដ្ឋកិច្ចជាតិយ៉ាងរឹងមាំ ហើយធានាអះអាងនូវការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជាថ្មីយើង ។*

*ពិតមែនហើយ ក្នុងឆ្នាំនេះ យើងមានការលំបាកមានការខ្វះខាតខ្លះ ។ តែការលំបាកនេះ គ្រាន់តែជាបណ្ដោះអាសន្នដែលយើងអាចដោះស្រាយបាន ហើយកំពុងតែដោះស្រាយបានជាបន្តបន្ទាប់ ។ ការលំបាកក្នុងឆ្នាំដំបូងនេះក៏ជាការធម្មតាព្រោះប្រទេសជាតិ និងប្រជាជនកម្ពុជាយើងទើបចេញពីសង្គ្រាមដ៏កំណាចឃោរឃៅដែលចក្រពត្តិអាមេរិក និងបរិវារវាបំផ្លិចបំផ្លាញ និងសាបព្រោះនូវមហាវិនាសកម្មកម្រិតខ្ពស់បំផុត ។ តែការប្រយុទ្ធទ្រាំទ្រការលំបាកវេទនា ប្រយុទ្ធបង្កបង្កើនផលឧបត្ថម្ភខ្លួនរបស់ប្រជាជនកម្ពុជាយើងក្នុងឆ្នាំនេះ បានបង្ហាញឲ្យសាកលលោកទាំង*

មូលឃើញច្បាស់នូវវីរភាពបដិវត្តន៍ខ្ពង់ខ្ពស់បំផុត ដែលជាប្រពៃណីរបស់ប្រជាជាតិ និងប្រជាជនកម្ពុជាយើងតាំងពីសម័យសង្គ្រាមបដិវត្តន៍រហូតមកដល់សម័យសន្តិភាពកសាងប្រទេសជាតិទៀត ។ វាជាកិត្តិយសយ៉ាងខ្ពង់ខ្ពស់បំផុតរបស់ប្រទេសជាតិ និងប្រជាជនកម្ពុជាយើងដែលទើបវាយឈ្នះចក្រពត្តិអាមេរិក ហើយឥឡូវប្រយុទ្ធបង្កបង្កើនផលឧបត្ថម្ភខ្លួនបានដោយឯករាជ្យ ម្ចាស់ការ មិនដេករង់ចាំពឹងផ្អែក ឬមិនសុំទានជំនួយបរទេសឡើយ ទោះបីជាឋិតនៅក្នុងសភាពទើបចេញពីមហាវិនាសកម្មនៃសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកយ៉ាងនេះក្តី ។ ឆ្នាំនេះយើងមិនទាន់សម្បូរ មិនទាន់គ្រប់គ្រាន់នៅឡើយទេ តែយើងអាចដោះស្រាយដោយឯករាជ្យ ម្ចាស់ការខ្លួនយើងបាន មិនឲ្យប្រជាជនដាច់ពោះស្លាប់ ហើយក៏មិនសុំទានជំនួយបរទេសដែរ ។ នេះជាមហាជ័យជម្នះថ្មីមួយទៀតរបស់យើងបន្ទាប់ពីមហាជ័យជម្នះជាប្រវត្តិសាស្ត្រនាថ្ងៃទី១៧ ខែមេសា ១៩៧៥ ព្រោះការដោះស្រាយបញ្ហាស្បៀងជាបញ្ហាមួយលំបាកបំផុតនៅក្នុងសកលលោកសព្វថ្ងៃ ។ សព្វថ្ងៃមានប្រទេសជាច្រើនដែលឋិតនៅក្នុងសន្តិភាពផងក៏នៅតែពុំទាន់ដោះស្រាយបញ្ហាស្បៀងជូនប្រជាជនគេបានដូចយើងសព្វថ្ងៃនេះផង ។

ឥឡូវ ប្រជាជនយើងនៅត្រូវឆ្លងកាត់ការលំបាកនឹងការខ្វះខាតជាបណ្តោះអាសន្ននេះតែប៉ុន្មានខែទៀតប៉ុណ្ណោះ ឲ្យតែដល់រដូវប្រូត នោះយើងនឹងមានស្បៀងគ្រប់គ្រាន់ហើយ ។ ព្រោះចលនាបង្កបង្កើនផលរបស់យើងក្នុងឆ្នាំនេះ ទោះបីទើបចេញពីភ្នក់ភ្លើងសង្គ្រាមក៏ដោយ មានសន្ទុះផុលផុសខ្លាំងក្លាជាងឆ្នាំមុនៗច្រើនណាស់ ។ នៅក្នុងតំបន់នានា ភាគច្រើនលើសលប់ស្រូវល្អជាងរាល់ឆ្នាំ ។ រីឯផ្ទៃស្រែ និងផ្ទៃដីដាំដុះក៏ត្រូវបានពង្រីកថ្មីច្រើនថែមទៀត ។ ដូច្នេះឆ្នាំនេះ យើងអាចឧបត្ថម្ភខ្លួនបានគ្រប់គ្រាន់ព្រោះរដ្ឋអំណាចបដិវត្តន៍យើងជារដ្ឋអំណាចរបស់ប្រជាជនកម្មករ-កសិករគ្មានរកស៊ីកេងប្រវ័ញ្ច រកស៊ីចំណេញកប់ក្តោងយកទៅធ្វើមានបានឯណាទេ មិនរឹបជាន់ ឆក់ប្លន់ប្រជាជនយកទៅបម្រើផលប្រយោជន៍បុគ្គលណាឬវណ្ណៈណាទេ ។ ដូច្នេះ ធ្វើបាន រកបានប៉ុន្មានគឺគិតគូរ លៃលក ចែកចាយជូនប្រជាជនវិញ ឲ្យមានការស៊ីចុក ស្លៀកពាក់គ្រប់គ្រាន់ និងដើម្បីការពារប្រទេស កសាងប្រទេសឲ្យបានសម្បូរសប្បាយ ខ្លាំងក្លា និងថ្កុំថ្កើងរុងរឿងប៉ុណ្ណោះ ។

តទៅឆ្នាំក្រោយៗទៀត ដោយប្រជាជនកម្ពុជាយើងទាំងអស់គ្នា ទាំងប្រជាជននៅក្នុងមូលដ្ឋានចាស់ ទាំងប្រជាជនដែលទើបចេញពីក្រុងចុះប្រឡូកធ្វើពលកម្មបានពេញទំហឹងទាំងអស់គ្នា គ្មានអ្នកណាដេកចាំតែស៊ី ដោយជិះជាន់កម្លាំងពលកម្មអ្នកដទៃ គ្មានអ្នកណារកស៊ីកេងប្រវ័ញ្ច ជិះជាន់លើអ្នកណាទៀត និងដោយប្រជាជនកម្ពុជាទាំងអស់ចូលរួមប្រាស្រ័យកសាងប្រទេសជាតិទាំងអស់គ្នា ដោយឯករាជ្យ ស្មើភាព សស្រាក់សស្រាំ ទាំងយប់ថ្ងៃយ៉ាងនេះ នោះផលិតផលជាតិយើងនឹងចេះតែកើនចម្រើនឡើងជាលំដាប់ ។ ពីមួយឆ្នាំទៅមួយឆ្នាំ យើងនឹងកាន់តែមានទុនច្រើនទ្វេថែមទៀតសម្រាប់យកមកពង្រីង និងពង្រីកសេដ្ឋកិច្ចជាតិយើងឲ្យកាន់តែរីកចម្រើនលូតលាស់ថែមឡើងជាបន្តបន្ទាប់ ។ ដូច្នេះប្រទេសកម្ពុជាយើងដែលជាប្រទេសកសិកម្មទន់ខ្សោយនឹងបានប្រែក្លាយទៅជាប្រទេសកសិកម្មសម័យដែលយើងអាចម្ចាស់ការលើបញ្ហាទឹកពី៧០-៨០ភាគរយ ប្រើប្រាស់ម៉ាស៊ីនជំនួសកម្លាំងមនុស្សពី៧០-៨០ភាគរយ ហើយនិងប្រើប្រាស់ជីនិងថ្នាំកសិកម្មជាទូទៅយ៉ាងឆាប់រហ័ស ។ ហើយតទៅអនាគតទៀត ប្រទេសជាតិយើងក៏នឹងមានការរីកចម្រើន ហើយវិវឌ្ឍឈានឡើងពីប្រទេសកសិកម្មសម័យទៅជាប្រទេសកសិកម្មសម័យឧស្សាហកម្ម រួចទៅជាប្រទេសឧស្សាហកម្មកសិកម្មសម័យជាលំដាប់បន្តបន្ទាប់ទៅទៀត ។

នេះហើយជាអនាគតភ្លឺស្វាងនៃសេដ្ឋកិច្ចថ្មីយើង ។

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**




# វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ ស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## *សេចក្តីផ្តើម*

មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាដើម្បីបើកវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យថ្នាក់សាកលវិទ្យាល័យជាលើកដំបូងសម្រាប់សាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យ ចាប់ពីថ្ងៃទី២៥ ដល់២៧ ខែកក្កដា ឆ្នាំ២០១១ ។ វគ្គបណ្តុះបណ្តាលនេះបានអញ្ជើញសាស្ត្រាចារ្យចំនួនពីររូបមកពីសាកលវិទ្យាល័យនីមួយៗក្នុងចំណោមសាកលវិទ្យាល័យទាំងអស់ចំនួន៥៧ដែលស្ថិតនៅក្រោមក្រសួងអប់រំ យុវជន និងកីឡា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានអញ្ជើញសាស្ត្រាចារ្យម្នាក់មកពីស្ថាប័នចំនួន៣៧ផ្សេងទៀតដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីធានាឲ្យបានថា វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យនេះត្រូវបានអនុវត្តទូទាំងប្រទេសនិងមានលក្ខណៈទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបាន ។ សាស្ត្រាចារ្យដែលបានចូលរួមមានចំនួន៩៦រូបដែលតំណាងឲ្យគ្រឹះស្ថានឧត្តមសិក្សានៅរាជធានីភ្នំពេញ ស្វាយរៀង បាត់ដំបង ពោធិ៍សាត់ សៀមរាប កំពង់ចាម ព្រះសីហនុ និង បន្ទាយមានជ័យ ។

វគ្គបណ្តុះបណ្តាលនេះត្រូវបានប្រារព្ធធ្វើឡើងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។ គោលបំណងនៃវគ្គនេះគឺដើម្បីចែករំលែកព័ត៌មានទាក់ទងនឹងការស្រាវជ្រាវលើព្រឹត្តិការណ៍មុននិងក្នុងអំឡុងរបបខ្មែរក្រហម និងផ្តល់សេចក្តីណែនាំពីវិធីសាស្ត្រនិងទ្រឹស្តីនៃការបង្រៀនថ្មីៗ ព្រមទាំងវិធីសាស្ត្របញ្ជ្រាបប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចូលទៅក្នុងកម្មវិធីបង្រៀនដែលមានស្រាប់ ។

ក្នុងអំឡុងវគ្គបណ្តុះបណ្តាល សាស្ត្រាចារ្យមួយចំនួនរួម

មានសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ សាស្ត្រាចារ្យ រស់ ចន្ទ្រាបុត្រ និងសាស្ត្រាចារ្យ អ៊ីវ ច័ន បានបកស្រាយយ៉ាងក្បោះក្បាយពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលនាំទៅរកអំពើប្រល័យពូជសាសន៍និងអ្វីដែលបានកើតឡើងក្រោមការគ្រប់គ្រងរបស់របបខ្មែរក្រហម ។ លោក ឌី ខាំបូលី បានចំណាយពេលច្រើនដើម្បីពន្យល់អំពីខ្លឹមសារសៀវភៅប្រវត្តិសាស្ត្ររបស់គាត់គឺប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខណៈពេលដែល បណ្ឌិត ជា ផល្លា និងលោក គ្រីស្តូហ្វ័រ ឌៀរីង បានណែនាំវិធីសាស្ត្របង្រៀនមួយចំនួនដែលនឹងក្លាយជាឧបករណ៍បង្រៀនដ៏មានប្រសិទ្ធភាពសម្រាប់ការបង្រៀនរបស់សាស្ត្រាចារ្យនីមួយៗ ។ អ្នកចូលរួមទាំងអស់ក៏មានឱកាសសួរសំណួរនិងសម្តែងការព្រួយបារម្ភដែរនៅក្នុងអំឡុងវគ្គសំណួរចម្លើយដែលមានការសម្របសម្រួលពីសំណាក់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជាច្រើននាក់ ។

## សេចក្តីរំពឹងទុក

មជ្ឈមណ្ឌលឯកសារកម្ពុជាមានសេចក្តីរំពឹងទុកជាក់លាក់មួយចំនួនដែលត្រូវសម្រេចឲ្យបានពីវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យថ្នាក់សាកលវិទ្យាល័យនេះ ។ សេចក្តីរំពឹងទុកទាំងនោះត្រូវបានលោក លី សុខឃាង រៀបរាប់ដូចតទៅ ៖

១) បង្កើនចំណេះដឹងរបស់សាស្ត្រាចារ្យស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

២) ផ្តល់ជូនសាស្ត្រាចារ្យសាកលវិទ្យាល័យនូវវិធីសាស្ត្រថ្មីៗ ថែមទៀតដើម្បីផ្ទេរចំណេះដឹងស្តីពីរបបខ្មែរក្រហមទៅដល់និស្សិត ។

៣) លើកទឹកចិត្តសាស្ត្រាចារ្យទាំងអស់ឲ្យធ្វើការស្រាវជ្រាវពីប្រទេសក្រោយជម្លោះផ្សេងៗ មានដូចជាប្រទេសអាល្លឺម៉ង់ រ៉្វាន់ដា អាហ្វ្រិកខាងត្បូង និងអ៊ីរ៉ាក់ (ប៉ុន្តែការស្រាវជ្រាវមិនកំណត់ត្រឹមប្រទេសទាំងនេះទេ) ។

៤) ណែនាំពីការសិក្សាបែបប្រៀបធៀបនិងចម្រុះជាតិសាសន៍ដើម្បីបង្ហាញពីសេចក្តីត្រូវការក្នុងការបញ្ជ្រាបការសិក្សាពីប្រទេសកម្ពុជាចូលទៅក្នុងបរិបទទូលំទូលាយជាងមុន ។

៥) ផ្តល់ជូនឯកសារយោងថ្មីៗ ដែលអាចមានប្រយោជន៍ដល់និស្សិតដូចមាននៅក្នុងឯកសារតម្រូវឲ្យអាន និងឯកសារណែនាំឲ្យអាននៅក្នុងវគ្គបណ្តុះបណ្តាលនេះ ។

ជាការពិតណាស់ បទសម្ភាសន៍ជាមួយអ្នកចូលរួមមួយចំនួនបានឆ្លុះបញ្ចាំងពីសេចក្តីរំពឹងទុកស្រដៀងគ្នាជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។ ក្នុងនាមជាអ្នករដ្ឋបាលក្នុងផ្នែកអប់រំអក្សរសាស្ត្រខ្មែរទូទៅរបស់វិទ្យាស្ថានអន្តរជាតិប៊ែលធី លោក



លោកជំទាវ ទន់ សាអ៊ីម ថ្លែងសុន្ទរកថានៅក្នុងសិក្ខាសាលា

សាង ហៃ មានប្រសាសន៍ថា លោកត្រូវតែ «ធ្វើយ៉ាងណាឲ្យសាស្ត្រាចារ្យទាំងអស់ដឹងច្បាស់ពីវិធីសាស្ត្រគាត់តែងមេរៀនសម្រាប់និស្សិត» ។ លោកសង្ឃឹមថានឹងបញ្ចូលចំណេះដឹងថ្មីៗទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចូលទៅក្នុងកម្មវិធីបង្រៀនដែលមានស្រាប់នៅវិទ្យាស្ថានរបស់លោក ។ លោក ឆាយ ធារិទ្ធ សាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រខ្មែរនៃវិទ្យាស្ថានអប់រំកម្ពុជាបាននិយាយថា ចាប់តាំងពីលោកកើតក្នុងរបប ប៉ុល ពត មក ការរៀនសូត្រពីសម័យកាលនេះនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ។ លោកចង់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះដោយសារលោកមានឱកាសផ្លាស់ប្តូរយោបល់ជាមួយសាស្ត្រាចារ្យដទៃទៀត និងដើម្បីទទួលបានបទពិសោធន៍ «ពិតប្រាកដ» ។ ជាលទ្ធផល លោកអាចនឹងបង្រៀនប្រវត្តិសាស្ត្រនេះទៅកាន់និស្សិតបានយ៉ាងមានប្រសិទ្ធភាពដើម្បីឲ្យនិស្សិតជំនាន់ក្រោយចងចាំប្រវត្តិសាស្ត្រនេះ ហើយទប់ស្កាត់មិនឲ្យកើតឡើងម្តងទៀត ។ លោកសាស្ត្រាចារ្យបាននិយាយថា «និស្សិតនឹងមានការភ័យខ្លាចចំពោះការកាប់សម្លាប់ ហើយនិស្សិតនឹងចាប់ផ្តើមគិតគូរពីការកសាងសន្តិភាពនៅក្នុងប្រទេសកម្ពុជាចាប់ពីពេលនេះតទៅ ។ លោកស្រី នួន សែនថាវី សាស្ត្រាចារ្យប្រវត្តិសាស្ត្រមកពីសាកលវិទ្យាល័យជាតិគ្រប់គ្រងបានបន្ថែមថា តាមរយៈកម្មវិធីនេះ លោកស្រី «ទទួលបានឯកសារកាន់តែច្រើនដែលសរសេរដោយបញ្ញវន្តល្បីៗ ដែលធ្វើឲ្យការបង្រៀនរបស់លោកស្រីកាន់តែច្បាស់លាស់ ហើយផ្ទេរចំណេះដឹងទាំងនេះទៅឲ្យនិស្សិតទាំងអស់» ។

នៅថ្ងៃបើកអង្គពិធីនៃវគ្គបណ្តុះបណ្តាលនេះ និស្សិតសាកលវិទ្យាល័យក៏បានចូលរួមដែរ ។ និស្សិតចំនួនប្រាំនាក់ដែលត្រូវបានជួបសម្ភាសន៍សុទ្ធតែមកពីវិទ្យាស្ថានវ៉ាន់ដា ហើយត្រូវបានតម្រូវឲ្យរៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំសិក្សាថ្នាក់មូលដ្ឋាន ។ សម្រាប់និស្សិត ម៉េក ឃឿន តាមរយៈកម្មវិធីបណ្តុះបណ្តាលសាស្ត្រាចារ្យនេះ និស្សិតចង់ឲ្យការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានត្រួតពិនិត្យសាជាថ្មីដើម្បីឲ្យនិស្សិតបានរៀនអំពីគោលនយោបាយរបស់របបនេះនិងភាពជាប់ពាក់ព័ន្ធខាងប្រវត្តិសាស្ត្រ ។ និស្សិតបានអត្ថាធិប្បាយដូចខាងក្រោម ៖

«ខ្ញុំបានរៀននៅមហាវិទ្យាល័យអស់រយៈពេលបីឆ្នាំមកហើយ ។ ខ្ញុំចង់រៀនអំពីរបបកម្ពុជាប្រជាធិបតេយ្យម្តងទៀត ព្រោះខ្ញុំចាប់អារម្មណ៍លើប្រវត្តិសាស្ត្រនេះ ។ ផ្អែកលើអ្វីដែលខ្ញុំបានរៀននៅឆ្នាំសិក្សាមូលដ្ឋាន ខ្ញុំមិនបានយល់ច្បាស់នៅឡើយពីអ្វីដែលបានកើតឡើងនៅក្នុងរបបនោះទេ ។ ខ្ញុំបានត្រឹមតែយល់ដឹងព្រឹត្តិការណ៍ខ្លះៗតែប៉ុណ្ណោះ ដូច្នេះខ្ញុំចង់ដឹងច្រើនថែមទៀត» ។

ការយល់ដឹងជាមូលដ្ឋានរបស់និស្សិតទាំងអស់នេះ រួមមានព័ត៌មានទាក់ទងនឹង «ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនកម្ពុជា ការកកើតឡើងនៃរបបនេះ និងប្រវត្តិមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម» ។ ជាលទ្ធផល និស្សិតផ្សេងទៀតដូចជា លាប សាមី បានពន្យល់ពីភាពចាំបាច់ក្នុងការរៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមបែបវិភាគ និងការទទួលបានឯកសារបន្ថែមទាក់ទងនឹងការពិតពីប្រវត្តិសាស្ត្រនោះ ។ ដោយសារតែនិស្សិតរូបនេះបានដឹងពីបទពិសោធន៍រស់នៅក្រោមរបបខ្មែរក្រហមតាមរយៈឪពុកម្តាយ និងសមាជិកគ្រួសារផ្សេងៗទៀត សាមី បានសំណូមពរថាកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងផ្តល់ក្របខណ្ឌនៃការវិភាគនិងទ្រឹស្តីដែលចាំបាច់ដើម្បីសិក្សាវិភាគឲ្យស៊ីជម្រៅអំពីអតីតកាលប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាបើទោះបីជាអតីតកាលនេះមានភាពខ្មៅងងឹតក៏ដោយ ។ ការទទួលបានចំណេះដឹងទាក់ទងនឹងប្រវត្តិសាស្ត្រនេះនឹងជួយមនុស្សជំនាន់ក្រោយឲ្យខិតខំទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងម្តងទៀត និងការពារកុំឲ្យមានការបំផ្លិចបំផ្លាញមកលើប្រជាជនខ្លួន ។

## ការតម្រង់ទិស

មុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យ វាគ្មិនបានផ្តល់នូវទស្សនវិស័យមួយចំនួនទៅលើសារសំខាន់នៃគំនិតផ្តួចផ្តើមនេះ ។

សាស្ត្រាចារ្យ វង់ សុធារ៉ា អនុប្រធានផ្នែកប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានលើកឡើងពីការអាក់ខានការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមសាលាអស់រយៈពេលយ៉ាងយូរ ។ បន្ទាប់ពីការដួលរលំរបស់របបនេះនៅឆ្នាំ ១៩៧៩ «ប្រទេសកម្ពុជាស្ថិតក្នុងភាពចលាចលដោយសារការវាយប្រយុទ្ធគ្នារវាងកងទ័ព» ។

ប៉ុន្តែឥឡូវនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវ

ឯកសារយ៉ាងច្រើនទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានរៀបចំវគ្គបណ្តុះបណ្តាលលោកគ្រូ-អ្នកគ្រូនិងសាស្ត្រាចារ្យនៅទូទាំងប្រទេសទៀតផង ។ លោកសាស្ត្រាចារ្យ វ៉ន់ សុធារ៉ា ក៏បានសង្កត់ធ្ងន់ពីសារសំខាន់នៃវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យថា ៖

«វគ្គបណ្តុះបណ្តាលនេះអាចឲ្យយើងដែលជាសាស្ត្រាចារ្យបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះទៅតាមបទដ្ឋាន និងបរិបទរបស់ប្រទេសមួយដែលកំពុងតែធ្វើការអភិវឌ្ឍទៅមុខ ។ រាល់ប្រទេសអភិវឌ្ឍទាំងអស់បានផ្តោតការយកចិត្តទុកដាក់ទៅលើការសិក្សាពីប្រវត្តិសាស្ត្ររបស់ខ្លួន និងប្រវត្តិសាស្ត្ររបស់ប្រទេសនៅទូទាំងពិភពលោក ។ ការធ្វើដូច្នេះនឹងជួយពង្រឹងអត្តសញ្ញាណជាតិរបស់ខ្លួន និងកំណត់ពីអនាគតរបស់ប្រទេសជាតិទៀតផង ។ ហើយការយល់ដឹងពីសារសំខាន់នៃការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងជួយអភិវឌ្ឍប្រទេសកម្ពុជា ។ ដូចដែលអធិការបតីអាល្លឺម៉ង់លោកស្រី អែងជឺឡា មេខែល បាននិយាយនៅក្នុងសុន្ទរកថារបស់លោកស្រីទៅកាន់រដ្ឋសមាជិកថា យើងត្រូវទទួលខុសត្រូវចំពោះការលំបាកកាលពីអតីតកាលដើម្បីជួយគ្នាទៅវិញទៅមកឲ្យយល់ថា ការរៀនអំពីអតីតកាលនេះគឺមានសារសំខាន់ខ្លាំងណាស់ ។ នេះមិនមែនដើម្បីផ្ចាញ់ផ្ចាលអតីតកាលទេ ប៉ុន្តែដើម្បីផ្លាស់ប្តូរអ្វីដែលបានកើតឡើងកាលពីអតីតកាល ។ ប្រជាជនដែលមិនបានដឹងអំពីអ្វីដែលបានកើតឡើងកាលពីអតីតកាលគឺជាមនុស្សល្ងង់ ។ អាស្រ័យហេតុនេះហើយ ចំណេះដឹងអំពីរបបខ្មែរក្រហមនៅពេលនេះពិតជាមានសារសំខាន់សម្រាប់យើងទាំងអស់គ្នាដើម្បីចែករំលែក ។ ដូច្នេះ «យើងអាចលុបបំបាត់ចោលនូវវប្បធម៌ការធ្វើបាប» ។

បន្ទាប់មក លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើអត្ថាធិប្បាយអំពីសារជាតិនៃគំនិតផ្តួចផ្តើមក្នុងវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យនេះ ដោយគូសបញ្ជាក់ពីផលប្រយោជន៍ និងការកិច្ចប្រឈមដែលនឹងកើតមានឡើង ។ សាស្ត្រាចារ្យមួយចំនួន «ប្រហែលមិនចង់បង្រៀនប្រវត្តិសាស្ត្រនេះទេ ដោយសារតែសាស្ត្រាចារ្យទាំងនោះត្រូវទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត និងព្រួយបារម្ភពីរឿងនយោបាយ» ។ បន្ថែមពីនេះទៀត វាអាចជាករណីដែលថា «កូនរបស់ជនរងគ្រោះ និងកូនរបស់ជនដៃដល់កំពុងតែរៀនជាមួយគ្នានៅក្នុងថ្នាក់តែមួយដែលអាចបង្កឲ្យមានភាពតានតឹងនៅក្នុងថ្នាក់រៀន ។

នៅជិតចុងបញ្ចប់នៃកម្មវិធីបើកវគ្គជាផ្លូវការ លោកជំទាវ ទន់ សាអ៊ឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងសុន្ទរកថា ដោយសង្កត់ធ្ងន់អំពីថាតើការរៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមានសារសំខាន់សម្រាប់និស្សិតដើម្បីឲ្យ «ក្លាយខ្លួនទៅជាអ្នកជាតិនិយម និងស្រឡាញ់ប្រទេសរបស់ខ្លួន» យ៉ាងដូចម្តេច ។

ក្នុងនាមជាសសរទ្រូងរបស់សង្គមជាតិនាពេលខាងមុខ និស្សិតត្រូវតែមានលទ្ធភាព «ដោះស្រាយបញ្ហាប្រកបដោយការត្រិះរិះពិចារណា ដឹកនាំប្រទេស និងជាអ្នកធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ។ វាជា «ការព្រួយបារម្ភរបស់រដ្ឋាភិបាលដែលយុវជនប្រព្រឹត្តអំពើមិនល្អ» ហើយមុខវិជ្ជាសីលធម៌ក៏ត្រូវតែបញ្ចូលទៅក្នុងការបង្រៀនដែរ ។ នេះជាមូល


លោក វ៉ាន់ថាន់ ពៅដារ៉ា កំពុងចែកឯកសារដល់សាស្ត្រាចារ្យ

ហេតុដែលការអប់រំពីអំពើប្រល័យពូជសាសន៍ និងការផ្តួចផ្តើមវគ្គបណ្តុះបណ្តាលនេះមានសារសំខាន់យ៉ាងខ្លាំង ។ ហើយដោយសារតែការអប់រំបង្កលទ្ធភាព «ឲ្យមនុស្សអាចដោះស្រាយបញ្ហាដោយប្រើបញ្ញា» លោកគ្រូ-អ្នកគ្រូត្រូវតែកំណត់ និងប្រើប្រាស់ «បច្ចេកទេសដែលមានប្រសិទ្ធភាព និងបង្កលទ្ធភាពឲ្យនិស្សិតទាំងអស់យល់មេរៀន» ។ វាមិនមែនជាករណីដែលថា និស្សិតគួរនិងអាចរៀនតែនៅក្នុងថ្នាក់នោះទេ ។ ផ្ទុយទៅវិញ មានឯកសារនិងសម្ភារជាច្រើនដែលនិស្សិតអាចទទួលបានក្នុងពេលទំនេរ ។ វាជាការទទួលខុសត្រូវរបស់លោកគ្រូ-អ្នកគ្រូក្នុងការពង្រីកចំណេះដឹងនេះដែលធ្វើឲ្យនិស្សិតកាន់តែសកម្មផុសផុលក្នុងការស្រាវជ្រាវ ។

លោកជិទាវក៏បានចំណាយពេលខ្លះលើកឡើងអំពីភាពរីកចម្រើនដែលរដ្ឋាភិបាលបានធ្វើការផ្តួចផ្តើមគំនិតទៅលើការអប់រំបែបសិក្សមជ្ឈមណ្ឌល ដោយមានកិច្ចសហប្រតិបត្តិការពីមជ្ឈ-មណ្ឌលឯកសារកម្ពុជា ។ លោកជិទាវក៏បានលើកឡើងអំពីថាតើសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យអាចប្រើជាឯកសារយោងដ៏សំខាន់សម្រាប់សាស្ត្រាចារ្យនិងជាទិន្នន័យវិភាគសម្រាប់អ្នកស្រាវជ្រាវនិងបញ្ញវន្តដែរឬទេ ។ លោកជិទាវក៏បានលើកឡើងត្រួសៗអំពីពាក្យស្លោកប្រឆាំងពីអំពើប្រល័យពូជសាសន៍ដែលត្រូវបានដាក់ដំឡើងដោយក្រសួងអប់រំ យុវជន និងកីឡានិងមជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមវិទ្យាល័យដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញនិងបណ្តាខេត្តមួយចំនួន ។ ពាក្យស្លោកទាំងនេះមានអត្ថន័យយ៉ាងសំខាន់ដោយសារតែពាក្យស្លោកនេះរួមចំណែក «ដល់ការលុបបំបាត់ភាពអាម៉ាស់ដែលបង្កឡើងដោយរបបនោះដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងសាជាថ្មីម្តងទៀត» ។

## សកម្មភាពថ្ងៃទីមួយ

### ពេលព្រឹក

បន្ទាប់ពីពិធីបើកសម្ពោធជាផ្លូវការរួច លោក លី សុខឃាង បានពន្យល់អំពីសេចក្តីរំពឹងទុកនិងពិពណ៌នាលម្អិតអំពីរបៀបវារៈរយៈពេលបីថ្ងៃទៀត ។ ក្នុងរយៈពេលប្រាំមួយខែនៃការរៀបចំវគ្គបណ្តុះបណ្តាលនេះ លោក លី សុខឃាង បានត្រៀមសំណុំឯកសារខ្លឹមសារយោងនិងសម្ភារៈជាច្រើនទៀតសម្រាប់អ្នកចូលរួមនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ចំពោះឯកសារយោងជាសៀវភៅមានតែគម្រប និងមាតិកាប៉ុណ្ណោះត្រូវបានថតចម្លងដោយសារតែបញ្ហាសិទ្ធិនៃការថតចម្លង ។ តែទោះជាយ៉ាងណាក៏ដោយ សាស្ត្រាចារ្យត្រូវបានជូនដំណឹងថា សាស្ត្រាចារ្យទាំងអស់អាចទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រសិនបើសាស្ត្រាចារ្យណាម្នាក់ចង់បានអត្ថបទណាមួយ ។ អត្ថបទមួយចំនួនមានដូចជា «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នយោបាយ ៈ ការជួសជុលចំណុចមិនច្បាស់នៃអនុសញ្ញាប្រល័យពូជសាសន៍» អាចរកឯកសារនោះទាំងមូលតែម្តង ។ ឯកសារទាំងនោះត្រូវបានសរសេរដោយបញ្ញវន្តបរទេសនិងមានការលំបាកក្នុងការបកប្រែឯកសារទាំងអស់ទៅជាភាសាខ្មែរ ។ បទបង្ហាញរបស់សាស្ត្រាចារ្យរយៈពេលបីថ្ងៃនេះក៏ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំឯកសារដែរ ។ ដោយសារតែឯកសារចាំបាច់ភាគច្រើនត្រូវបានដាក់បញ្ចូលរួចហើយ អ្នកចូលរួមទាំងអស់ត្រូវបានតម្រូវឲ្យអានឯកសារទាំងនោះជាមុនដើម្បីឲ្យអ្នកចូលរួមអាចមានភាពងាយស្រួលក្នុងការយល់អំពីបទបង្ហាញនីមួយៗ ។

បន្ទាប់មក បណ្ឌិត ដា ផល្លា បានបន្តចាប់ផ្តើមដោយសុំឲ្យសាស្ត្រាចារ្យម្នាក់ៗណែនាំខ្លួននិងសាកលវិទ្យាល័យឬវិទ្យាស្ថានដែលសាស្ត្រាចារ្យទាំងនោះកំពុងបង្រៀន ។ បន្ទាប់ពីលំហាត់នេះ បណ្ឌិត ដា ផល្លា បាននិយាយយោងទៅកាន់កម្មវិធីបង្រៀនដែលមាននៅក្នុងសំណុំឯកសារដោយគូសបញ្ជាក់ថា សាស្ត្រាចារ្យត្រូវតែបង្កើតកម្មវិធីបង្រៀនដោយខ្លួនឯងនិងបង្ហាញជូននិស្សិតនៅពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី ។ កម្មវិធីបង្រៀននេះគឺជាកិច្ចសន្យាទៅវិញទៅមកដែលរួមមាន «កិច្ចការដែលនិស្សិតត្រូវរៀន និងអ្វីដែលសាស្ត្រាចារ្យត្រូវបង្រៀន» ។ តាមរយៈការពិភាក្សានេះ បណ្ឌិត ដា ផល្លា បានធ្វើការគូសបញ្ជាក់ពីសមាសធាតុសំខាន់ៗនៅក្នុងកម្មវិធីបង្រៀននេះ ដោយរាប់បញ្ចូលព័ត៌មានទាក់ទងនឹងអត្ថបទតម្រូវឲ្យអាន និងណែនាំឲ្យអានកិច្ចការសម្រាប់ធ្វើនិងកម្មវត្ថុរបស់វគ្គនោះ ។ បន្ទាប់មក លោក គ្រីស្តូហ្វ័រ ឌៀរីង សហនិពន្ធសៀវភៅណែនាំគ្រូបង្រៀនបានចូលមកបំពេញបន្ថែមទៅលើបទបង្ហាញរបស់បណ្ឌិត ដា ផល្លា ដោយគូសបញ្ជាក់ថា

សាស្ត្រាចារ្យត្រូវដឹងថាតើចំណេះដឹងនិងជំនាញណាដែលសាស្ត្រាចារ្យទាំងនោះចង់ឲ្យនិស្សិតរបស់ខ្លួនទទួលបាននៅក្នុងវគ្គសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ លោកបានណែនាំគ្រូសៗអំពីទ្រឹស្តីនៃការរៀនចំនួនពីរប្រភេទគឺ Bloom's Texonomy និងភាពឆ្លាតវៃច្រើនប្រភេទរបស់ Gardner ដែលនឹងត្រូវពិភាក្សានៅថ្ងៃទីបី ។

គោលរាងនេះគឺដើម្បីឲ្យយើងចងចាំទុកថា បុគ្គលម្នាក់ៗមានរបៀបនៃការសិក្សាខុសៗគ្នា ។ មានសិស្សខ្លះពូកែខាងការវិភាគស្ងាត់ដោយខ្លួនឯង ចំណែកឯសិស្សខ្លះទៀតរៀនពូកែនៅពេលដែលបានពិគ្រោះផ្លាស់ប្តូរយោបល់គ្នា ។ មានសិស្សខ្លះពូកែខាងតូរ្យតន្ត្រី និងកំណាព្យ ឯសិស្សខ្លះទៀត ពូកែខាងរាំនិងសម្តែងកាយវិការ ។ ដោយសារតែគ្រូត្រូវបង្រៀនសិស្សមានរបៀបនៃការសិក្សាខុសៗគ្នាដូចនេះគ្រូចាំបាច់ត្រូវតែស្វែងយល់ពីភាពខុសគ្នារបស់សិស្សម្នាក់ៗ ហើយត្រូវតែចេះប្រើប្រាស់នូវវិធីសាស្ត្របង្រៀនផ្សេងៗ ។

ទោះបីជាមានការលំបាកក្នុងការយល់ពីទ្រឹស្តីនេះ លោកឌៀរីង បានធ្វើការពន្យល់ដោយគូសបញ្ជាក់ថា «សិស្សម្នាក់ៗមានជំនាញខុសៗគ្នា ។ សិស្សមួយចំនួនទៀតក៏រៀនតាមវិធីខុសៗគ្នាដែរ» ។ មានសិស្សខ្លះអាចរៀនលុះត្រាតែនៅអង្គុយស្ងាត់តែម្នាក់ឯងនៅក្នុងបណ្ណាល័យខណៈពេលដែលសិស្សមួយចំនួនទៀតអាចរៀនបានលុះត្រាតែមានការប្រាស្រ័យទាក់ទងគ្នាជាក្រុមដើម្បីស្វែងយល់មេរៀនឲ្យកាន់តែច្បាស់ ។ ដូចនេះ ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង គ្រូចាំបាច់ត្រូវតែដាក់បញ្ចូលវិធីសាស្ត្ររៀនផ្សេងៗពីគ្នានៅពេលរៀបចំមេរៀនក៏ដូចជាកម្មវិធីបង្រៀនរបស់គាត់ ។

## កម្មវិធីពេលរសៀល

ក្រោយពីទទួលទានអាហារថ្ងៃត្រង់រួច មជ្ឈមណ្ឌលឯកសារកម្ពុជាមានកិត្តិយសក្នុងការអញ្ជើញលោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ដែលលោកនឹងធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាក្នុងបរិបទធំទូលាយមួយគឺសម័យសង្គ្រាមត្រជាក់ ។ លោកសាស្ត្រាចារ្យបានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃឥទ្ធិពលសង្គ្រាមត្រជាក់ទៅលើកំណើនកងកម្លាំងខ្មែរក្រហមនិងការបន្តកាន់កាប់អំណាចរហូតដល់ទសវត្សរ៍៩០ ។ នៅក្នុងអំឡុងពេលនោះប្រទេសកម្ពុជាត្រូវបានបង្ខំឲ្យធ្លាក់ចូលក្នុងសង្គ្រាមត្រជាក់បើទោះបីជាសាធារណជនដែលមិនមែនជាជនកុម្មុយនីស្តក៏ព្យាយាមចង់រក្សាអព្យាក្រឹតភាពដោយឈរនៅកណ្តាលរវាងលោកសេរីដែលគ្រប់គ្រងដោយសហរដ្ឋអាមេរិកនិងលោកកុម្មុយនីស្តដែលដឹកនាំដោយចិននិងសហភាពសូវៀត ។ ជាអកុសលនៅពេលនោះ


សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ កំពុងធ្វើបទបង្ហាញ

អព្យាក្រឹតភាពគឺអាស្រ័យទៅលើអំណាចនៃសង្គ្រាមដែលខ្លាំងជាងគេ ៖ ប្រទេសកម្ពុជាមិនមានជម្រើសនោះទេដោយសារតែខ្លួនបានក្លាយទៅជាទីតាំងឈរជើងរបស់ទ័ពវៀតណាមខាងជើង ។ អាស្រ័យហេតុនេះហើយប្រទេសកម្ពុជាបានក្លាយជាគោលដៅនៃការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកនៅចុងទសវត្សរ៍៦០ ។ ដូចដែលលោកសាស្ត្រាចារ្យបានអះអាងថាប្រទេសកម្ពុជា «គឺជាកូនអុក មិនមែនជាអ្នកលេងអុកនោះទេ ។ ហើយសហរដ្ឋអាមេរិកបានដើរចេញនៅពេលដែល

ខ្លួនចាញ់ល្បែងសង្គ្រាម» ។ នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ខ្មែរក្រហមមានបំណងបង្កើតបដិវត្តន៍មួយដោយឯករាជ្យ និងខ្លួនទីពឹងខ្លួនដោយ មិនត្រូវការអន្តរាគមន៍និងជំនួយពីសំណាក់បរទេសទេ ។ ខ្មែរក្រហមបានបដិសេធសម្ព័ន្ធភាពដែលខ្លួនបានផ្សារភ្ជាប់ពីមុនមកជាមួយប្រទេសវៀតណាមនិងចិនដើម្បីធ្វើយ៉ាងណាដកខ្លួនចេញពីឋានៈជាកូនចៅគេ ។ ប៉ុន្តែប្រទេសចិននៅតែចាត់ទុកប្រទេសកម្ពុជាថាជា «កម្លាំងដ៏ខ្លាំងក្លាដើម្បីប្រឆាំងនឹងរបបដែលគាំទ្រសហភាពសូវៀតដែលឡើងកាន់កាប់អំណាចនៅប្រទេសវៀតណាមឆ្នាំ១៩៧៥» ។ ជាក់ស្តែងណាស់ ប្រទេសកម្ពុជាបាន «ក្លាយទៅជារបស់បញ្ចាំងនៅលើក្តារអុកនៃសង្គ្រាមត្រជាក់» ។ នៅទីបញ្ចប់ សង្គ្រាមត្រជាក់នាំមកនូវការបំផ្លិចបំផ្លាញនិងភាពរងទុក្ខវេទនាមកលើប្រជាជនកម្ពុជា ។ ចំពោះលោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ មេរៀនសំខាន់បំផុតដែលយើងរៀនពីប្រវត្តិសាស្ត្រនេះគឺដើម្បី «ចងចាំប្រវត្តិសាស្ត្រ ជាពិសេសយើងមិនត្រូវបំភ្លេចចោលនូវប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃរបបខ្មែរក្រហមនោះទេ» ។

ចំណោទមួយចំនួនត្រូវបានចោទសួរឡើងនៅក្នុងវគ្គសំណួរចម្លើយដែលមានសិក្ខាកាមពីរនាក់ជាអ្នកសួរសំណួរ ។ សំណួរទីមួយសួរថា «តើមានកត្តាអ្វីខ្លះដែលបណ្តាលឲ្យខ្មែរក្រហមនាំមកនូវអំពើឃោរឃៅដល់ប្រទេសកម្ពុជា?» លោកសាស្ត្រាចារ្យបានឆ្លើយតបថាសូម្បីតែខ្លួនគាត់ក៏មិនមានចម្លើយទៅនឹងសំណួរនោះដែរ ។ តែទោះជាយ៉ាងណាក៏ដោយ លោកសាស្ត្រាចារ្យបានលើកឡើងថាខ្មែរក្រហមបានអះអាងថាខ្លួនពុំមានបទពិសោធន៍គ្រប់គ្រងរដ្ឋនោះទេ ទោះបីជាខ្លួនបានព្យាយាមអនុវត្តនូវគោលនយោបាយក្នុងការគ្រប់គ្រងយ៉ាងណាក៏ដោយ ។ ខ្មែរក្រហមមានបំណងបោះជំហានលឿនហួសហេតុពេកដើម្បីបញ្ជាក់ថាខ្លួនធ្វើបដិវត្តន៍ខ្លាំងក្លាជាងនៅប្រទេសចិននិងវៀតណាមទៅទៀត ។ ដូចដែលលោកសាស្ត្រាចារ្យមានប្រសាសន៍ថា «ខ្មែរក្រហមគឺហាក់ដូចជាឡានមួយគ្រឿងដែលបើកចុះចំណោទលឿនខ្លាំងពេករហូតទាល់តែដាច់កង់ចេញមកក្រៅ» ។ មានសិក្ខាកាមមួយចំនួនទៀតមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើទំនាស់រវាងចិននិងវៀតណាមនិងឥទ្ធិពលរបស់ទំនាស់នេះមកលើរបបខ្មែរក្រហម ។ លោកសាស្ត្រាចារ្យបានលើកជាទូទៅថា «ប្រទេសវៀតណាមគឺតែងតែមានការខឹងសម្បានិងខ្លាចញញើតប្រទេសចិនណាស់ ។ កាលពីពេលនោះសហភាពសូវៀតនិងប្រទេសចិននៅតែជាសត្រូវនឹងគ្នា ។ ប្រសិនបើខ្មែរក្រហមចូលដៃចូលជាមួយប្រទេសចិននេះគឺជាអ្វីដែលវៀតណាមនឹងមិនអនុញ្ញាតទេ» ។ ប្រទេសវៀតណាមដឹងថាខ្លួន «ចាំបាច់ត្រូវតែបញ្ឈប់ខ្មែរក្រហមដោយសារតែប្រទេសចិនកំពុងតែឈ្នះប្រទេសជិតខាងរបស់ខ្លួនទាំងអស់» ។

ជាកិច្ចបន្ទាប់ លោក ឌី ខាំបូលី បានធ្វើបទបង្ហាញបន្ថែមទៅនឹងបទបង្ហាញរបស់លោកសាស្ត្រាចារ្យ ឆេនដល័រ ដោយដំបូងធ្វើការពិពណ៌នាបន្តិចអំពីសៀវភៅរបស់លោកនិងរៀបរាប់អំពីព្រឹត្តិការណ៍បន្ថែមដែលកើតឡើងមុនពេលនិងអំឡុងពេលដែលខ្មែរក្រហមកាន់កាប់អំណាច ។ សង្គ្រាមត្រជាក់គឺពិតប្រាកដណាស់ជាកត្តាមួយដែលនាំឲ្យមានរបបខ្មែរក្រហមកើតឡើង ។ ប៉ុន្តែរបបនេះមិនមែនកើតចេញពីកត្តាតែម្យ៉ាងនោះទេ ។ យើងគួរតែពិចារណាទៅលើការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនិងការឃោសនារបស់សម្តេច សីហនុ ក្រោយរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ១៩៧០ ដែលទាំងនេះបានធ្វើឲ្យកងកម្លាំងខ្មែរក្រហមកាន់តែកើនឡើងច្រើន ។ មានប្រជាជនកម្ពុជាជាច្រើនបានបាត់បង់សមាជិកគ្រួសារដោយសារតែការទម្លាក់គ្រាប់បែក ។ ហេតុដូចនេះ អ្នកទាំងនោះគិតថាជាតួនាទីរបស់ខ្លួនក្នុងការចូលរួមចលនានេះដើម្បីវាយរំដោះប្រទេស ។ អ្នកទាំងនេះក៏ទទួលបានការអំពាវនាវរបស់សម្តេចឲ្យ «កូនចៅទាំងអស់ចូលព្រៃម៉ាគីដើម្បីតស៊ូនិងទាមទារយកអំណាចមកវិញ» ។ ជាលទ្ធផល ចំនួននៃកងយោធាខ្មែរក្រហម «បានកើនឡើងពី៣.០០០ទៅ៣០.០០០នាក់ក្នុងរយៈពេលបីឆ្នាំ» ។

មានអ្នកស្រាវជ្រាវផ្សេងៗជាច្រើនបានផ្តល់ទ្រឹស្តីខុសៗគ្នាថាតើនឹងមានអ្វីកើតឡើងក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ១៩៧៥ ។ ចំពោះលោក ឌី ខាំបូលី មនោគមន៍វិជ្ជាខ្មែរក្រហមគឺមានលក្ខណៈថ្មីស្រឡាងហើយដាច់ខាត ដោយសារតែរបបនេះមានបំណងចង់បង្កើត «ប្រទេសសង្គមនិយមមួយដែលល្អប្រសើរជាងប្រទេសណាៗទៀត ដូចជាចិននិងវៀតណាម» ។ មនោគមន៍វិជ្ជាបែបនេះគឺគ្រាន់តែជាសុបិន

មួយដែលមិនអាចសម្រេចបានប៉ុណ្ណោះ ។ ចក្កុវិស័យជ្រុលនិយម របស់ ប៉ុល ពត បានដឹកនាំប្រជាជនកម្ពុជាទៅរកជ្រោះមរណៈ ។ របបនេះតែងតែព្យាយាមធ្វើការកម្ទេចខ្មាំងស៊ីរូងផ្ទៃក្នុងព្រោះថា មានតែកម្ទេចខ្មាំងចោលអស់នោះទេ ទើបអាចធ្វើឲ្យចលនានេះបន្តឋិតថេរបាន ។ ខ្មែរក្រហមក៏ព្យាយាមសម្លាប់អ្នកទាំងឡាយណាដែលមានឈាមជ័រជាវៀតណាមឬអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយសម្តេច សីហនុ ។ ចំពោះអ្នកផ្សេងទៀត ខ្មែរក្រហមសង្ស័យថាអ្នកទាំងនេះគឺជាសមាជិកគិញសម្ងាត់ កា.ហ្សេ.បេ និង សេ.អ៊ី.អា ដែលមានបំណងចង់ «លេប» ទឹកដីកម្ពុជា ។ ដូចអ្វីដែលលោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងនៅក្នុងបទបង្ហាញរបស់គាត់ពីខាងដើម លោក ឌី ខាំបូលី បានបញ្ជាក់ម្តងទៀតដែរថា ខ្មែរក្រហមមានបំណងចង់ផ្លាស់ប្តូរប្រទេសកម្ពុជាឲ្យក្លាយទៅជាប្រទេសមួយដែលឯករាជ្យ ហើយមិនទទួលឥទ្ធិពលពីប្រទេសមហាអំណាចនោះទេ ។ ដើម្បីសម្រេចគោលបំណងនេះរបបខ្មែរក្រហមចាំបាច់ត្រូវតែដកហូតអំណាចពីអ្នកមានចំណេះដឹងទាំងអស់ទៅឲ្យកសិករក្រីក្រវិញ ។

ខ្មែរក្រហមបានរឹតបន្តឹងគោលនយោបាយសមូហភាពរបស់ខ្លួនដែលមានឥទ្ធិពលតាំងពីឆ្នាំ១៩៧៣មកម៉្លេះ ។ សហករណ៍ត្រូវបានបង្កើតឡើងនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ដើម្បីចៀសវាងនូវរាល់កម្មសិទ្ធិបុគ្គលទាំងឡាយនិងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។ របបនេះជឿជាក់ថាខ្លួន «អាចកសាងឯករាជ្យភាពរបស់ប្រជាជនកម្ពុជាដែលមានតែតាមមធ្យោបាយនេះទេទើបធ្វើឲ្យប្រជាជនរស់នៅដោយខ្លួនឯង» ។ របបនេះអនុវត្តគោលនយោបាយខ្លួនទីពឹងខ្លួន ព្រោះធ្វើបែបនេះប្រជាជនកម្ពុជាមិនចាំបាច់ពឹងផ្អែកទៅលើប្រទេសមហាអំណាចផ្សេងៗដើម្បីរស់នោះទេ ។ សហករណ៍ត្រូវបានយល់ឃើញថាជា «កម្លាំងស្នូលនៅក្នុងការកសាងប្រទេសជាតិ» ទៅវិញ ។ ដើម្បីបញ្ជាក់អំពីភាពស្មោះត្រង់និងលះបង់របស់ខ្លួនចំពោះអង្គការប្រជាជនទាំងអស់ត្រូវបានបង្ខំឲ្យចូលរួមការប្រជុំស្វ័យទិតៀនដែលធ្វើឡើងក្រោយពេលប៉ុន្មានម៉ោងបន្ទាប់ពីការធ្វើស្រែ ។ ក្នុងករណីដែលអ្នកត្រូវបានទិតៀន ហើយមិនបានខិតខំប្រឹងប្រែងកែប្រែ «កំហុស» របស់ខ្លួន អ្នកទាំងនោះនឹងត្រូវបាននាំទៅអប់រំឬសម្លាប់ចោល ។ ចំពោះអ្នកដែលមិនខិតខំបំពេញកិច្ចការរបស់ខ្លួនត្រូវបានចាត់ទុកថាជាសត្រូវដែលមានបំណងចង់រារាំងការអភិវឌ្ឍដំណើរការរបស់សង្គមថ្មីមួយនេះ ។

បន្ទាប់ពីបទបង្ហាញរបស់លោក ឌី ខាំបូលី គឺមានវគ្គសំណួរចម្លើយខ្លីមួយ ។ សិក្ខាកាមម្នាក់មានបំណងចង់ដឹងថាតើ ប៉ុល ពត មានគំនិតចង់បន្សុទ្ធ «អត្តចរិត» របស់ប្រជាជនកម្ពុជាដោយរបៀបណា ។ លោក ឌី ខាំបូលី បាននិយាយថា ប៉ុល ពត ចង់ជួយអ្នកក្រដែលត្រូវបានជិះជាន់ដោយពួកអ្នកមាន ។ ប៉ុន្តែ



សាស្ត្រាចារ្យ ឡៅ សុផល ឆ្លើយសួរសំណួរទៅវាគ្មិន

ចំពោះ ប៉ុល ពត ដើម្បីយកឈ្នះអ្នកដែលគាបសង្កត់នេះគឺចាំបាច់ត្រូវប្រើប្រាស់វិធីសាស្ត្របដិវត្តន៍ ។ ប៉ុល ពត បានអានសៀវភៅកុម្មុយនីស្តជាច្រើនដែលរៀបរាប់ពិស្តារអំពីចលនានៅប្រទេសកូរ៉េខាងជើង វៀតណាម ចិន និងយូហ្គោស្លាវី ហើយបន្ទាប់មកព្យាយាមធ្វើការបញ្ចូលចម្រុះនូវមនោគមន៍វិជ្ជាទាំងនោះ ។ ការពិភាក្សានេះក៏បានឈានទៅដល់នាទីគួរឲ្យចាប់អារម្មណ៍នៅពេលដែលសិក្ខាកាមម្នាក់ចោទសំណួរថា ចំពោះបុគ្គលដែលទទួលយក

ការឃោសនារបស់ ប៉ុល ពត នឹងមិនចាត់ទុករបបនេះថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ ។ លោក អេង កុកថាយ បានផ្តល់អំណះអំណាងវិញថា វាមិនអាចនឹងចៀសវាងបានដែរ ដោយសារតែការឃោសនានេះគឺនិយាយតែមួយជ្រុងនៃរបបខ្មែរក្រហមប៉ុណ្ណោះ ។ ការស្រាវជ្រាវជាច្រើនត្រូវបានធ្វើឡើងស្តីពីរបៀបដែលរបបនេះប្រើប្រាស់នូវបទចម្រៀង ពាក្យស្លោក និងឯកសារផ្សេងៗ ដើម្បីទៅគ្រប់គ្រងប្រជាជនខ្លួនឯងនិងដើម្បីអាច




ធ្វើឲ្យមានការអនុវត្តគោលនយោបាយនៃការបង្ខំឲ្យធ្វើការនិងការសម្លាប់រង្គាល ។ បទសម្ភាសន៍ដែលធ្វើឡើងជាមួយអ្នករស់រានមានជីវិតពីរបបនោះ និងការលាតត្រដាងអំពីទីតាំងសម្លាប់រង្គាលគឺសុទ្ធតែជាភស្តុតាងមួយបញ្ជាក់ថាមានរឿងរ៉ាវសោកនាដកម្មជាច្រើនបានកើតមានឡើងមែន ដែលខុសទាំងស្រុងពីអ្វីដែលខ្មែរក្រហមបានលើកឡើងនោះ ។ លោក លី សុខឃាង បានបន្ថែមថា ឯកសារប្រវត្តិសាស្ត្រអាចធ្វើឲ្យមនុស្សមើលឃើញពីការពិតនៃអ្វីដែលបានកើតមានឡើងពិតប្រាកដកាលពីជំនាន់នោះ ។ នេះគឺច្បាស់ណាស់ថាមានតែតាមរយៈការអប់រំពីអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះដែលអាចធ្វើឲ្យក្មេងជំនាន់ក្រោយមានការយល់ដឹងពិតប្រាកដនិងត្រឹមត្រូវអំពីដំណើររឿងប្រវត្តិសាស្ត្រនេះ ។

មានសិក្ខាកាមម្នាក់ទៀតបានស្ម័គ្រចិត្តឡើងបញ្ចេញយោបល់ឲ្យអង្គពិធីទាំងមូលធ្វើការពិចារណាអំពីគោលបំណងនៃសំណេរនេះ ។ ឧទាហរណ៍ សៀវភៅមេរៀនរបស់លោក ឌី ខាំបូលី គឺជាសៀវភៅប្រវត្តិសាស្ត្រមួយដែលមិនមែនសរសេរឡើងដោយផ្អែកទៅលើនិន្នាការនយោបាយអ្វីនោះទេ ចំណែកឯកសារខ្មែរក្រហមវិញគឺជាឯកសារឃោសនាដែលមានទិសដៅបង្ហាញឲ្យឃើញពីអាការៈខាងក្រៅរបស់របបនេះតែប៉ុណ្ណោះ ។ ចំណែកឯសិក្ខាកាមម្នាក់ទៀតមិនយល់ស្របទៅនឹងអំណះអំណាងនេះទេ ដោយលើកឡើងថា សារសំខាន់នៃឯកសារនិងទម្រង់នៃភស្តុតាងផ្សេងៗគឺត្រូវបានកំណត់ដោយអ្នកដែលពិនិត្យនិងបកស្រាយឯកសារនោះប៉ុណ្ណោះ ។ អាស្រ័យហេតុនេះហើយ នេះគឺជាតួនាទីរបស់ក្មេងជំនាន់ក្រោយក្នុងការបកស្រាយនិងវាយតម្លៃអ្វីដែលបានកើតឡើងកាលពីពេលនោះតាមរយៈការវិនិច្ឆ័យដោយខ្លួនឯង និងពិនិត្យយ៉ាងល្អិតល្អន់ទៅលើឯកសារឃោសនារបស់ខ្មែរក្រហម ព្រមទាំងការស្រាវជ្រាវផ្សេងៗដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាប័នផ្សេងៗទៀត ។ ដូចនេះប្រវត្តិសាស្ត្រមិនមែនត្រូវបានកំណត់ឡើងដោយពឹងផ្អែកទៅលើ «អង្គហេតុ» (ជាក់លាក់) នោះទេ តែប្រវត្តិសាស្ត្រគឺជាការពិពណ៌នាដែលត្រូវបានតាក់តែងឡើងដោយមានការវិនិច្ឆ័យ ការជ្រើសរើសនិងការបកស្រាយដែលមានសភាពខុសៗគ្នាទៅតាមបុគ្គលម្នាក់ៗដោយផ្អែកលើអំណះអំណាងសមហេតុផល ។

**សកម្មភាពក្នុងថ្ងៃទីពីរ ៖**

**កម្មវិធីពេលព្រឹក ៖**

នៅវេលាម៉ោងប្រាំបីព្រឹក លោក អេង កុកថាយ និងលោក ឡុង ដានី ដែលអញ្ជើញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយណែនាំអំពីខ្សែភាពយន្តឯកសារទាំងបីដែលនឹងយកមកបញ្ចាំងមានដូចជា «តំបន់រំដោះក្នុងឆ្នាំ១៩៧៣» «គុកភ្នំបាសិទ្ធិ» និង «កុមារកម្ពុជា» ។ ខ្សែភាពយន្តឯកសារនេះគឺជាកម្មសិទ្ធិរបស់

រដ្ឋាភិបាលវៀតណាម រហូតដល់ឆ្នាំ២០០៩ ទើបមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានខ្សែភាពយន្តនេះ ។ ខ្សែភាពយន្តឯកសារទាំងបីនេះសុទ្ធតែអមដោយបទចម្រៀង « ឱ!ភ្នំពេញ អើយ!» បើទោះបីជាខ្សែភាពយន្តឯកសារទីបីមានការសន្ទនាជាភាសាវៀតណាមក៏ដោយ ។ ខ្សែភាពយន្តឯកសារដែលមានចំណងជើងថា «តំបន់រំដោះក្នុងឆ្នាំ១៩៧៣» គឺជាឯកសារឃោសនាមួយដែលផលិតឡើងនៅក្នុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូរណសិរ្សរំដោះមួយក្រុមមកពីប្រទេសវៀតណាមខាងត្បូង ។ នៅក្នុងខ្សែភាពយន្តឯកសារនេះបានរៀបរាប់បង្ហាញដោយខ្លីៗអំពីទិដ្ឋភាពនៃតំបន់ដែលកាន់កាប់ដោយខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៣ ៖ ទាហានលើកបីកូនក្មេងអ្នកភូមិធ្វើការនៅវាលស្រែដោយភាពសប្បាយរីករាយ ហាលស្បែកពស់ថ្លាន់ បោកស្រូវ និងត្បាញ ។ ខ្សែភាពយន្តឯកសារនេះក៏អាចមើលឃើញ ខៀវ សំផន និង សុន សេន ដែលជាអ្នកដឹកនាំដំណើរទស្សនកិច្ចដែរ ។ «គុកភ្នំបាសិទ្ធិ» គឺជាខ្សែភាពយន្តឯកសារទីមួយដែលបានផលិតឡើងដោយកងទ័ពវៀតណាមនៅក្រោយពេលដែលកងទ័ពវៀតណាមបានវាយរំដោះទីក្រុងភ្នំពេញចេញពីកណ្តាប់ដៃរបស់ខ្មែរក្រហម ។ ឯកសារនេះបានចងក្រងអំពីចំណាប់អារម្មណ៍ដំបូងបង្អស់របស់កងទ័ពវៀតណាមមកលើបរិវេណមន្ទីរឃុំឃាំងស-២១ ដែលត្រូវបានបោះបង់ចោលដោយខ្មែរក្រហម ។ ភាពយន្តឯកសារនេះបានរៀបរាប់ពីបរិវេណខាងក្រៅនៃអាគារនេះនិងទិដ្ឋភាពពីបន្ទប់មួយទៅបន្ទប់មួយទៀតដែលបង្ហាញអំពីគំនរខ្មោះ គុកតូចៗនិងរូបថតរបស់អ្នកស្លាប់នៅមន្ទីរស-២១ជាច្រើនដែលថតដោយខ្មែរក្រហម ។ ខ្សែភាពយន្តនេះក៏បានបង្ហាញអំពីសាកសពស្អុយរលួយដែលជាប់នឹងរនាំងខ្មោះក្នុងថ្នុកឈាម ។

ខ្សែភាពយន្តឯកសារទីបីដែលមានចំណងជើងថា «កុមារកម្ពុជា» ត្រូវបានផលិតឡើងដោយវៀតណាមដើម្បីធ្វើការប្រៀបធៀបរវាងកុមារនៅប្រទេសកម្ពុជានិងបស្ចិមប្រទេស ។ រូបភាពនៃកុមារកម្ពុជាធ្វើការនៅក្នុងវាលស្រែ មើលថែប្អូនៗ ហើយមានរូបរាងស្គមស្គាំងដោយសារតែការបង្អត់អាហារត្រូវបានដាក់ប្រៀបធៀបទៅនឹងរូបភាពរបស់កុមារនៅបស្ចិមប្រទេសដែលរូបភាពស្រស់ស្រាយនិងញញឹមញញែម ។ រូបភាពនៅទួលស្លែងក៏ត្រូវយកមកប្រៀបធៀបជាមួយរូបភាពនៅសាលារៀនរបស់ក្មេងនៅបស្ចិមប្រទេសដែរ ។

ភាគច្រើននៅពេលទស្សនាភាពយន្តឯកសារនេះ សិក្ខាកាមទាំងអស់សុទ្ធតែយកចិត្តទុកដាក់ទស្សនាភាពយន្តឯកសារនេះដោយភាពស្ងៀមស្ងាត់ ។ ខ្សែភាពយន្តទីបីដែលបានបង្ហាញអំពីកុមារកំពុងតែហូបស្លឹកឈើបានធ្វើឲ្យសិក្ខាកាមភាគច្រើនខ្សឹបខ្សៀវពិភាក្សាគ្នាពីប្រភេទនៃស្លឹកឈើនោះ តែបន្តិចក្រោយមកក៏បាត់សំឡេងទៅវិញ ។


និស្សិតចូលរួមក្នុងសិក្ខាសាលា

លោក ឡុង ដានី បានសួរទៅកាន់សិក្ខាកាមទាំងអស់អំពីយោបល់របស់សិក្ខាមចំពោះខ្សែភាពយន្តទាំងបីនេះ ហើយក៏ចាប់ផ្តើមបើកវេទិកាសួរសំណួរផងដែរ ។ សំណួរទីមួយសួរថាតើតំបន់ណាខ្លះឬផ្នែកណាខ្លះរបស់ប្រទេសកម្ពុជាដែលទទួលរងទុក្ខវេទនាជាងគេ? ហើយតំបន់ណាខ្លះដែលមិនសូវជាទទួលរងនោះ? លោក ឡុង ដានី បានឆ្លើយតបដោយបង្វែរការចាប់អារម្មណ៍របស់សិក្ខាកាមទាំងអស់ទៅលើខ្សែភាពយន្តឯកសារ ។ ភាពយន្តឯកសារទីមួយដែលបង្ហាញពីតំបន់រំដោះរបស់ខ្មែរក្រហមមិនបង្ហាញអំពីការឈឺចាប់អ្វីនោះទេ ដោយសារតែឯកសារ

នេះគ្រាន់តែចង់បញ្ជាក់អំពីជ័យជម្នះរបស់ខ្មែរក្រហមតែប៉ុណ្ណោះ ។ ភាពយន្តឯកសារទីពីរ និងទីបីចង់បង្ហាញអំពីផលប៉ះពាល់របស់របបនេះមកលើប្រជាជនកម្ពុជាដែលឆ្លុះបញ្ចាំងអំពីទុក្ខសោកយ៉ាងខ្លាំងក្លា ។ តំបន់នីមួយៗកាលពីជំនាន់នោះមាន កម្រិតនៃការទទួលរងទុក្ខវេទនាមិនដូចគ្នានោះទេ ។

អ្នកសួរសំណួរទីពីរមានការត្អូញត្អែរទៅនឹងខ្សែភាពយន្តឯកសារទាំងបីដែលមិនបានឆ្លុះបញ្ចាំងទៅលើការរងទុក្ខវេទនាខុសៗគ្នាពីតំបន់មួយទៅតំបន់មួយទៀតនៃសម័យ ប៉ុល ពត ។ មិនស្មើគ្នានៅតាមតំបន់នីមួយៗ ដោយបញ្ជាក់ទៀតថា តំបន់ខ្លះទទួលរងការកាប់សម្លាប់ច្រើនជាងតំបន់ខ្លះទៀត ។ ដូចនេះគាត់យល់ឃើញថា នេះគឺជាការសម្គាល់ណាស់កាលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការស្រាវជ្រាវបន្ថែម និងធ្វើការប្រៀបធៀបពីតំបន់មួយទៅតំបន់មួយទៀត ។

អ្នកសួរសំណួរបន្ទាប់ទៀតបានបង្ហាញអំពីសំណូមពររបស់ខ្លួនទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យបែងចែកតំបន់ទៅតាមវិសាលភាពនៃការកាប់សម្លាប់ ។ សាស្ត្រាចារ្យរូបនេះក៏



បណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ កំពុងធ្វើបទបង្ហាញ

គាត់បាននិយាយយ៉ាងខ្លាំងៗពីខ្សែភាពយន្តឯកសារទាំងនេះដែលមានតែរូបភាព ប៉ុន្តែគ្មានសំឡេង ។ លោក ឡុង ដានី បាននិយាយថា ភាពយន្តឯកសារទីមួយនិងទីពីរឯកសារគ្មានសំឡេងទេ តែខ្សែភាពយន្តឯកសារទីបីមានសំឡេងជាភាសាវៀតណាម ។ អ្នករៀបចំកម្មវិធីនេះក៏បានបញ្ជាក់បន្ថែមថា ការដែលមិនបានបើកសំឡេងនៅក្នុងភាពយន្តឯកសារទីបីគឺដោយសារតែយល់ឃើញថាខ្លាចមានការរំខានដល់ការទស្សនារបស់សិក្ខាកាមទាំងអស់គ្នាទើបសម្រេចចិត្តបិទសំឡេង ។

សំណួរបន្ទាប់ទៀតនៅតែផ្តោតទៅលើភាពរងទុក្ខវេទនា សង្កត់ធ្ងន់ដែរថា មិនមែនមានតែមនុស្សស្លាប់ដោយសារការកាប់សម្លាប់នោះទេ តែមានមនុស្សជាច្រើនទៀតបានស្លាប់ដោយសារជំងឺនិងការបង្អត់អាហារ ។ ដូចនេះអត្រាមនុស្សស្លាប់មិនមែនគ្រាន់តែរាប់មើលតាមរណ្តៅសាកសពនោះទេ គឺមនុស្សជាច្រើនដែលស្លាប់នៅតាមផ្ទះនិងកន្លែងផ្សេងទៀតដែលមិនមាននរណាដឹង ។ ហើយគាត់ក៏ឆ្ងល់ថាតើមូលហេតុអ្វីបានជាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនទៅទីក្រុងហូជីមិញដើម្បីប្រមែប្រមូលយករូបភាពឯកសារផ្សេងៗទៀត ។ លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបានឆ្លើយសំណួរនេះដោយនិយាយថា ការប្រើ

ប្រាស់ខ្សែភាពយន្តឯកសារនេះគឺដើម្បីឲ្យលោកគ្រូ-អ្នកគ្រូទាំងអស់ចេះប្រើប្រាស់វាជាឧបករណ៍បង្រៀនដើម្បីបណ្តុះឲ្យមានការពិភាក្សាបន្ថែមទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពយន្តឯកសារបែបនេះជាង២២០ ដែលភាគច្រើនភាពយន្តឯកសារនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងនៅតុលាការ ដូចនេះហើយទើបមជ្ឈមណ្ឌលមិនអាចធ្វើការចែកចាយផ្សព្វផ្សាយបានរហូតទាល់តែតុលាការនេះបិទសវនាការចប់សព្វគ្រប់ ។ លោកក៏បានបញ្ជាក់បន្ថែមទៀតដែរថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងរៀបចំឲ្យសាធារណជនអាចស្វែងរកឯកសារ រូបភាពក៏ដូចជាឯកសារផ្សេងៗនៅពេលដែលមជ្ឈមណ្ឌលអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានកសាងឡើង ។ លោកក៏បានបញ្ជាក់បន្ថែមដែរថា មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការបោះពុម្ពសៀវភៅមួយស្តីពីឥទ្ធិពលនៃរបបខ្មែរក្រហមមកលើតំបន់ផ្សេងៗក្នុងអំឡុងពេលពីរឆ្នាំខាងមុខនេះ ។ ទាក់ទងទៅនឹងចំនួនមនុស្សស្លាប់ លោកបាននិយាយថា នៅក្នុងឯកសារឆ្នាំ១៩៨១-១៩៨២គឺបានឲ្យតួលេខអ្នកស្លាប់ដល់ទៅជាង៣,៣លាននាក់ ឯណោះខណៈពេលដែលលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ផ្តល់តួលេខត្រឹមតែ១,៧លានតែប៉ុណ្ណោះ ។ លោកក៏បានបញ្ជាក់ថា តួលេខនេះនៅតែមានភាពសុក្រឹតនៅឡើយទេ ដោយសារតែការស្រាវជ្រាវទាំងនេះមិនបានអនុវត្តទៅតាមគោលការណ៍ប្រជាសាស្ត្រពិតប្រាកដ ។

នៅពេលដែលបញ្ចាំងរូបភាពឯកសាររួច បណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ បានចាប់ផ្តើមពិភាក្សាអំពីប្រធានបទរបស់លោកដែលនិយាយអំពី «ព្រឹត្តិការណ៍សំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជាពីឆ្នាំ១៩៤៥ដល់១៩៧៥» ។ បណ្ឌិតសភាចារ្យបានលើកពីការវិវឌ្ឍនៃប្រធានបទប្រវត្តិសាស្ត្រដែលមានការផ្លាស់ប្តូរតាមសម័យកាលតាំងពី៥០០ឆ្នាំមុនគ.ស ។ នាពេលបច្ចុប្បន្ននេះប្រវត្តិសាស្ត្រមានលក្ខណៈជាវិទ្យាសាស្ត្រ ។ អ្នកប្រវត្តិសាស្ត្រមិនត្រឹមតែធ្វើការកត់ត្រាទុកព្រឹត្តិការណ៍នានាដែលកើតឡើងនោះទេ តែចាំបាច់ត្រូវចេះចោទសួរពីមូលហេតុនៃការកើតឡើងនៃព្រឹត្តិការណ៍ដែរ ។

បន្ទាប់មក បណ្ឌិតសភាចារ្យពិភាក្សាអំពីស្ថានភាពនយោបាយសកលលោកមុនសង្គ្រាមលោកលើកទីពីរនិងការចាប់ផ្តើមមានសង្គ្រាមត្រជាក់នៅពេលដែលមានការឈ្លានពានមកលើប្រទេសឆេកូស្លូវ៉ាគីពីសំណាក់មហាអំណាចសហភាពសូវៀតនៅក្នុងឆ្នាំ១៩៤៨ និងការសាយភាយរបស់សង្គ្រាមនេះមកដល់អាស៊ីនៅពេលម៉ៅទទួលបានជ័យជម្នះនៅក្នុងឆ្នាំ១៩៤៩ ។ លោកបណ្ឌិតបានបន្តថា ការហៅថាសង្គ្រាមត្រជាក់នេះគឺដោយសារមានតែប្រទេសតូចតាចតែប៉ុណ្ណោះដែលវាយប្រហារគ្នា ។ លោកបណ្ឌិតបន្ថែមទៀតថា សហរដ្ឋអាមេរិកមានការចាប់អារម្មណ៍មកលើអាស៊ីអាគ្នេយ៍ដោយសារតែកត្តាពាណិជ្ជកម្ម និងទ្រឹស្តីដូមីណូដែលថា បើប្រទេសមួយធ្លាក់ចូលក្នុងរបបកុម្មុយនីស្ត នោះប្រាកដជាជះឥទ្ធិពលមកដល់ប្រទេសជិតខាងជាមិនខាន ។

នៅក្នុងដំណាក់កាលនេះព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានប្រកាន់យកនូវគោលនយោបាយអព្យាក្រឹត ។ ប្រទេសកម្ពុជានៅតែទទួលការគំរាមកំហែងពីប្រទេសថៃនិងវៀតណាមខាងត្បូង ។ ព្រះមហាក្សត្រមានការសង្ស័យទៅលើពួកឆ្វេងនិយមនិងស្តាំនិយមដែលបណ្តាលឲ្យព្រះអង្គអនុវត្តគោលនយោបាយយ៉ាងតឹងរ៉ឹងដើម្បីធានាឲ្យបាននូវអាព្យាក្រឹតភាពរបស់កម្ពុជា ។ ជាលទ្ធផល ជម្លោះផ្ទៃក្នុងកើតឡើង ។ ព្រះមហាក្សត្របានអនុវត្តគោលការណ៍មួយដើម្បីសម្លាប់សមាជិកដែលប្រឆាំងនឹងព្រះអង្គ ។ បន្ទាប់មក រដ្ឋប្រហារឆ្នាំ១៩៧០ លន់ នល់ ក៏អនុវត្តនូវគោលនយោបាយសម្លាប់គូបដិបក្ខនេះដែរ ហើយខ្មែរក្រហមក៏អនុវត្តដូចគ្នាផងដែរ ។ វេទិកាសួរសំណួរផ្តោតទៅលើការយល់ដឹងឲ្យកាន់តែច្បាស់ថែមទៀតទាក់ទិននឹងគោលបំណងនៅខាងក្រោយសកម្មភាពសង្គ្រាមត្រជាក់ ។ សិក្ខាកាមម្នាក់មានការងឿងឆ្ងល់អំពីរបៀបនៃការកំណត់ពេលវេលាសង្គ្រាមត្រជាក់ដោយសារតែលោកបណ្ឌិតសភាចារ្យបានលើកឡើងថា ឆ្នាំ១៩៤៨គឺជាការចាប់ផ្តើមសង្គ្រាមត្រជាក់ ខណៈពេលដែលលោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ បានលើកឡើងនៅក្នុងបទបង្ហាញរបស់លោកថា សង្គ្រាមត្រជាក់គឺចាប់ផ្តើមនៅឆ្នាំ១៩៤៦ទៅវិញ ។ លោកបណ្ឌិតសភាចារ្យបានឆ្លើយតបថាកាលបរិច្ឆេទទាំងពីរនេះគឺត្រឹមត្រូវដូចគ្នា ។ ការដែលលោកលើកឡើងបែបនេះដោយសារតែឆ្នាំ១៩៤៨ គឺជាឆ្នាំដែលសហភាពសូវៀតវាយលុកចូលប្រទេសឆេកូស្លូវ៉ាគី ។ សិក្ខាកាម

ម្នាក់ទៀតចង់ដឹងអំពីថាតើបដិវត្តន៍ផ្កាម្ល៉ិះដែលកើតឡើងនាពេលថ្មីៗនេះអាចប្រៀបធៀបទៅនឹងអ្វីដែលកើតឡើងនៅក្នុងសង្គ្រាមត្រជាក់បានទេ ។ លោកបណ្ឌិតបានកត់សម្គាល់អំពីភាពដូចគ្នានៅក្នុងកាលៈទេសៈទាំងពីរ ។ អ្នកដែលមានអំណាចនៅក្នុងដៃដឹងអំពីអំណាចរបស់អ្នកឲ្យ និងការគាបសង្កត់មកលើខ្លួន ហើយក៏ជ្រើសរើសយកការវាយប្រឆាំងនឹងការគាបសង្កត់នោះ ។ ដូចគ្នាដែរទៅនឹងបដិវត្តន៍ផ្កាម្ល៉ិះគឺមានយុទ្ធសាស្ត្រជាច្រើនដែលយកមកប្រើប្រាស់នៅក្នុងការវាយប្រហារប្រឆាំងទៅនឹងការគាបសង្កត់ដោយខ្លះមានសភាពឃោរឃៅ ហើយខ្លះទៀតបានធ្វើឡើងដោយសន្តិភាព ដែលទាំងនេះស្ថិតនៅលើកម្រិតនៃការពាក់ព័ន្ធរបស់ប្រទេសមហាអំណាចតែប៉ុណ្ណោះ ។ សំណួរមួយទៀតបានចោទសួរថាតើអំពើប្រល័យពូជសាសន៍នឹងអាចចៀសវាងបានទេ ប្រសិនបើមិនមានទំនាស់នៅក្នុងខ្សែស្រឡាយព្រះរាជវង្ស? លោកបណ្ឌិតបានឆ្លើយតបថា ទោះបីជាការគាំទ្ររបស់សម្តេចបានបន្ថែមនូវភាពស្របច្បាប់ដល់ខ្មែរក្រហមក៏ដោយ ក៏ការឡើងកាន់អំណាចរបស់ខ្មែរក្រហមគឺមានពាក់ព័ន្ធទៅនឹងកត្តាអន្តរជាតិជាជាងកត្តាខ្សែរាជវង្ស ។ សំណួរមួយទៀតក៏បានចោទឡើងទាក់ទងនឹងគោលបំណងរបស់ប្រទេសវៀតណាមនៅពេលចូលមកទីក្រុងភ្នំពេញដែលបន្ទាប់មកបន្តការកាន់កាប់រហូតដល់ឆ្នាំ១៩៨៩ ។ លោកបណ្ឌិតសភាចារ្យបានឆ្លើយតបថា គាត់នឹងប្រើពាក្យ «អន្តរាគមន៍» ជាជាងប្រើពាក្យ «ឈ្លានពាន» ឬ«រំដោះ» ។ ប្រទេសវៀតណាមដឹងពីស្ថានភាពរបស់ខ្មែរ ហើយគ្មានប្រទេសដទៃទៀតដែលអាចចូលមកជួយប្រទេសកម្ពុជាបាននៅពេលនោះទេ ដូច្នេះយើងអាចនិយាយថា វៀតណាមមានបំណងចូលមករំដោះកម្ពុជា ។ យ៉ាងណាមិញ វៀតណាមបានបន្តនៅក្នុងប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៨៩ ដែលជាឆ្នាំបញ្ចប់សង្គ្រាមត្រជាក់ ទើបវៀតណាមដកទ័ពចេញពីទឹកដីកម្ពុជា ។ ការដាក់ទ័ពនៅប្រទេសកម្ពុជារយៈពេលមួយទសវត្សរ៍នេះគឺដើម្បីទប់ស្កាត់ការឡើងកាន់អំណាចម្តងទៀតពីសំណាក់ខ្មែរក្រហមដែលនៅឈរជើងក្នុងព្រៃ ។

## កម្មវិធីពេលរសៀល

នៅពេលរសៀលនេះ សិក្ខាកាមទាំងអស់មានឱកាសក្នុងការស្តាប់ និងនិយាយជាមួយ ហ៊ឹម ហ៊ុយ ដែលជាអតីតឆ្មាំគុកនៃមន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ ត្រូវបានកេណ្ឌឲ្យចូលធ្វើទ័ពខ្មែរក្រហមនៅដើមឆ្នាំ១៩៧៣ ហើយទៅប្រយុទ្ធតាមផ្លូវជាតិនៅតាមបណ្តោយទន្លេមេគង្គរហូតដល់សង្គ្រាមបញ្ចប់នៅក្នុងឆ្នាំ១៩៧៥ ។ បន្ទាប់មក ក្រោយពីចំណាយពេលធ្វើស្រែនៅតាខ្មៅមួយរយៈរួចមក ហ៊ឹម ហ៊ុយ ក៏ត្រូវបានថ្នាក់លើហៅមកឲ្យធ្វើការខាងកងទ័ពជើងទឹក តែជាក់ស្តែងត្រូវបានដាក់ឲ្យធ្វើការនៅមន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ មានតួនាទីចាំទទួលអ្នកទោសនៅខាងក្រៅបរិវេណ ហើយដឹកជញ្ជូនអ្នកទោសដែលត្រូវបានសួរចម្លើយរួចទៅជើងឯកដើម្បីសម្លាប់នៅទីនោះ ។ បន្ទាប់ពីខ្មែរក្រហមត្រូវបានផ្តួលរំលំ ហ៊ឹម ហ៊ុយ ក៏បានត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ ហើយចាប់ផ្តើមកសាងជីវិតថ្មី ។ ប៉ុន្តែប្អូនប្រុសរបស់ ហ៊ឹម ហ៊ុយ បានស្លាប់ដោយសាររបបនោះដែរ ។

ទោះបីជាបានរៀបរាប់ពីសកម្មភាពរបស់ខ្លួនដោយខ្លីៗយ៉ាងនេះក៏ដោយ ក៏គាត់ទទួលបានការចាប់អារម្មណ៍ពីសំណាក់សិក្ខាកាមដែលជាលោកគ្រូ-អ្នកគ្រូទាំងអស់ដែរ ។ មានសិក្ខាកាមម្នាក់បានសួរទៅ ហ៊ឹម ហ៊ុយ ថាតើគាត់មានអារម្មណ៍យ៉ាងដូចម្តេចក្នុងការ



លោក ហ៊ឹម ហ៊ុយ និយាយទៅកាន់សាស្ត្រាចារ្យ

ធ្វើការងារនៅមន្ទីរស-២១នោះ ដោយដឹងថាមនុស្សដែលត្រូវបានចាប់ចូលមកឃុំឃាំងនៅទីនោះត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់ចោលបែបនេះ? ហ៊ឹម ហ៊ុយ បានឆ្លើយតបថា ដូចដែលគាត់បានផ្តល់សក្ខីកម្មនៅឯសាលាក្តីខ្មែរក្រហម និងមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ គាត់នៅក្រោមបញ្ជារបស់ថ្នាក់លើ ហើយត្រូវបានបង្ខំឲ្យធ្វើការងារនេះ ។

ម្យ៉ាងវិញទៀត ការងាររបស់គាត់គឺត្រឹមតែជាអ្នកដឹកជញ្ជូនអ្នកទោសពីកន្លែងមួយទៅកន្លែងមួយទៀតតែប៉ុណ្ណោះ មិនមែននៅចាំសម្លាប់អ្នកទោសនោះទេ ។ ប៉ុន្តែកាលពីជំនាន់នោះ ទ័ពចាំបាច់ត្រូវតែដាច់ខាត និងស្មោះត្រង់នឹងអង្គការ ។ ប្រសិនជាថ្នាក់លើបញ្ជាឲ្យធ្វើអ្វីមួយនោះ បញ្ជានោះត្រូវតែធ្វើតាមដាច់ខាត មិនអាចខកខានបាននោះទេ ពីព្រោះថាបើមិនដូច្នោះទេ សូម្បីតែខ្លួនគាត់ក៏ត្រូវបានសម្លាប់ចោលដែរ ។ ផ្ទុយទៅនឹងអ្វីដែលខ្មែរក្រហមតែងតែអះអាង អ្នកទោសដែលត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកកាន់មន្ទីរ ស-២១ មិនមែនសុទ្ធតែជាជនក្បត់ឬក៏ជាគិញសម្ងាត់ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ អ៊ីនោះទេ។ ហ៊ឹម ហ៊ុយ បាននិយាយថា ឌុច មើលទៅហាក់បីដូចជាកំពុងបំពេញបេសកកម្មរបស់ខ្លួនអ៊ីចឹង ព្រោះ ឌុច ផ្ទាល់បាននិយាយនៅក្នុងអង្គប្រជុំមួយធ្វើឡើងនៅទួលស្លែង កាលពីឆ្នាំ១៩៧៧ថា «សម្លាប់ទាំងអស់ទុកតែបីលាននាក់» ប៉ុណ្ណោះ ។ មានសិក្ខាកាមខ្លះទៀតមានមន្ទិលសង្ស័យទៅលើភាពស្មោះត្រង់ និងគោលបំណងនៃចម្លើយរបស់ ហ៊ឹម ហ៊ុយ ដោយសួរសំណួរមួយទៀតថា តើកាលដែលគាត់ចេញមកផ្តល់សក្ខីកម្មបែបនេះគឺដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជាបង្គាប់ឲ្យធ្វើឬខ្លួនមានបំណងនិយាយបែបនេះតែម្តង? ហ៊ឹម ហ៊ុយ បានបញ្ជាក់ទៅវិញថា គាត់បាននិយាយពីរឿងរ៉ាវនិងបទពិសោធន៍របស់គាត់ប្រាប់មនុស្សជាច្រើនរួមមានទាំងអ្នកកាសែតទៀតផង ដោយសារតែគាត់ធ្វើតាមបញ្ជាពីគេតែប៉ុណ្ណោះ ។ នៅក្នុងឆ្នាំ១៩៧៧ គាត់បានស្នើទៅ សុន សេន ឲ្យប្តូរគាត់ទៅធ្វើជាទ័ពវិញដើម្បីប្រយុទ្ធជាមួយវៀតណាម ។ ធ្វើដូចនេះទោះបីជាយ៉ាងណាគាត់ក៏អាចស្លាប់ទៅបានស្រួលដោយមិនចាំបាច់នាំទុក្ខដល់ឪពុកម្តាយនោះទេ ព្រោះថាការដែលធ្វើការនៅក្នុងគុកប្រាកដជាមិនអាចគេចផុតពីសេចក្តីស្លាប់បានឡើយ ។ នៅពេលដែលត្រូវបានចោទសួរថាតើគាត់ត្រូវបានអ្នកភូមិរើសអើងពីប្រវត្តិរបស់គាត់ដែរឬទេ? ហ៊ឹម ហ៊ុយ បានឆ្លើយថា អ្នកភូមិនៅក្នុងសហគមន៍របស់គាត់ធ្វើចំពោះគាត់ដូចគ្នាទៅនឹងអ្នកភូមិដទៃទៀតដែរ ដោយសារតែអ្នកភូមិដឹងថាគាត់ធ្វើតាមបញ្ជារបស់គេទេ ហើយទាំងនេះគឺពិតជាកើតមានមែននៅក្នុងសម័យនោះ ។ បើពិនិត្យមើលទៅគាត់ហាក់ដូចជាមានបំណងពិតប្រាកក្នុងការនិយាយរៀបរាប់ពីការពិតក្នុងនាមជាសាក្សីរស់ម្នាក់ក្នុងសម័យខ្មែរក្រហម ។


បណ្ឌិត ចន ឆរឆីអារី សាស្ត្រាចារ្យ ដេវីត ឆេនដល័រ

ចំពោះកម្មវិធីបន្ទាប់ លោក ចន ឆរឆីអារី បានផ្តល់បទបង្ហាញអំពីសៀវភៅរបស់គាត់ដែលមានចំណងជើងថា ៖ «ការវិនិច្ឆ័យទោស ៖ ដំណើរការកាត់ទោសរបស់តុលាការខ្មែរក្រហម» ។ ទាក់ទងទៅនឹងការស្រាវជ្រាវរបស់គាត់ក៏ដូចជាមានលក្ខណៈខុសគ្នាបន្តិចទៅនឹងបទបង្ហាញមុន លោក ឆរឆីអារី បានផ្តោតសំខាន់ទៅលើយុត្តិធម៌ក្រោយអំពើប្រល័យពូជសាសន៍និងអ្វីដែលកម្ពុជាបានធ្វើរួចមកហើយតាំងពីឆ្នាំ១៩៧៩រហូតមកដើម្បីធ្វើការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហមដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ ។ នៅឆ្នាំ១៩៧៩ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតតុលាការប្រជាជនបដិវត្តន៍ដែលធ្វើឡើងនៅសាលចតុមុខ ។ នីតិវិធីរបស់តុលាការនេះពុំមានទម្ងន់ខ្លាំងនោះទេ ដោយសារតែវាមានកំហុសឆ្គងផ្នែកនីតិវិធី (កង្វះខាតនៃការការពារសិទ្ធិរបស់

ចុងចោទ) ។ យោងទៅតាមលោក ឆរឆឺអារី សាលាក្តីខ្មែរក្រហមសព្វថ្ងៃនេះគឺគ្រាន់តែជាកិច្ចខំប្រឹងប្រែងមួយដើម្បីកែតម្រូវនូវចំណុចខ្វះខាតរបស់តុលាការប្រជាជនបដិវត្តន៍តែប៉ុណ្ណោះ ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៨២ដល់១៩៨៣ រដ្ឋាភិបាលកម្ពុជាមានបំណងបង្កើតនូវគណៈកម្មការស្វែងរកការពិតមួយដែលមានទម្រង់ជាញត្តិរណសិរ្ស ។ ប៉ុន្តែបញ្ហាគឺថា ទម្រង់នៃញត្តិនេះត្រូវបានរៀបចំឡើងចេញពីមូលហេតុនយោបាយដើម្បីឲ្យសាធារណរដ្ឋប្រជាមានិតកម្ពុជាទទួលបានអាសនៈនៅអង្គការសហប្រជាជាតិ ។ សរុបសេចក្តីមក យើងមានការពិបាកក្នុងការនាំមកនូវយុត្តិធម៌ដល់ប្រជាជនកម្ពុជានៅក្រោយសង្គ្រាមនោះ ។ អស់រយៈពេលជាយូរមកហើយ យុត្តិធម៌មិនត្រូវបានលើកឡើងឲ្យច្បាស់លាស់នោះទេ ដោយសារតែភាគីអ្នកចរចាជឿជាក់ថា ការធ្វើបែបនេះនឹងអាចធ្វើឲ្យខ្មែរក្រហមភ័យខ្លាចនិងរត់ចូលព្រៃដើម្បីតស៊ូបន្តទៀត ។

លោក ចន ឆរឆឺអារី បានបន្តអះអាងថា សាលាក្តីនេះនឹងមិនអាចធ្វើអ្វីៗបានទាំងអស់នោះទេ ក្នុងការដោះស្រាយជាមួយអតីតកាលនោះ តែផ្ទុយទៅវិញ កម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នឹងមានតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើឲ្យកេរដំណែលនៃញត្តិរណសិរ្សនោះកាន់តែប្រសើរឡើង ។ សាលាក្តីនេះប្រឈមមុខនឹងឧបសគ្គនិងចំណុចខ្វះខាតជាច្រើន ហើយយើងត្រូវតែចងចាំថាយុត្តិធម៌មួយដ៏ពេញលេញគឺមិនអាចសម្រេចទៅបានឡើយ ។ ប៉ុន្តែការពិតដែលថាមានការទទួលស្គាល់ជាផ្លូវការនូវអ្វីដែលបានកើតឡើងថាជាទង្វើខុសឆ្គងនោះគឺអាចធ្វើឲ្យ «សង្គមមួយដែលទទួលរងនូវនិទ្ទណ្ឌភាពរបស់ជនល្មើសជាយូរមកហើយនេះ» មានសេចក្តីអង់អាចឡើងវិញ ។

នៅក្នុងវេទិកាសួរសំណួរ សិក្ខាកាមម្នាក់បានសួរសំណួរយ៉ាងស៊ីជម្រៅមួយថា តើការផ្សះផ្សាជាតិគួរតែធ្វើឡើងទោះបីជាពុំមានយុត្តិធម៌ក៏ដោយឬក៏មានតែយុត្តិធម៌ហើយពុំចាំបាច់មានការផ្សះផ្សាជាតិទេ? លោក ចន ឆរឆឺអារី បានឆ្លើយតបថា ការថ្លឹងថ្លែងឲ្យស្មើគ្នារវាងយុត្តិធម៌និងការផ្សះផ្សាជាតិគឺជារឿងមួយដែលធ្វើតាមលំដាប់នៃស្ថានភាពជាមូលដ្ឋានតែប៉ុណ្ណោះ ។ នៅក្នុងបរិបទសព្វថ្ងៃនេះគឺអាចធ្វើឲ្យមាននូវនីតិវិធីផ្លូវច្បាប់ដែលអនុញ្ញាតឲ្យមានការផ្សះផ្សាជាតិ ។ ទោះបីជាសាធារណជនមិនមានភាពរីករាយទៅនឹងសាលក្រម ឌុច ក៏ដោយ ក៏ការវិនិច្ឆ័យទោសនេះបានបង្កើតនូវការជឿទុកចិត្តមកលើតុលាការដែរ ។ ជាពិសេសទៅទៀតដោយគោរពទៅតាមគោលការណ៍នៃការការពារសិទ្ធិរបស់ចុងចោទ សាលាក្តីនេះធ្វើដាក់ខ្មែរក្រហមនូវអ្វីដែលផ្ទុយស្រឡះពីទង្វើរបស់ខ្មែរក្រហម ហើយជួយបង្កើតនូវគំរូមួយសម្រាប់ប្រព័ន្ធផ្លូវច្បាប់របស់ប្រទេសកម្ពុជា ។ ប៉ុន្តែយើងត្រូវចងចាំថា មានតែមេដឹកនាំខ្មែរក្រហមមួយចំនួនតូចតែប៉ុណ្ណោះដែលត្រូវយកមកវិនិច្ឆ័យទោស និងដាក់ឲ្យទទួលខុសត្រូវតាមផ្លូវច្បាប់ ។ ដូចនេះ ការអប់រំពីអំពើប្រល័យពូជសាសន៍គឺមានសារសំខាន់ណាស់ដោយសារតែវាផ្តល់នូវទម្រង់មួយទៀតនៃការទទួលខុសត្រូវនិងសាធារណជនត្រូវប្រឈមទៅនឹងការពិតនិងយុត្តិធម៌ ។

ជាកិច្ចបន្ត លោកបណ្ឌិតសភាចារ្យ អ៊ីវ ច័ន ប្រធានវិទ្យាស្ថានភាសាជាតិបានផ្តល់នូវបទបង្ហាញពិស្តារមួយក្រោមប្រធានបទដែលមានចំណងជើងថា : «ប្រទេសកម្ពុជារវាងឆ្នាំ១៩៧៥ ដល់១៩៧៩» ។ ជាកិច្ចចាប់ផ្តើម លោកបណ្ឌិតបានចោទជាសំណួរមួយឡើងថា «តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? តើប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យទទួលយករបបថ្មីនេះឬក៏ប្រជាជនខ្លួនឯងមានបំណងចង់បានរបបនេះដែរកាលពីដំបូង?» តាមយោបល់របស់លោកបណ្ឌិត ជាការ «ពិបាកដែរក្នុងការឆ្លើយ» ដោយសារតែមានកត្តាជាច្រើនដែលត្រូវពិចារណា ។ បទបង្ហាញរបស់លោកបណ្ឌិតនឹងធ្វើការពិភាក្សានិងផ្តោតសំខាន់ទៅលើគោលនយោបាយខាងក្នុងនិងខាងក្រៅដែលទាក់ទងនិងប៉ះពាល់មកលើកម្ពុជាប្រជាធិបតេយ្យ ។

បើយើងធ្វើការសិក្សាអំពីបរិបទនៅក្នុងប្រទេសកម្ពុជា មើលទៅហាក់បីដូចជាកង់ប្រវត្តិសាស្ត្រវិលជុំដដែលៗតាមរយៈព្រឹត្តិការណ៍ស្រដៀងគ្នា : បែកហើយរួមគ្នាវិញ បែកហើយរួមគ្នាវិញ ។ ប៉ុន្តែចំពោះការយល់ឃើញរបស់លោកបណ្ឌិតវិញគឺមិនដូចគ្នានោះទេ ។ អំពើប្រល័យពូជសាសន៍ដែលកើតមាននៅប្រទេសកម្ពុជាគឺជាអតីតកាលមួយដ៏ជូរចត់បំផុតសម្រាប់ប្រវត្តិសាស្ត្រជាតិខ្មែរ ប៉ុន្តែជាមួយគ្នានេះដែរ ចំពោះប្រទេសតូចតាចនេះគឺជាអ្វីដែលមិនអាចចៀសវាងបាន ជាពិសេសឲ្យចេញផុតពីអន្ទាក់នៃប្រទេសមហាអំណាចផ្សេងៗ ។ លោកបណ្ឌិតក៏បាន

លើកឡើងពីបញ្ហាដូចគ្នាដែលសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ និង លោកបណ្ឌិតសភាចារ្យ រស់ ច័ន្ត្រាបុត្រ ដែលនិយាយថា ប្រសិន បើគ្មានសង្គ្រាមត្រជាក់នោះទេ ខ្មែរក្រហមក៏មិនអាចឡើងកាន់ អំណាចដងដែរ ។ ដើម្បីធ្វើការការពារបូរណភាពទឹកដីរបស់ខ្លួន កម្ពុជាបានព្យាយាមរក្សានូវអព្យាក្រឹតភាពរហូតដល់ចប់សង្គ្រាម ។ ប៉ុន្តែការធ្វើដូច្នេះគឺមិនមែនជារឿងងាយស្រួលមួយនោះទេ ហើយវាបានផ្តល់ជាបញ្ហាដល់មេដឹកនាំកម្ពុជាដែលជាចុងក្រោយ បានធ្វើឲ្យប្រទេសជាតិធ្លាក់ចូលទៅក្នុងស្ថានភាពដ៏អាក្រក់មួយ ។

បើយោងទៅតាមលោកបណ្ឌិតសភាចារ្យ អ៊ីវ ច័ន្ទ យើងមិនអាចស្តីបន្ទោសឲ្យអ្នកដទៃតែម្យ៉ាងនោះទេ ។ ចក្ខុវិស័យ របស់ ប៉ុល ពត ដែលចង់បានសង្គមកម្ពុជាថ្មីស្រឡាងមួយនោះគឺ ជាគំនិតស្រមើស្រមៃតែប៉ុណ្ណោះ ឧទាហរណ៍ដូចជាកាលដែល ប៉ុល ពត ចង់លុបបំបាត់វណ្ណៈសង្គម និងកម្មសិទ្ធិបុគ្គលដើម្បី ស្វែងរកយុត្តិធម៌ឲ្យអ្នកក្រីក្រអ៊ីចឹងគឺជារឿងមួយដែលមិនអាចទៅ រួច ។ ប៉ុល ពត មានទិសដៅចង់បំផ្លិចបំផ្លាញសាសនាដោយសារ តែសាសនានឹងនាំឲ្យមានភាពខុសគ្នារវាងអ្នកប្រណិប័តន៍និងមិន ប្រណិប័តន៍តាមសាសនា នោះហើយដោយសារតែកាលពីជំនាន់ នោះភាគច្រើនចំណេះដឹងគឺទទួលបានពីវត្តអារាមដែលមានព្រះ សង្ឃជាអ្នកប្រៀនប្រដៅ ។ ប៉ុល ពត ជឿជាក់ថា មានតែផ្តល់ សិទ្ធិឲ្យអ្នកក្រស្មើនឹងអ្នកមានតែប៉ុណ្ណោះ ទើបអាចធ្វើឲ្យប្រទេស កម្ពុជាមានភាពរុងរឿងបាន ។ ផ្ទុយទៅវិញ ប៉ុល ពត បានបង្ខំឲ្យ ប្រជាជនទាំងអស់ធ្វើការជាសមូហភាព ដូចជាការធ្វើស្រែចម្ការ ដាំដំណាំ លើកទំនប់ និងជីកប្រឡាយ ។ ទាំងនេះមើលទៅដូចជា ជោគជ័យ ប៉ុន្តែជាក់ស្តែងវាប្រែក្លាយទៅជាវិនាសកម្មទៅវិញ ។ ប៉ុល ពត មិនមានមន្ទិលសង្ស័យទៅនឹងគោលនយោបាយរបស់ ខ្លួននោះទេ ប៉ុន្តែបែរជាបន្ទោសថា ដោយសារមនុស្សនៅជុំវិញខ្លួន ឯងមិនមានសមត្ថភាពគ្រប់គ្រាន់ ហើយមានបំណងធ្វើវិទ្ធង្សនា ប្រឆាំងនឹងការងារបដិវត្តន៍ខ្លួនទៅវិញ ។ ការស្រមើស្រមៃចង់បាន ភាពល្អឥតខ្ចោះរបស់ ប៉ុល ពត មិនបាននាំមកនូវអ្វីជាជាក់ស្តែង ដល់ប្រទេសកម្ពុជាក្រៅពីសោកនាដកម្មដ៏ឃោរឃៅនោះទេ ។

នៅក្នុងវេទិកាសំណួរចម្លើយ លោកគ្រូ-អ្នកគ្រូបានសួរ សំណួរទាក់ទងទៅនឹងវិធីសាស្ត្រដែលខ្មែរក្រហមប្រើប្រាស់ក្នុងការ កំណត់ប្រភេទមនុស្សដែលត្រូវ «កម្ទេច» ក៏ដូចជាពាក្យពេចន៍ដែល ខ្មែរក្រហមប្រើប្រាស់ ដែលពាក្យខ្លះពុំមានអត្ថន័យដូចឥឡូវនេះទេ ។ លោកបណ្ឌិតបានពន្យល់ថា ខ្មែរក្រហមធ្វើការប្រមែប្រមូលប្រវត្តិ រូប និងស្វែងរកអតីតមន្ត្រីរាជការ ហើយខ្មែរក្រហមក៏ប្រមូលអ្នក ចេះដឹងដែលមានចំណេះវិជ្ជាច្រើនពេក ហើយមានមតិប្រឆាំងនឹង ផែនការបដិវត្តន៍របស់ខ្លួន ។

## សកម្មភាពថ្ងៃទីបី

## សកម្មភាពពេលព្រឹក

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាន ផ្តល់ជាបទអត្ថាធិប្បាយស្តីពីប្រភេទឯកសារដែលមាននៅឯ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលសាស្ត្រាចារ្យសកលវិទ្យាល័យអាច ទទួលបានសម្រាប់កិច្ចការស្រាវជ្រាវ និងការបង្រៀន ។ លោក ឆាំង យុ បានជំរុញឲ្យសាស្ត្រាចារ្យទាំងអស់ប្រើប្រាស់ឯកសារដែល មានសម្រាប់ការបង្រៀន ហើយក៏បានគូសបញ្ជាក់ពីវិធីសាស្ត្រ មួយចំនួនសម្រាប់ការប្រើប្រាស់ឯកសារជាឯកសារយោងដើម្បី លើកកម្ពស់គុណភាពបង្រៀន ។ បន្ទាប់មកទៀត លោក ឆាំង យុ ក៏បានរៀបរាប់ពីប្រភេទឯកសារទាំងប្រាំប្រភេទដែលមាន នៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទីមួយ មជ្ឈមណ្ឌលឯកសារ កម្ពុជាមានប្រភេទឯកសារជាក្រដាសដូចជាចម្លើយសារភាពរបាយ ការណ៍របស់មេដឹកនាំខ្មែរក្រហមនិងផែនទីជាដើម ។ ទីពីរ មជ្ឈ មណ្ឌលឯកសារកម្ពុជាមានប្រភេទឯកសារទាក់ទងនឹងព័ត៌មានស្តីពី បូជនីយដ្ឋានគម្ពល់លលាដ៍ក្បាល និងឆ្អឹងជនរងគ្រោះ និងឯកសារ ស្រាវជ្រាវស្តីពីវិធីសាស្ត្រវិភាគលើលលាដ៍ក្បាល និងឆ្អឹងជនរង គ្រោះដើម្បីដឹងពីមូលហេតុនៃការស្លាប់ អាយុ ឬភេទរបស់ជនរង គ្រោះ ។ ទីបី មជ្ឈមណ្ឌលឯកសារកម្ពុជាមានរក្សាទុកនូវឯកសារ ដើមនៃបទសម្ភាសន៍ជាមួយជនដៃដល់និងជនរងគ្រោះដែលអាច យកមកប្រើប្រាស់សម្រាប់ការស្រាវជ្រាវ និងជាភស្តុតាងសម្រាប់ ដំណើរការស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមបាន ។ ទីបួន មជ្ឈមណ្ឌលឯកសារកម្ពុជាមានរក្សាទុកនូវរូបថតដើមហើយដែល កម្រមានដែលអាចយកទៅប្រើប្រាស់ដើម្បីស្វែងរកជនរងគ្រោះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនិងអតីតកម្មាភិបាលខ្មែរ ក្រហមដើម្បីជួបសម្ភាសន៍ជាមួយនឹងអ្នកទាំងនោះ ។ ទីប្រាំ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពយន្តឯកសារដែលភាគច្រើនត្រូវបានផលិតដោយកងយោធាវៀតណាមដែលសាស្ត្រាចារ្យទាំងអស់អាចយកមកប្រើប្រាស់សម្រាប់ការស្រាវជ្រាវ ។ លោកនាយកបានរំឭកដល់សាស្ត្រាចារ្យទាំងអស់ថា បទសម្ភាសន៍និងចម្លើយសារភាពខ្លះមានផ្ទុកនូវព័ត៌មានមិនពិតប៉ុន្តែក្នុងនោះក៏មានបទសម្ភាសន៍និងចម្លើយសារភាពជាច្រើនដែលមានផ្ទុកនូវព័ត៌មានពិតដែរ ។ ដូច្នេះលោកនាយកបានជំរុញឲ្យសាស្ត្រាចារ្យទាំងអស់ធ្វើការស្រាវជ្រាវឲ្យបានទូលំទូលាយ ប្រើប្រាស់ឯកសារឲ្យបានច្រើនប្រភេទ និងវិភាគលើទិដ្ឋភាពជាក់ស្តែងជាច្រើនលើប្រភេទឯកសារនោះដើម្បីចៀសវាងការសន្និដ្ឋានខុសនិងលម្អៀង ។ លោកក៏បានណែនាំឲ្យសាស្ត្រាចារ្យទាំងអស់ធ្វើការស្រាវជ្រាវដោយខ្លួនឯងជាជាងសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយរកឯកសារហើយផ្ញើទៅឲ្យ ។ លោកនាយកក៏បានជំរុញឲ្យសាស្ត្រាចារ្យទាំងអស់បញ្ជូនសិស្សរបស់ខ្លួនមកធ្វើការស្រាវជ្រាវនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជាហើយមជ្ឈមណ្ឌលឯកសារកម្ពុជានឹងជួយគាំទ្រការស្រាវជ្រាវរបស់សិស្សនិស្សិតយ៉ាងពេញទំហឹង ។

ជាចុងបញ្ចប់ លោកនាយក ឆាំង យុ បានចែកជូនឯកសារមួយច្បាប់ដែលរៀបរាប់ពីធនធានដែលមាននៅឯមជ្ឈមណ្ឌលឯកសារកម្ពុជាដល់សាស្ត្រាចារ្យទាំងអស់ ។ សាស្ត្រាចារ្យទាំងអស់បានត្រងត្រាប់ស្តាប់យ៉ាងយកចិត្តទុកដាក់បំផុតលើបទអត្ថាធិប្បាយស្តីពីធនធានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក សេង ដីណូ សាស្ត្រាចារ្យផ្នែកវប្បធម៌មកពីវិទ្យាស្ថានប្រាយហូប ដែលជាអ្នកកើតទាន់របបខ្មែរក្រហមបាននិយាយថាគាត់សង្ឃឹមថានឹងទទួលបានឯកសារផ្សេងៗដើម្បីប្រើប្រាស់សម្រាប់ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមទៅឲ្យនិស្សិតរបស់គាត់ ពីព្រោះរាល់ពេលដែលគាត់បានចែករំលែកបទពិសោធន៍ផ្សេងៗ ដូចជាស្តីពីស្ថានភាពរស់នៅជំនាន់ខ្មែរក្រហមទៅកាន់និស្សិតរបស់គាត់ និស្សិតខ្លះមិនជឿគាត់ឡើយ ។ ចំណែកឯលោក អាង សុភាព ដែលជាសាស្ត្រាចារ្យអក្សរសាស្ត្រអង់គ្លេសនៃវិទ្យាស្ថានខ្មែរជំនាន់ថ្មីក៏បានបង្ហាញនូវទស្សនៈស្រដៀងគ្នានេះដែរ ។ សាស្ត្រាចារ្យរូបនេះសង្ឃឹមថានឹងប្រើប្រាស់ឯកសារទាំងអស់នោះសម្រាប់ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ពីព្រោះថានិស្សិតខ្លះមិនជឿលើអ្វីដែលលោកបានចែករំលែកកន្លងមកនោះទេ ។ បន្ថែមលើនេះ លោក វង់ សុធារ៉ា សាស្ត្រាចារ្យប្រវត្តិសាស្ត្ររបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញបាននិយាយថា សាកលវិទ្យាល័យរបស់លោកខ្វះខាតធនធានថវិកាសម្រាប់ការស្រាវជ្រាវ ដូច្នេះ លោកពឹងផ្អែកលើមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងស្រុងសម្រាប់ការស្រាវជ្រាវ ។ ដូច្នេះវាគូសបញ្ជាក់ឲ្យឃើញថាឯកសារដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាបម្រើជាប្រយោជន៍យ៉ាងច្រើនដល់សាស្ត្រាចារ្យទាំងអស់ ។

បន្ទាប់មកទៀត បណ្ឌិត ជា ផល្លា បានផ្តល់ជាសេចក្តីណែនាំពីវិធីសាស្ត្របង្រៀនចំនួនពីរ ។ បណ្ឌិត ជា ផល្លា បានសុំឲ្យសាស្ត្រាចារ្យទាំងអស់បើកសៀវភៅណែនាំគ្រូដែលសាស្ត្រាចារ្យទាំងអស់ទទួលបានពីមុន ហើយក៏បានបញ្ជាក់ថាសិស្សក៏អាចប្រើប្រាស់សៀវភៅនេះដែរ ។ បណ្ឌិត ជា ផល្លា បានគូសបញ្ជាក់ថាសៀវភៅណែនាំគ្រូបង្រៀននេះមានផ្ទុកនូវវិធីសាស្ត្របង្រៀនជាច្រើនដែលសាស្ត្រាចារ្យទាំងអស់អាចជ្រើសរើសយកទៅប្រើប្រាស់សម្រាប់ជាប្រយោជន៍ដល់ការបង្រៀនរបស់ខ្លួនបាន ។ បន្ទាប់មកទៀតបានសួរទៅកាន់សាស្ត្រាចារ្យទាំងអស់ពីវិធីសាស្ត្របង្រៀនទូទៅដែលសាស្ត្រាចារ្យទាំងអស់បានកំពុងតែប្រើប្រាស់នៅក្នុងថ្នាក់រៀនរបស់ខ្លួន ។ សាស្ត្រចារ្យជាច្រើនបានរៀបរាប់ពីវិធីសាស្ត្របង្រៀនរបស់ខ្លួនដែលក្នុងនោះរួមមានវិធីសាស្ត្របង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលដែលក្នុងវិធីសាស្ត្រនេះសិស្សដើរតួយ៉ាងសកម្មនៅក្នុងការសិក្សា និងវិធីសាស្ត្របង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌលដែលក្នុងវិធីសាស្ត្រនេះសាស្ត្រាចារ្យធ្វើបទខទ្ទេសហើយសួរសំណួរទៅកាន់សិស្ស ។ ក្រៅពីនេះមានវិធីសាស្ត្របង្រៀនផ្សេងទៀតដូចជាការពិភាក្សាជាក្រុម បទខទ្ទេសរបស់សាស្ត្រាចារ្យនិងការអនុវត្តរបស់សិស្សការធ្វើដំណើរទស្សនកិច្ចនិងការដើរតួជាដើម ។ សាស្ត្រាចារ្យម្នាក់បាននិយាយថា លោកបានដាក់សំណួរទៅកាន់សិស្សមុនពេលនិងក្រោយពេលដែលលោកគ្រូចាប់ផ្តើមនិងបញ្ចប់បទខទ្ទេសដើម្បីស្ទាបស្ទង់មើលចំណេះដឹងរបស់សិស្សមុននិងក្រោយពេលស្តាប់បទខទ្ទេសរបស់គាត់ ។ ក្រោយពីការចែករំលែកបទពិសោធន៍ពីសំណាក់សាស្ត្រាចារ្យទាំងអស់ទាក់ទងនឹងវិធីសាស្ត្របង្រៀនមក បណ្ឌិត ជា ផល្លា បាននិយាយសង្ខេបឡើង

វិញលើវិធីសាស្ត្របង្រៀនដែលសាស្ត្រាចារ្យទាំងអស់បានលើកឡើងមុននេះហើយបានផ្តល់ជាសេចក្តីណែនាំមួយចំនួនស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀនទាំងអស់នោះ ។ ជាឧទាហរណ៍ នៅពេលដែលលោកស្រីសាស្ត្រាចារ្យផ្នែកបច្ចេកវិទ្យាបាននិយាយថាលោកស្រីបានប្រើប្រាស់វិធីសាស្ត្រធ្វើដំណើរទស្សនកិច្ចដើម្បីបង្រៀនសិស្សនោះ បណ្ឌិត ជា ផល្លា បានណែនាំថាដើម្បីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឲ្យកាន់តែមានប្រសិទ្ធភាព ការធ្វើដំណើរទស្សនកិច្ចទៅវាលពិឃាតឬបូជនីយដ្ឋានផ្សេងៗអាចហុចជាប្រយោជន៍ច្រើនបន្ថែមលើបទខុស ។

បន្ទាប់មកទៀត បណ្ឌិត ជា ផល្លា បានរៀបរាប់ពីខ្លឹមសារបច្ចុប្បន្ននេះវិធីសាស្ត្របង្រៀនត្រូវបានប្តូរពីគ្រូមជ្ឈមណ្ឌលមកជាសិស្សមជ្ឈមណ្ឌលវិញ ។ ចំណែកឯសាស្ត្រាចារ្យម្នាក់ទៀតបានមានមតិថា ការប្រើប្រាស់ខ្សែភាពយន្តនិងចម្រៀងនៅក្នុងការបង្រៀនក៏មានប្រយោជន៍ដែរជាជាងការប្រើតែបទខុសតែមួយមុខ ។ បណ្ឌិត ជា ផល្លា ក៏បានពន្យល់ណែនាំពីវិធីសាស្ត្របង្រៀនមួយចំនួនបន្ថែមទៀតដូចជាការពិភាក្សាជាក្រុមកិច្ចការសហការជាក្រុមប្រៀបធៀប និងការធ្វើបទបង្ហាញដែលសាស្ត្រាចារ្យទាំងអស់អាចយកទៅអនុវត្តនៅក្នុងការបង្រៀនរបស់ខ្លួនបាន ។ ជាមួយគ្នានោះ បណ្ឌិត ជា ផល្លា ក៏បានបកស្រាយយ៉ាងលម្អិតលើវិធីសាស្ត្រនីមួយៗ ។ លំហាត់ប្រៀបធៀបសំដៅទៅលើ


ក្រុមពិភាក្សា


ការតែងកំណាព្យ

របស់សៀវភៅណែនាំគ្រូបង្រៀននេះ ។ ខុសពីកម្មវិធីសិក្សាដែលមានផ្ទុកនូវលំអានមេរៀនស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍ សៀវភៅណែនាំគ្រូបង្រៀននេះមានផ្ទុកនូវវិធីសាស្ត្រជាច្រើនដែលមានប្រយោជន៍ ។ បណ្ឌិត ជា ផល្លា បានប្រើស្លាយផាវវើផញដើម្បីអត្ថាធិប្បាយពីមាតិការបស់សៀវភៅណែនាំគ្រូបង្រៀននេះដែលនៅក្នុងផ្ទាំងស្លាយនោះរួមមាន ៈ គោលដៅ និងលទ្ធផលវិធីសាស្ត្របង្រៀនសំណួរលំនាំកិច្ចការរបស់សិស្ស ។ សាស្ត្រាចារ្យម្នាក់បានគូសបញ្ជាក់ថាវិធីសាស្ត្រដែលត្រូវបានរៀបរាប់ខាងលើនេះពិតជាមានប្រយោជន៍សម្រាប់ការបង្រៀនពីព្រោះនាពេលការបែងចែកសិស្សម្នាក់ៗឲ្យអានអត្ថបទខុសៗគ្នា ហើយក្រោយមកចាត់សិស្សពីរនាក់ដែលអានអត្ថបទខុសគ្នានោះឲ្យផ្លាស់ប្តូរព័ត៌មានជាមួយគ្នាទៅវិញទៅមក ។ ការធ្វើបទបង្ហាញគឺផ្តោតសំខាន់ទៅលើការធ្វើបទបង្ហាញរបស់សិស្សលើកិច្ចការរៀនសូត្រនិងស្រាវជ្រាវដែលសិស្សបានយល់ដឹង ហើយនៅពេលធ្វើបទបង្ហាញសិស្សត្រូវតែយកចិត្តទុកដាក់លើការរៀបចំព័ត៌មានចំណេះដឹង រូបភាពដំណាក់កាលនៃការធ្វើបទបង្ហាញការទាក់ទាញចំណាប់អារម្មណ៍ពីអ្នកស្តាប់និងសំឡេង ។ ចំណែកឯកិច្ចការសហការជាក្រុមគឺសំដៅលើការដែលសិស្សបំពេញកិច្ចការជាក្រុម បែងចែកការទទួលខុស

ត្រូវរៀងៗខ្លួន ហើយដើរតួយ៉ាងសកម្មក្នុងការសិក្សារបស់ខ្លួន ។ កិច្ចការសហការជាក្រុមបែងចែកជាតួនាទីប្រាំយ៉ាងខុសៗគ្នាដូចជា ៖ អ្នកសម្របសម្រួល អ្នកកត់ត្រា អ្នកផ្ទៀងផ្ទាត់ពេលវេលា អ្នកលើកទឹកចិត្ត និងអ្នករាយការណ៍ ។

បន្ទាប់ពីបានឈប់សម្រាកអាហារសម្រន់មក សាស្ត្រាចារ្យទាំងអស់ត្រូវបានបែងចែកជាក្រុមសម្រាប់ការអនុវត្តវិធីសាស្ត្រកិច្ចការសហការជាក្រុម ។ ដំបូងឡើយ សាស្ត្រាចារ្យទាំងអស់ត្រូវបានបែងចែកជាបួនក្រុមធំៗតាមពណ៌នៃកាតសម្គាល់ខ្លួន ។ បន្ទាប់មកទៀត សាស្ត្រាចារ្យទាំងអស់នៅក្នុងក្រុមនីមួយៗត្រូវបានដាក់លេខសម្គាល់ផ្សេងៗគ្នា ហើយត្រូវបានបំបែកឲ្យចូលជាក្រុម





សាស្ត្រាចារ្យ ចាន់ ភក្តី និងសាស្ត្រាចារ្យ ឡោ សាន កំពុងធ្វើបទបង្ហាញពីកំណាព្យ

តូចៗទៀតដែលក្នុងមួយក្រុមមានសមាជិកប្រាំនាក់ ។ សមាជិកនៅក្នុងក្រុមតូចៗនេះត្រូវបានណែនាំឲ្យបែងចែកតួនាទីនិងការទទួលខុសត្រូវខុសៗគ្នាដើម្បីតែងជាកំណាព្យមួយដែលឋិតនៅក្រោមចំណងជើងនៃប្រធានបទការផ្សះផ្សា និងគូររូបភាពអមជាមួយនឹងកំណាព្យនោះ ហើយបន្ទាប់មកធ្វើការបកស្រាយអត្ថន័យកំណាព្យនោះទៅកាន់ក្រុមពណ៌ធំៗដទៃទៀត ។ ក្រុមតូចៗទាំងអស់នៃក្រុមពណ៌ធំមួយបានផ្លាស់ប្តូរកិច្ចការរបស់ខ្លួន ហើយក្រោយមកសម្រេចជ្រើសយកកំណាព្យដែលល្អមួយដើម្បីបកស្រាយទៅកាន់ក្រុមធំៗផ្សេងទៀត ។ ស្របពេលនោះ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយសម្របសម្រួលកិច្ចការរបស់សាស្ត្រាចារ្យទាំងអស់ ។

គួរឲ្យកត់សម្គាល់សាស្ត្រាចារ្យទាំងអស់បានចូលរួមយ៉ាងសកម្មនៅក្នុងការបំពេញកិច្ចការជាក្រុមនេះ ។ ក្រុមតូចៗខ្លះបានសហការគ្នាដើម្បីសរសេរកំណាព្យមួយ ចំណែកឯក្រុមតូចៗផ្សេងទៀតបានសរសេរកំណាព្យរៀងៗខ្លួនមុននឹងផ្លាស់ប្តូរជាមួយនឹងសមាជិកក្រុមផ្សេងទៀត ។ ក្រោយពីក្រុមតូចៗនីមួយៗបានបញ្ចប់ការសរសេរកំណាព្យនិងការគូរគំនូររួចមក សមាជិកនីមួយៗបានចូលជាក្រុមធំដែលមានពណ៌ដូចគ្នាដើម្បីបោះឆ្នោតជ្រើសយកកំណាព្យ និងគំនូរដែលល្អជាងគេ ។ ក្រុមខ្លះបានបញ្ចូលកំណាព្យឬរូបភាពពីរមកធ្វើជាតំណាងឲ្យក្រុមធំរបស់ខ្លួន ។ ក្រុមដែលត្រូវបានជ្រើសរើសត្រូវចម្លងកំណាព្យ និងរូបភាពរបស់ខ្លួនមកដាក់លើផ្ទាំងក្រដាសធំៗសម្រាប់ការបកស្រាយ ។ យើងកត់សម្គាល់ឃើញថា សាស្ត្រាចារ្យទាំងអស់បានចូលរួមយ៉ាងសកម្ម ។ ជាឧទាហរណ៍ ក្រុមដែលមានសមាជិកចំនួនដប់ប្រាំបីនាក់បាននាំគ្នាអង្គុយជាក្រុមធំមួយដើម្បីផ្លាស់ប្តូរយោបល់និងត្រងត្រាប់ស្តាប់ការបកស្រាយកំណាព្យរបស់ក្រុមខ្លួន ។ នៅពេលដែលត្រូវបានសួរថាតើសាស្ត្រាចារ្យចង់ឲ្យសិស្សបំពេញកិច្ចការតែងកំណាព្យឬធ្វើកិច្ចការស្រដៀងនេះទេ សាស្ត្រាចារ្យរូបនេះបានឆ្លើយតបថា

“សិស្សទាំងអស់ចូលចិត្តធ្វើកិច្ចការបែបនេះណាស់” ។

ជាចុងបញ្ចប់ ក្រុមធំៗនីមួយៗបានឡើងបកស្រាយអត្ថន័យនៃកំណាព្យរបស់ក្រុមខ្លួនទៅកាន់អង្គពិធីទាំងមូល ។ ក្រុមធំទីមួយបានសូត្រនូវកំណាព្យមួយដែលមានចំណងជើងថាខ្មែរពណ៌តែមួយដែលបកស្រាយពីការរស់នៅដោយរងទុក្ខលំបាកវេទនានិងភាពឈឺចាប់របស់ប្រជាជនខ្មែរ ហើយខ្មែរបានតស៊ូស្វែងរកសន្តិភាពនិងការផ្សះផ្សា ។ រូបគំនូររបស់ក្រុមនេះបានធ្វើការប្រៀបធៀបពីការបែងចែកខ្មែរកាលពីអតីតកាលជាមួយនឹងបច្ចុប្បន្នកាលដោយប្រើប្រាស់ពណ៌និងរូបធរណីមាត្រដែលមានសណ្ឋានខុសៗគ្នាមកធ្វើជាតំណាងឲ្យក្រុមនយោបាយផ្សេងៗគ្នាដើម្បីឆ្លុះបញ្ចាំងពីការបែងចែកប្រជាជនខ្មែរកាលពីមុនឆ្នាំ១៩៧៥និងការរួបរួមគ្នារបស់ប្រជាជននាពេលបច្ចុប្បន្ននេះ ។ សំខាន់បំផុតរូបភាពនេះបានតំណាងឲ្យសារសំខាន់នៃភាពបង្រួបបង្រួមគ្នានិងការឈប់កាប់សម្លាប់គ្នារវាងខ្មែរនិងខ្មែរ ។ ក្រុមទីពីរបានបកស្រាយកំណាព្យរបស់ខ្លួនដែលមានចំណងជើងថា “ការរួបរួមជាតិ” ។ កំណាព្យរបស់ក្រុមនេះបានរៀបរាប់ពីទុក្ខលំបាកវេទនានិងការបង្ហូរឈាមដែលកើតមាននៅលើទឹកដីកម្ពុជា ហើយក៏បានសង្កត់ធ្ងន់លើការទាមទារឲ្យបានមកនូវសុខសន្តិភាពនិងសេចក្តីសុខសុភមង្គល ហើយក៏បានបញ្ជាក់ថា ប្រជាជនខ្មែរបច្ចុប្បន្នកំពុងតែរៀនរស់នៅដោយគ្មានការរើសអើង ។ កំណាព្យនេះបានបញ្ជាក់ថាការរួបរួមគ្នាគឺពិតជាមានសារសំខាន់ដើម្បីឲ្យខ្មែរទាំងអស់គ្នារស់នៅដោយសន្តិភាព ។ រូបភាពរបស់ក្រុមនេះមានដូចជាពពកខ្មៅដែលតំណាងឲ្យការរងទុក្ខលំបាកវេទនានិងព្រះអាទិត្យចែងចាំងដែលច្រានពពកខ្មៅចេញទៅដើម្បីឲ្យប្រជាជនខ្មែររស់នៅដោយសន្តិភាព ។ ព្រះអាទិត្យចែងចាំងបានបំភ្លឺប្រាសាទអង្គរវត្ត និងដើមត្នោតដែលជាតំណាងឲ្យដួងព្រលឹងរបស់ប្រជាជនខ្មែរទាំងមូល ។ ក្រុមទីបីបានបកស្រាយកំណាព្យមួយនិយាយពីផ្កាឈូកដែលដុះចេញពីដីភក់ ។ ផ្កាឈូកនេះ តំណាងឲ្យអរិយធម៌ខ្មែរដែលធ្លាប់តែរុងរឿងនៅពេលដែលខ្មែរទាំងអស់គ្នារួបរួមជាធ្លុងមួយ ។ បន្ទាប់ មកទៀត ក្រុមនេះក៏បានរៀបរាប់ពីការចោទប្រកាន់ជាជនក្បត់ការបែកបាក់គ្នា ការប្រយុទ្ធតស៊ូ និងការកាប់សម្លាប់ដែលបានកើតមានឡើងនៅពេលដែលប្រជាជនខ្មែរមិនបានរួបរួមនិងសាមគ្គីគ្នា ។ កំណាព្យរបស់ក្រុមនេះបានបញ្ចប់ទៅដោយជំរុញលើកទឹកចិត្តឲ្យក្មេងៗជំនាន់ក្រោយចេះផ្សះផ្សានិងរួបរួមគ្នាដើម្បីឲ្យជាតិកម្ពុជារុងរឿងម្តងទៀត ។ ក្រុមទីបីនេះបានពន្យល់ថា ប្រវត្តិសាស្ត្រកម្ពុជាបានជំរុញលើកទឹកចិត្តឲ្យសាស្ត្រាចារ្យទាំងអស់គ្នាខិតខំប្រឹងប្រែងក្នុងការបំពេញកិច្ចការរបស់ខ្លួន ហើយក៏បានកត់សម្គាល់ថាវាពិតជាសំខាន់ក្នុងការឆ្លុះបញ្ចាំងពីវដ្តនៃជម្លោះដែលត្រូវបានបញ្ចប់ដោយការផ្សះផ្សា ។ សាស្ត្រាចារ្យទាំងអស់បានសើចសប្បាយពេញបន្ទប់អង្គពិធីខណៈពេលដែលអ្នកទាំងអស់គ្នាបានឈរកាន់ដៃគ្នាដូចរូបគំនូរដែលក្រុមទីបីបានគូរដើម្បីធ្វើជាតំណាងឲ្យការរួបរួមគ្នា ។

ចុងបញ្ចប់ ក្រុមទីបួនបានបកស្រាយកំណាព្យពីរដែលក្រុមរបស់ខ្លួនបានសរសេរ ។ កំណាព្យទីមួយដែលសូត្រដោយបទយីកេបានរៀបរាប់ពីអរិយធម៌អង្គរដែលត្រូវបានបំផ្លិចបំផ្លាញដោយខ្មែរក្រហម និងពីសន្តិភាព ការរួបរួមជាតិដែលមាននៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ ។ ក្រុមនេះបានបកស្រាយថាប្រទេសកម្ពុជាធ្លាប់ជាប្រទេសដ៏អង់អាចក្លាហានមួយ ប៉ុន្តែត្រូវបានបាក់បែកនិងបាត់បង់នូវអរិយធម៌ដ៏អស្ចារ្យដោយសារតែប្រជាជនខ្មែរបានរងទុក្ខលំបាកវេទនា ។ បច្ចុប្បន្ននេះ ប្រជាជនកម្ពុជាកំពុងតែរស់នៅដោយសន្តិភាពនិងភាពរួបរួមគ្នា ។ បន្ទាប់មកទៀត ក្រុមនេះក៏បានជំរុញឲ្យសាស្ត្រាចារ្យទាំងអស់ច្រៀងតាមកំណាព្យរបស់ខ្លួនដែលរៀបរាប់ពីទុក្ខលំបាកវេទនាពីអតីតកាល និងការបង្រួបបង្រួមនាពេលបច្ចុប្បន្ន ។ កំណាព្យទីពីររបស់ក្រុមនេះបានបកស្រាយពីបញ្ហាកាលពីអតីតកាលនិងការរួបរួមគ្នាដែលកើតមានកាលពីឆ្នាំ១៩៩៨ ។ រូបភាពដែលអមជាមួយនឹងកំណាព្យនេះឆ្លុះបញ្ចាំងពីមនោគមន៍វិជ្ជាសកលលោកដែលបានជះឥទ្ធិពលនិងបានដាក់សម្ពាធមកលើប្រទេសកម្ពុជា ។ រូបភាពនៃការចាប់ដៃគ្នាដែលឋិតនៅក្នុងរូបផែនទីប្រទេសកម្ពុជាបានតំណាងឲ្យការរួបរួមគ្នានិងការផ្សះផ្សា ។ ក្រោយពីការធ្វើបទបង្ហាញរបស់ក្រុមនីមួយៗមក លោកស្រីបណ្ឌិត ជា ផល្លា បានអរគុណដល់ក្រុមទាំងអស់ ហើយបានសង្ខេបពីវិធីសាស្ត្រនៃកិច្ចការសហការជាក្រុមដែលសាស្ត្រាចារ្យទាំងអស់បានរៀនសូត្រ និងអនុវត្ត ។ បន្ទាប់ពីបទបង្ហាញរបស់ក្រុមនីមួយៗបានបញ្ចប់ផុតទៅ កញ្ញា សូ ហ្វារីណា បានចែកសៀវភៅរបស់ខ្លួនជូនទៅឲ្យសាស្ត្រាចារ្យទាំងអស់ដែលសៀវ

ភៅនេះនិយាយពីរឿងរ៉ាវរបស់ស្ត្រីចាមរស់នៅក្រោមរបបខ្មែរក្រហមនិងបទពិសោធន៍របស់ស្ត្រីទាំងអស់នោះ ។ ហ្វារីណា បានកត់សម្គាល់ថា ស្ត្រីមូស្លីមនិងស្ត្រីកម្ពុជាបានទទួលរងទុក្ខវេទនាប្រហាក់ប្រហែលគ្នា ។ ជាឧទាហរណ៍ ស្ត្រីទាំងអស់ត្រូវបានបំបែកចេញពីក្រុមគ្រួសាររបស់ខ្លួន បង្ខំឲ្យធ្វើពលកម្មនិងគំរាមកំហែងដោយគោលនយោបាយរបស់ខ្មែរក្រហម ។ សូ ហ្វារីណា បានគូសបញ្ជាក់ថាស្ត្រីចាមក៏ត្រូវបានរងនូវការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនាដែរហើយបើទោះបីជាស្ត្រីទាំងអស់មានបំណងប្រឆាំងនឹងគោលនយោបាយនោះ ក៏អ្នកទាំងអស់នេះត្រូវតែលាក់ទុកការប្រឆាំងនេះនៅក្នុងចិត្តរបស់ខ្លួនជាជាងបង្ហាញការប្រឆាំងនេះទៅកាន់ខ្មែរក្រហមដោយចំហ ។

ជាចុងក្រោយ លោក ឆាំង យុ បានមានមតិឡើងយោបល់ ។ លោកនាយកបានរៀបរាប់ពីគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីសរសេរសៀវភៅប្រវត្តិសាស្ត្រតាមមូលដ្ឋានដែលមានឈ្មោះហៅថាគណៈកម្មការសរសេរសៀវភៅប្រវត្តិសាស្ត្រតាមមូលដ្ឋាន ។ លោកបានបកស្រាយថា គណៈកម្មការនេះនឹងមកប្រជុំពិភាក្សាគ្នានិងចងក្រងអត្ថបទទាំងអស់នោះទៅជាសៀវភៅដែលនឹងត្រូវយកទៅបោះពុម្ពផ្សាយហើយចែកជូនដល់សិស្សនិស្សិត ។ លោកនាយកក៏បានកោះអញ្ជើញសាស្ត្រាចារ្យទាំងអស់ដែលមានចំណាប់អារម្មណ៍ឲ្យចូលរួមធ្វើជាសមាជិកនៃគណៈកម្មការនេះ ។ បន្ទាប់មកទៀត លោកនាយកក៏បានណែនាំពីគម្រោងសម្ដែងល្ខោនជាសំឡេងដែលមានចំណងជើងថា ទម្លាយភាពស្ងប់ស្ងាត់ដែលសម្ដែងពីរឿងរ៉ាវទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យហើយល្ខោននេះបានសម្ដែងជាច្រើនលើកនៅតាមខេត្តផ្សេងៗទូទាំងប្រទេសកម្ពុជា ។ ជាពិសេសជាងនេះ ល្ខោនជាសំឡេងនេះក៏មានថតចម្លងដាក់នៅក្នុងស៊ីឌីដែរ ។ លោកនាយក ក៏បានចាក់ចម្រៀងពីរបទនៃល្ខោននេះជូនដល់សាស្ត្រាចារ្យទាំងអស់ស្ដាប់ ។ ចម្រៀងទីមួយជាចម្រៀងដែលមានទំនុកភ្លេងនិងអត្ថន័យលន្លង់លន្លោច ។ ចម្រៀងនេះនិយាយពីរឿងរ៉ាវរបស់ប្ដីដែលស្លាប់ទៅហើយនោះបានមកជួបប្រពន្ធរបស់ខ្លួននៅក្នុងសុបិនដើម្បីរៀបរាប់ប្រាប់ប្រពន្ធពីអារម្មណ៍នឹកចង់ជួបនាងជាប្រពន្ធ ។ ចំណែកឯចម្រៀងទីពីរ និយាយពីការប្រែក្លាយទន្លេឈាមមកជាទន្លេនៃការផ្សះផ្សានិងការទទួលខុសត្រូវ ដោយជំរុញឲ្យអ្នកស្ដាប់ «និយាយ» ។ លោកនាយក ឆាំង យុ ក៏បាននិយាយថា បទចម្រៀងនេះអាចចែកផ្សព្វផ្សាយជាមួយនឹងប្រទេសផ្សេងៗទៀតដែលទទួលរងនូវគ្រោះថ្នាក់ដូចគ្នានឹងប្រទេសកម្ពុជាដែរ ។


លោក ហ៊ុយ វណ្ណៈ មន្ត្រីកិច្ចការសាធារណៈរបស់សាលាក្ដីខ្មែរក្រហម

## សកម្មភាពពេលរសៀល

បន្ទាប់ពីការឈប់សម្រាកអាហារថ្ងៃត្រង់ មន្ត្រីកិច្ចការសាធារណៈរបស់តុលាការខ្មែរក្រហមគឺ លោក ហ៊ុយ វណ្ណៈ បានធ្វើបទបង្ហាញខ្លីមួយទៅកាន់សាស្ត្រាចារ្យទាំងអស់ ដោយជំរុញឲ្យសាស្ត្រាចារ្យទាំងអស់នាំសិស្សនិស្សិតរបស់ខ្លួនមកទស្សនាតុលាការខ្មែរក្រហមនេះ ។ លោកបានបកស្រាយថា ការិយាល័យរបស់លោកឬក៏មជ្ឈមណ្ឌលឯកសារកម្ពុជានឹងជួយសម្របសម្រួលដល់ការមកទស្សនារបស់សិស្សនិស្សិតទាំងអស់ ។ ក្រោយពីចែកចាយសៀវភៅព័ត៌មានស្ដីពីតុលាការខ្មែរក្រហមទៅកាន់សាស្ត្រាចារ្យទាំងអស់មក លោក ហ៊ុយ វណ្ណៈ បានផ្ដល់សេចក្ដីសង្ខេបពីដំណើរការវិវត្តរបស់តុលាការខ្មែរក្រហម ហើយបានគូសបញ្ជាក់ថា តុលាការខ្មែរក្រហមនេះ

ជាតុលាការជាតិ បើទោះបីជាមានបុគ្គលិកជនជាតិបរទេសបម្រើការងារនៅទីនោះក៏ដោយ ។ បន្ថែមលើនេះ តុលាការនេះក៏បានអនុញ្ញាតឲ្យសាធារណជនបានចូលរួមតាមដានដំណើការរបស់ខ្លួនដែរ ។ គោលបំណងនៃការិយាល័យកិច្ចការសាធារណៈរបស់លោកគឺដើម្បីពង្រីកការយល់ដឹងរបស់សាធារណជនទាំងក្នុងស្រុកនិងក្រៅស្រុកអំពីកិច្ចការរបស់តុលាការខ្មែរក្រហមនេះ ។ លោកបានសង្កត់ធ្ងន់លើការផ្លាស់ប្តូរឥរិយាបថរបស់សាធារណជនមកលើកិច្ចការរបស់តុលាការដោយបានកត់សម្គាល់ថា ដើមឡើយប្រជាជនទូទៅមិនយល់ថា តុលាការជាកន្លែងដែលល្អនោះទេ ប៉ុន្តែបច្ចុប្បន្ននេះសាធារណជនយល់ថាតុលាការជាកន្លែងដែលល្អប្រសើរ ហើយមានលក្ខណៈកាន់តែបើកចំហជាងមុនផងដែរ ។ ជាចុងក្រោយលោកក៏បានបញ្ជាក់ថា បើទោះបីជាតុលាការនេះបានបំពេញកិច្ចការតាមអាណត្តិរបស់ខ្លួនដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហម និងអ្នកដែលមានការទទួលខុសត្រូវខ្ពស់មកកាត់ទោសក៏ដោយ ក៏ការបង្កើតជាតុលាការកាត់ទោសនេះមិនមែនជាមធ្យោបាយចុងក្រោយដើម្បីស្វែងរកយុត្តិធម៌នោះទេ ។ ជាងនេះទៅទៀត សាស្ត្រាចារ្យសាកលវិទ្យាល័យទាំងអស់មានតួនាទីអប់រំក្មេងៗជំនាន់ក្រោយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ។

បន្ទាប់មកទៀត សាស្ត្រាចារ្យទាំងអស់ក៏មានឱកាសសួរសំណួរទៅកាន់លោក ហ៊ុយ វណ្ណៈ ហើយសំណួរទាំងអស់សុទ្ធតែជាសំណួរដែលមានលក្ខណៈជាក់លាក់និងទូលំទូលាយ ។ ឧទាហរណ៍សំណួរមួយចំនួនបានសួរថា «តើតុលាការអាចបញ្ចប់កិច្ចការរបស់ខ្លួនបានដែរឬទេ ប្រសិនបើជនជាប់ចោទស្លាប់? តើសម្អាងលើភ័ស្តុតាងអ្វីដែលអះអាងថា តុលាការខ្មែរក្រហមនេះគឺជាតុលាការជាតិ? លោក ហ៊ុយ វណ្ណៈ បានឆ្លើយតបនឹងសំណួរទាំងអស់នេះបានយ៉ាងក្បោះក្បាយបំផុត ។

បន្ទាប់មកទៀត លោក គ្រីស្តូហ្វ័រ ឌៀរីង បានធ្វើបទបង្ហាញជាបន្តទៀតស្តីពីវិធីសាស្ត្របង្រៀនចំនួនពីរ ។ លោកបានស្នើឲ្យសាស្ត្រាចារ្យទាំងអស់ពិនិត្យមើលលើកំពូលពីរ៉ាមីតរបស់ប្លូមថេហ្សូ ណូមី ហើយជ្រើសរើសថាតើចំណុចមួយណានៃកំពូលពីរ៉ាមីតដែលជាចំណុចសំខាន់ជាងគេ ។ សាស្ត្រាចារ្យទាំងអស់បានឆ្លើយតបថាផ្នែកខាងក្រោមនៃពីរ៉ាមីតគឺការទទួលបានចំណេះដឹងជាចំណុចសំខាន់ជាងគេ ហើយសាស្ត្រាចារ្យចំនួនពីរនាក់បានបញ្ចេញមតិថាអ្នកទាំងពីរបានចំណាយពេលច្រើនដើម្បីផ្ទេរចំណេះដឹងនិងព័ត៌មានស្តីពីព្រឹត្តិការណ៍សំខាន់ៗឲ្យសិស្សនិស្សិតរបស់គាត់ ។ លោក គ្រីស្តូហ្វ័រ ឌៀរីង បានឆ្លើយតបទៅវិញថា បើទោះបីជាចំណេះដឹងមានសារសំខាន់ជាងគេក៏ដោយ ក៏វាពិតជាមានសារសំខាន់ដែលសាស្ត្រាចារ្យទាំងអស់អាចបកស្រាយលើព្រឹត្តិការណ៍ទាំងអស់នោះចេញសេចក្តីសន្និដ្ឋានដែលសមហេតុផលនិងផ្តល់ព័ត៌មានសំខាន់ៗទៅកាន់សិស្សនិស្សិត ។ លោកបានគូសបញ្ជាក់ថា សាស្ត្រាចារ្យមិនមែនមានតែតួនាទីជាផ្តល់ចម្លើយទៅកាន់បញ្ហាតែមួយមុខទេ តែសាស្ត្រាចារ្យត្រូវតែចេះចោទជាសំណួរនិងបញ្ហាថ្មីៗដែលពាក់ព័ន្ធនឹងបទពិសោធន៍ជាក់ស្តែងទៅឲ្យសិស្សនិស្សិត ។ ហើយបើទោះបីជាចំណេះដឹងមានសារសំខាន់ក៏ដោយ ក៏សិស្សនិស្សិតត្រូវតែចេះយកចំណេះដឹងដែលខ្លួនទទួលបានមកប្រើប្រាស់ដើម្បីបំពេញកិច្ចការចាំបាច់មួយ ។ ដូច្នេះ សាស្ត្រាចារ្យទាំងអស់ក៏គួរតែចំណាយពេលវេលាខ្លះទៅលើផ្នែកផ្សេងទៀតនៃប្លូមថេហ្សូណូមី នេះដែលក្នុងនោះរួមមាន ៖ ការយល់ដឹង ការអនុវត្តការវាយតម្លៃនិងការវិភាគជាដើម ។ លោក គ្រីស្តូហ្វ័រ ឌៀរីង បានក្រើនរំឭកដល់សាស្ត្រាចារ្យទាំងអស់ពីតួនាទីរបស់សិស្សនៅក្នុងការធ្វើកិច្ចការពិភាក្សាជាក្រុម ។ អ្នកសម្របសម្រួលនឹងទទួលបានការណែនាំពីគ្រូបង្រៀនដើម្បីធានាថាសមាជិកក្នុងក្រុមផ្សេងទៀតយល់ពីកិច្ចការរបស់សមាជិកក្រុម ។ អ្នកផ្ទៀងផ្ទាត់ពេលវេលាត្រូវតាមដានពេលវេលាដែលក្រុមរបស់ខ្លួនមាន ។ ចំណែកឯអ្នកលើកទឹកចិត្តវិញត្រូវតែធានាថាសមាជិកនីមួយៗបំពេញកិច្ចការរបស់ក្រុម ។ អ្នកកត់ត្រាត្រូវសរសេររបាយការណ៍ពីការងាររបស់ក្រុមខ្លួន ហើយចំណែកឯអ្នករាយការណ៍ត្រូវឡើងធ្វើបទបង្ហាញពីកិច្ចការសម្រេចចុងក្រោយរបស់ខ្លួនទៅកាន់ក្រុមផ្សេងទៀត ។

បន្ទាប់ពីសាស្ត្រាចារ្យទាំងអស់ត្រូវបានបែងចែកជាក្រុមតាមពណ៌ដូចលើកមុនមក សាស្ត្រាចារ្យទាំងអស់បានចាប់ផ្តើមធ្វើកិច្ចការសហការជាក្រុម ។ ក្រុមនីមួយៗត្រូវចាត់តាំងអ្នកសម្របសម្រួលដើម្បីឲ្យលោក គ្រីស្តូហ្វ័រ ឌៀរីង ផ្តល់ការណែនាំពីកិច្ចការដែលក្រុមទាំងអស់ត្រូវធ្វើ ។ ក្រុមធំៗដែលមានពណ៌ដូចគ្នាត្រូវបានបែងចែកជាក្រុមពីរដែលក្រុមមួយត្រូវអានពីព័ត៌មានស្តីពី

ប្រទេសអ៊ីរ៉ាក់ និងក្រុមពណ៌ផ្សេងទៀតអានព័ត៌មានស្តីពីប្រទេសអាល្លឺម៉ង់ និងការសម្លាប់រង្គាល ។ លោកក៏បានណែនាំឲ្យក្រុមនីមួយៗឆ្លើយនឹងសំណួរចំនួនពីរ ក្រោយពីការអានស្រាវជ្រាវរបស់ខ្លួន ។ ១) តើមានព័ត៌មាននិងព្រឹត្តិការណ៍សំខាន់បំផុតអ្វីខ្លះរបស់ប្រវត្តិសាស្ត្រនោះ? ២) តើព័ត៌មានអ្វីដែលសំខាន់ជាងគេទាក់ទងនឹងជនរងគ្រោះ? ដូច្នេះសមាជិកក្រុមនីមួយៗត្រូវតែពន្យល់បកស្រាយសមាជិកផ្សេងទៀតពីព័ត៌មានសំខាន់ៗដែលខ្លួនទទួលបាន ។ ក្រុមនីមួយៗទទួលបានពេលវេលាចំនួនដប់នាទីដើម្បីបំពេញកិច្ចការនេះ ។

អ្នកសម្របសម្រួលបានវិលត្រឡប់ទៅកាន់ក្រុមធំៗរបស់ខ្លួនវិញ ហើយបានប្រាប់សមាជិកផ្សេងទៀតពីកិច្ចការដែលក្រុមរបស់ខ្លួនត្រូវធ្វើ ។ ដោយសារតែសមាជិកផ្សេងទៀតត្រូវបានរំខានដោយរង់ចាំអ្នកសម្របសម្រួលយូរពេក នោះវាទាមទារឲ្យមានការចំណាយពេលមួយរយៈខ្លីដើម្បីឲ្យសមាជិកទាំងអស់មានឆន្ទៈចូលរួមបំពេញកិច្ចការនេះម្តងទៀត ។ យើងសង្កេតឃើញថាក្រុមខ្លះធ្វើការស្រាវជ្រាវរកព័ត៌មានទាក់ទងនឹងសំណួរទាំងពីរដោយឡែកៗពីគ្នា ចំណែកឯក្រុមផ្សេងទៀតបានផ្លាស់ប្តូរមតិយោបល់រវាងគ្នាទៅវិញទៅមក ។

បន្ទាប់ពីការឈប់សម្រាកអាហារសម្រន់មក លោក គ្រីស្តូហ្វ័រ ឌៀរីង បានរំឭកដល់សាស្ត្រាចារ្យទាំងអស់ថា វិធីសាស្ត្របង្រៀនតាមរបៀបលំហាត់ប្រៀបធៀបអាចយកទៅប្រើប្រាស់បានសម្រាប់ប្រធានបទគ្រប់ប្រភេទ ។ វិធីសាស្ត្រប្រៀបធៀបនេះចែកជាបីដំណាក់កាល ។ ទីមួយ គ្រូបង្រៀនត្រូវផ្តល់ព័ត៌មានសំខាន់ៗទៅឲ្យសិស្សរបស់ខ្លួន ។ បន្ទាប់មកទៀត សិស្សទាំងអស់ត្រូវតែដឹងនិងយល់ឲ្យបានច្បាស់ពីព័ត៌មាននៃប្រធានបទនោះ ។ ទីបី គ្រូបង្រៀននឹងវិភាគលើកម្រិតយល់ដឹងរបស់សិស្សចំពោះប្រធានបទនោះដោយឲ្យសិស្សឡើងមកធ្វើបទបង្ហាញនៅក្នុងថ្នាក់ ។ ដើម្បីអនុវត្តវិធីសាស្ត្រនេះលោក គ្រីស្តូហ្វ័រ ឌៀរីង បានស្នើឲ្យសាស្ត្រាចារ្យពីររូបឡើងមកចែករំលែកព័ត៌មានសំខាន់ដែលខ្លួនគិតថាជាចម្លើយទៅកាន់ក្រុមធំៗផ្សេងទៀត ។ លោកក៏បានរៀបរាប់បន្ថែមទៀតថាតាមវិធីសាស្ត្រប្រៀបធៀបនេះសមាជិកក្រុមដទៃទៀតក៏អាចចូលរួមចែករំលែកមតិយោបល់បន្ថែមពីការស្រាវជ្រាវរបស់ខ្លួន ។ វិធីសាស្ត្របែបនេះអនុញ្ញាតឲ្យយើងវិភាគបានថាតើសមាជិកក្រុមនេះបានយល់ពីព័ត៌មានស្រដៀងគ្នាដែរឬយ៉ាងណា ។ យ៉ាងណាមិញ ដោយសារតែបញ្ហាពេលវេលាមិនគ្រប់គ្រាន់ក្រុមទាំងអស់បានបន្តអនុវត្តដំណាក់កាលមួយទៀតនៃវិធីសាស្ត្របង្រៀនលំហាត់ប្រៀបធៀបនេះ ។

សម្រាប់កិច្ចការបន្ទាប់មកទៀត អ្នកសម្របសម្រួលត្រូវបានណែនាំឲ្យបែងចែកសមាជិកក្រុមតូចៗដែលមានតែគ្នាពីរនាក់ ។ ក្នុងក្រុមតូចនេះសមាជិកម្នាក់ត្រូវតែ «យល់ឲ្យច្បាស់» ពីប្រវត្តិសាស្ត្ររបស់ប្រទេសអ៊ីរ៉ាក់ ហើយម្នាក់ទៀតត្រូវតែ «យល់ឲ្យច្បាស់» ពីប្រវត្តិសាស្ត្ររបស់ប្រទេសអាល្លឺម៉ង់ ។ ក្រុមតូចៗនីមួយៗត្រូវតែឆ្លើយនឹងសំណួរបីដូចជា ១) តើអ្វីខ្លះដែលជាភាពដូចគ្នានៃអំពើសម្លាប់រង្គាល?២) តើអ្វីខ្លះដែលជាភាពខុសគ្នារវាងអំពើសាហាវឃោរឃៅ? ៣) តើអំពើសាហាវឃោរឃៅដែលកើតមាននៅក្នុងប្រទេសអ៊ីរ៉ាក់និងអាល្លឺម៉ង់មានលក្ខណៈដូចគ្នាឬខុសគ្នាពីអ្វីដែលកើតមាននៅក្រោមរបបខ្មែរក្រហមយ៉ាងដូចម្តេចខ្លះ? ក្រុមនីមួយៗទទួលបានពេលវេលាចំនួនប្រាំបីនាទីដើម្បីបំពេញកិច្ចការនេះ ។ ដោយសារជិតដល់ពេលឈប់សម្រាក សាស្ត្រាចារ្យទាំងអស់កាន់តែមានអារម្មណ៍នឿយហត់ក្នុងការបំពេញកិច្ចការជាក្រុមរួមគ្នានេះដែលអ្នកទាំងអស់គ្នាបានធ្វើពីមុនរួចម្តងហើយ ។ ទោះបីជាយ៉ាងនេះក្តី ក៏សមាជិកនីមួយៗបានផ្លាស់ប្តូរគំនិតយោបល់របស់ខ្លួនទៅវិញទៅមកនិងពិភាក្សាយ៉ាងក្បោះក្បាយលើសំណួរដែលចោទសួរ ។ នៅពេលដែលសមាជិកក្រុមបានជួបជុំគ្នា ហើយលោក គ្រីស្តូហ្វ័រ ឌៀរីង បានស្នើសុំឲ្យសមាជិកក្រុមម្នាក់ឡើងមកផ្លាស់ប្តូរគំនិតយោបល់របស់ខ្លួន ។ សាស្ត្រាចារ្យម្នាក់បានរៀបរាប់ថាបើទោះបីជាមានពូជសាសន៍ខុសៗគ្នាត្រូវបានគាមសម្លាប់ ហើយវិធីសាស្ត្រនៃការសម្លាប់នោះខុសៗគ្នាក៏ដោយ ក៏ការសម្លាប់នៅតែកើតមាននៅក្នុងប្រទេសទាំងបីនេះដដែល ។

ជាចុងបញ្ចប់ លោក គ្រីស្តូហ្វ័រ ឌៀរីង បានសង្ខេបបញ្ចប់លើវិធីសាស្ត្របង្រៀនតាមវិធីប្រៀបធៀប ។ លោកបានគូសបញ្ជាក់ថាដំណាក់កាលទីពីរនៃវិធីសាស្ត្រនេះបានធ្វើឲ្យសិស្សចេះបង្រៀនគ្នាទៅវិញទៅមកដូចគ្នានឹងសកម្មភាពដែលសាស្ត្រាចារ្យទើបតែបានអនុវត្ត ។ លោកបានសង្កត់ធ្ងន់ថា ការអនុវត្តនេះ

គឺធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីវិធីសាស្ត្រប្រៀបធៀប និងដើម្បីបង្ហាញពីវិធីសាស្ត្រដែលសិស្សអាចបង្រៀនគ្នាទៅវិញទៅមកស្របពេលដែលកំពុងតែធ្វើការជាក្រុម ។

នៅពេលដែលសួរថាតើគាត់នឹងយកវិធីសាស្ត្រដឹកសនេះទៅអនុវត្តនៅក្នុងការបង្រៀនរបស់ខ្លួនដែរឬទេ នោះសាស្ត្រាចារ្យម្នាក់នោះបានឆ្លើយតបថា លោកមិនគិតថាវិធីសាស្ត្រនេះវាមានភាពសមរម្យសម្រាប់សិស្សកម្រិតទាបដែលសិស្សទាំងអស់នេះអាចនឹងមានការពិបាកក្នុងការឆ្លើយនឹងសំណួរស្របពេលដែលពួកគេកំពុងតែធ្វើកិច្ចការជាដៃគូបើយើងប្រៀបធៀបជាមួយនឹងការពិភាក្សាជាក្រុមធំ ។ យ៉ាងណាមិញ សាស្ត្រាចារ្យម្នាក់ទៀតបានអះអាងថា គាត់នឹងប្រើប្រាស់វិធីសាស្ត្រពិភាក្សាជាក្រុមនិងវិធីសាស្ត្រសិស្សបង្រៀនសិស្សគ្នាឯងនេះពីព្រោះថាវិធីសាស្ត្រទាំងអស់នេះជួយឲ្យសិស្សចេះចោទសួរសំណួរនិងចេះរៀនសូត្រពីគ្នាទៅវិញទៅមក ។

ជាចុងបញ្ចប់ លោក គ្រីស្តូហ្វ័រ ឌៀរីង បានធ្វើសេចក្តីសង្ខេបនៃវគ្គបណ្តុះបណ្តាលនេះ ។ លោកបានស្នើសុំឲ្យអ្នកស្ម័គ្រចិត្តពីរនាក់ឡើងមកសរសេរយ៉ាងសង្ខេបពីសកម្មភាពដែលខ្លួនបានរៀនសូត្រនិងធ្វើនៅក្នុងអំឡុងវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃនេះនៅលើក្តារខៀននៅក្នុងសាលប្រជុំ ។ លោកក៏បានកត់សម្គាល់ថាបើទោះបីជាវាមានសារសំខាន់ក្នុងការផ្តល់ជាសេចក្តីសង្ខេបលើអ្វីដែលខ្លួនបានរៀនហើយក៏ដោយ ក៏វាជាការប្រសើរដែលសិស្សអាចនិយាយរៀបរាប់ពីអ្វីដែលខ្លួនឯងបានរៀនដោយខ្លួនឯងជាជាងគ្រូប្រាប់សិស្សទាំងអស់ពីអ្វីដែលសិស្សបានរៀននិងគួររៀន ។ បន្ទាប់មក លោកក៏បានស្វែងរកអ្នកស្ម័គ្រចិត្តឲ្យឡើងមកចែករំលែកអ្វីដែលខ្លួនបានរៀនសូត្រយល់ដឹងតាមរយៈវគ្គបណ្តុះបណ្តាលនេះ ។ សាស្ត្រាចារ្យដែលស្ម័គ្រចិត្តបានផ្តល់នូវព័ត៌មានជាច្រើនដែលខ្លួនបានរៀនសូត្រពីវគ្គបណ្តុះបណ្តាលនេះ ដែលក្នុងនោះរួមមានការយល់ដឹងពីព្រឹត្តិការណ៍បន្ថែមទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ជាឧទាហរណ៍ សាស្ត្រាចារ្យបីរូបបានរៀបរាប់ពីការសិក្សាពីឥទ្ធិពលបរទេសដែលជះឥទ្ធិពលមកលើការប្រព្រឹត្តអំពើឃោរឃៅនៅក្នុងប្រទេសកម្ពុជា ។

ការសង្កត់ធ្ងន់របស់សាស្ត្រាចារ្យទាំងអស់លើការសិក្សាពីព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រខ្មែរក្រហមបានឆ្លុះបញ្ចាំងឲ្យឃើញពីការផ្តោតសំខាន់លើព័ត៌មានស្តីពីព្រឹត្តិការណ៍ផ្សេងៗជាជាងការផ្តោតលើវិធីសាស្ត្របង្រៀន ។ ហើយតាមរយៈបទសម្ភាសន៍ភាគច្រើន សាស្ត្រាចារ្យទាំងអស់ក៏បានរៀបរាប់ដូចគ្នានេះដែរ ។



លោក គ្រីស្តូហ្វ័រ ឌៀរីង កំពុងណែនាំអំពីវិធីសាស្ត្របង្រៀន

បើទោះបីជាសាស្ត្រាចារ្យមួយចំនួនយល់ថា វិធីសាស្ត្របង្រៀនដែលវគ្គបណ្តុះបណ្តាលបានផ្តល់ឲ្យមានសារសំខាន់និងមានប្រយោជន៍ដល់ការបង្រៀនក៏ដោយ ក៏សាស្ត្រាចារ្យមួយភាគធំចាប់អារម្មណ៍នឹងការសិក្សាពីព្រឹត្តិការណ៍ទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាង។ ឧទាហរណ៍ សាស្ត្រាចារ្យម្នាក់បានរៀបរាប់ថា បើទោះបីជាគាត់មានសៀវភៅប្រវត្តិសាស្ត្រដើម្បីបង្រៀនសិស្សក៏ដោយ ក៏សាស្ត្រាចារ្យរូបនេះមានការខ្វះខាតនូវវិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាពសម្រាប់ការបង្រៀនប្រវត្តិសាស្ត្រនេះដែរ។ អ្នកគ្រូសាស្ត្រាចារ្យមុខវិជ្ជាធនាគារនិងហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិឈ្មោះ ឈឹន ដាលី បាននិយាយថា អ្នកគ្រូ



ឈឹន ដាលី

បានអញ្ជើញមកចូលរួមវគ្គបណ្តុះបណ្តាលនេះដើម្បីយល់ដឹងពីព្រឹត្តិការណ៍សំខាន់ៗជុំវិញប្រវត្តិសាស្ត្រខ្មែរក្រហមដូចជាចំនួនមនុស្សស្លាប់និងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះទាំងអស់នោះ។ សាស្ត្រាចារ្យក៏បានអះអាងថា វគ្គបណ្តុះបណ្តាលនេះបានផ្តល់ព័ត៌មានសំខាន់ដូចក្តីរំពឹង។ សាស្ត្រាចារ្យ អេង សុភាព មកពីវិទ្យាស្ថានខ្មែរជំនាន់ថ្មីបានអះអាងថា គាត់មានចំណាប់អារម្មណ៍ខ្លាំងមកលើព្រឹត្តិការណ៍ដែលកើតមានជាក់ស្តែងនៅក្នុងអំឡុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ក៏សង្ឃឹមថានឹងបានទទួលនូវចំណេះដឹងផ្សេងៗទាក់ទងនឹងវិធីសាស្ត្របង្រៀនដែរ។ លោកគ្រូក៏បានបកស្រាយថាគាត់ធ្លាប់មានបទពិសោធន៍ច្រើនពីមុនមកទាក់ទងនឹងចំណេះដឹងនៃវិធីសាស្ត្របង្រៀនហើយវិធីសាស្ត្រលំហាត់ប្រៀបធៀបនេះ គាត់ក៏បានធ្លាប់ប្រើប្រាស់នៅក្នុងថ្នាក់រៀនរបស់គាត់ដែរ។ ស្រដៀងគ្នានេះ សាស្ត្រាចារ្យ សេង ជីណូ មកពីវិទ្យាស្ថានប្រាយហូបបាននិយាយថា វិធីសាស្ត្ររៀបចំមេរៀនទាំងអស់នេះមានលក្ខណៈស្រដៀងគ្នានឹងវិធីសាស្ត្រដែលណែនាំដោយក្រសួងអប់រំ ហើយ ជីណូ ក៏បានអះអាងថា គាត់បានប្រើប្រាស់វិធីសាស្ត្ររៀបចំមេរៀនដែលមានដូចជាគោលដៅ និងចំណុចបំណងរួមទាំងវិធីសាស្ត្រផ្សេងៗទៀតរួចហើយដែរ។

បន្ទាប់ពីការពិភាក្សាពីចំណេះដឹងផ្សេងៗដែលសាស្ត្រាចារ្យទាំងអស់បានទទួលបានពីវគ្គបណ្តុះបណ្តាលនេះមក សាស្ត្រាចារ្យម្នាក់បានកត់សម្គាល់ថាវគ្គបណ្តុះបណ្តាលនេះគឺជាជំហានមួយដែលដឹកនាំប្រទេសកម្ពុជាឲ្យដើរឆ្ពោះទៅមុខ ហើយសាស្ត្រាចារ្យម្នាក់ទៀតក៏បានមានយោបល់ថា វាពិតជាមានសារសំខាន់ក្នុងការប្រើប្រាស់ប្រវត្តិសាស្ត្រពីអតីតកាលរបស់ប្រទេសកម្ពុជាដើម្បីបង្រៀនយុវជនខ្មែរជំនាន់ក្រោយ។ ជាក់ស្តែង សាស្ត្រាចារ្យ ឈឹន ដាលី បាននិយាយថា អ្នកគ្រូនឹងបង្រៀនសិស្សរបស់អ្នកគ្រូពីអំពើសាហាវឃោរឃៅដែលកើតមាននៅក្នុងអំឡុងរបបខ្មែរក្រហមដើម្បីឲ្យសិស្សនិស្សិតទាំងអស់ចៀសវាងប្រព្រឹត្តអំពើទាំងអស់នោះ។ នៅពេលដែលសួរថាតើយុវជនជំនាន់ក្រោយដូចជារូបខ្លួនជឿលើព្រឹត្តិការណ៍ដែលកើតមាននៅរបបខ្មែរក្រហមឬទេនោះ និស្សិតឈ្មោះ យ៉ាន ពេជ្រ ដែលជានិស្សិតផ្នែកវិស្វកម្មនៃសាកលវិទ្យាល័យអន្តរជាតិឌីវីបានឆ្លើយថា «យុវជនជំនាន់ក្រោយមិនសូវជឿលើព្រឹត្តិការណ៍ទាំងអស់នោះប៉ុន្មានទេ រួមទាំងរូបខ្ញុំផងដែរ»។ បើទោះបីជាឪពុកម្តាយរបស់ប្អូនបានប្រាប់ប្អូនពីព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីសម័យនោះជាហូរហែក៏ដោយ ក៏ប្អូនបានមកចូលរួមវគ្គបណ្តុះបណ្តាលនេះដើម្បីធ្វើការសិក្សាស្វែងយល់បន្ថែមទៀតដែរ។ ពេជ្រ បានសង្កត់ធ្ងន់ថា ប្រជាជនកម្ពុជាទាំងអស់ចាំបាច់ត្រូវតែរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីចៀសវាងកុំប្រព្រឹត្តអំពើឃោរឃៅទាំងអស់នោះ។

លោក ឆាំង យុ បានមានមតិបញ្ចប់អង្គពិធីនៃវគ្គបណ្តុះបណ្តាលដែលមានរយៈពេលបីថ្ងៃនេះ។ លោកនាយកបានគូសបញ្ជាក់ថា វាពិតជាមានសារសំខាន់ក្នុងការចងចាំថាប្រវត្តិសាស្ត្រខ្មែរក្រហមមិនមែនផ្តោតតែទៅលើការកាប់សម្លាប់នោះទេ។ យើងក៏ត្រូវទាញ

យកព័ត៌មានទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងនៃរបបខ្មែរក្រហមដូចជា ប្រព័ន្ធគ្រប់គ្រងធនាគារនិងប្រព័ន្ធបច្ចេកវិជ្ជាជាដើម ។ លោកនាយកក៏បានកត់សម្គាល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានចម្រៀងខ្សែភាពយន្តនិងសៀវភៅដែលត្រូវបានផលិតនិងនិពន្ធកាលពីអំឡុងរបបខ្មែរក្រហមបន្ថែមលើឯកសារដែលនៅសេសសល់ពីរបប លន់ នល់ និងឯកសារដែលទទួលបានពីបរទេសជាច្រើនទៀតដែរ ។ លោកនាយកបានជំរុញលើកទឹកចិត្តសាស្ត្រាចារ្យសាកលវិទ្យាល័យទាំងអស់ឲ្យជំរុញសិស្សនិស្សិតរបស់ខ្លួនធ្វើការស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះ ហើយក៏បានក្រើនរំឭកថាមជ្ឈមណ្ឌលឯកសារកម្ពុជាអាចនឹងផ្ដល់ជំនួយផ្សេងៗដល់ការស្រាវជ្រាវរបស់សិស្សនិស្សិតដែរ ។ លោកនាយកបានជំរុញឲ្យសិស្សនិស្សិតទាំងអស់ឲ្យធ្វើការស្រាវជ្រាវសិក្សា និងបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនេះទៅកាន់យុវជនជំនាន់ក្រោយទៀត ហើយបានសង្កត់ធ្ងន់ថាគ្រូបង្រៀនអាចដើរតួធ្វើឲ្យអរិយធម៌កម្ពុជារុងរឿងសុសសាយសាជាថ្មីម្ដងទៀត ។

ពេលនេះ លោកនាយក ឆាំង យុ បានថ្លែងថា នេះគឺជាពេលវេលាមួយដែលប្រជាជនកម្ពុជាត្រូវសរសេរពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនមិនមែនបរទេសឡើយ ។ សាស្ត្រាចារ្យម្នាក់បាននិយាយថា លោកមានអារម្មណ៍ក្រៀមក្រំដែលវគ្គបណ្ដុះបណ្ដាលនេះបានបញ្ចប់ទៅឆាប់ពេក ពីព្រោះលោកមិនដឹងថាពេលណាទើបក្រុមសិក្ខាកាមទាំងអស់អាចមកជួបជុំគ្នាម្ដងទៀតបែបនេះនោះទេ ។ លោកសាស្ត្រាចារ្យម្នាក់ទៀតបានរៀបរាប់ពីស្ថានភាពរបស់បូជនីយដ្ឋានដែលតម្កល់ទុកនូវលលាដ៍ក្បាល និងឆ្អឹងរបស់ជនរងគ្រោះ ដោយកត់សម្គាល់ថា គាត់ធ្លាប់បានឃើញសត្វគោអង្កៀមឆ្អឹងជនរងគ្រោះនៅឯបូជនីយដ្ឋានមួយកន្លែង ។ លោកនាយកបានណែនាំថាសាស្ត្រាចារ្យអាចរកដំណោះស្រាយ បានតាមរយៈការជំរុញឲ្យនិស្សិតផ្ដួចផ្ដើមគំនិតស្នើសុំថវិកាដើម្បីសាងសង់បូជនីយដ្ឋានដែលល្អដើម្បីតម្កល់ទុកលលាដ៍ក្បាលនិងឆ្អឹងរបស់ជនរងគ្រោះឲ្យបានល្អជាងនេះ ។ បន្ថែមលើនេះ លោកនាយក ឆាំង យុ បាននិយាយថា ដើម្បីទទួលបានយុត្តិធម៌យើងត្រូវការតុលាការ ហើយដើម្បីការផ្សះផ្សាយើងត្រូវការសិល្បៈ ។ បន្ទាប់មកទៀត លោកនាយកក៏បានណែនាំអ្នកសម្ដែងល្ខោន «ទម្លាយភាពស្ងប់ស្ងាត់» ម្នាក់ដែលមានសំឡេងពិរោះក្រលួចមកច្រៀងចម្រៀងពីរបទដែលចម្រៀងទីមួយនិយាយពីអារម្មណ៍របស់ស្វាមីដែលស្លាប់ទៅ និងចម្រៀងទីពីរនិយាយពីការប្រែក្លាយទន្លេឈាមមកជាទន្លេនៃការផ្សះផ្សា ។

**សារ៉ុន គីម, ថេសា បៀរឡេក, សារីតា គួប៊ីក,**



និស្សិតសាកលវិទ្យាល័យវ៉ាន់ដា ចូលរួមសិក្ខាសាលានាថ្ងៃបើកវគ្គដំបូង

# សារសំខាន់នៃវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្រិតឧត្តមសិក្សា

ការបណ្តុះបណ្តាលគ្រូកម្រិតមហាវិទ្យាល័យនេះត្រូវបានប្រារព្ធធ្វើលើកដំបូងបង្អស់នៅប្រទេសកម្ពុជា ដោយហេតុថាចាប់តាំងពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម គឺផ្តោតសំខាន់ទៅលើបញ្ហានយោបាយ ព្រោះកម្លាំងយោធារបស់ខ្មែរក្រហមនៅតែបន្តធ្វើសកម្មភាពរបស់ខ្លួននៅតាមបណ្តោយព្រំដែនភាគខាងលិច និងបានគ្រប់គ្រងតំបន់មួយចំនួនទៀតនៅក្នុងប្រទេសកម្ពុជា ។ លើសពីនេះទៅទៀត ខ្មែរក្រហមត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ និងមានការគាំទ្រពីប្រទេសមួយចំនួន ។

នៅអំឡុងពេលការសិក្សាប្រវត្តិសាស្ត្រសម័យខ្មែរក្រហមមិនទាន់បានរៀបចំ និងបែងចែកជាមុខវិជ្ជាបង្រៀនឲ្យបានច្បាស់លាស់ និងដាច់ដោយឡែកទេ គឺក្រសួងអប់រំគ្រាន់តែបានបញ្ជ្រាបផ្នែកប្រវត្តិសាស្ត្រនេះចូលក្នុងមេរៀនអំណាននៃមុខវិជ្ជាភាសាខ្មែរ សីលធម៌ ឬ ពលរដ្ឋវិជ្ជា តែប៉ុណ្ណោះ ។ នេះបើយើងយោងតាមលោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួង អប់រំ យុវជន និងកីឡា ។

ក្រោយមក ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំមុខវិជ្ជាប្រវត្តិវិទ្យាទៅជាមុខវិជ្ជាមួយដាច់ដោយឡែកពីមុខវិជ្ជាសង្គមផ្សេងទៀត ហើយបន្ទាប់ពីកងទ័ពខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៨ ក្រសួងបានបញ្ចូលផ្នែកខ្លះនៃប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងមុខវិជ្ជាប្រវត្តិវិទ្យាសម្រាប់បង្រៀននៅសាលាចំណេះទូទៅ ។ នៅឆ្នាំ២០០៧



លោកជំទាវ ទន់ សាអ៊ីម ចូលរួមកម្មវិធីបណ្តុះបណ្តាលគ្រូកម្រិតឧត្តមសិក្សា

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ សៀវភៅនេះត្រូវបានផ្ទៀងផ្ទាត់និងត្រួតពិនិត្យដោយរាជរដ្ឋាភិបាលកម្ពុជា ហើយក្រោយមកបានប្រកាសឲ្យបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នេះជាផ្លូវការនៅក្នុងសាលាចំណេះទូទៅនិងសាកលវិទ្យាល័យទូទាំងប្រទេសកម្ពុជា ។

**និត ហ៊ុយ** អាយុ ៣៧ឆ្នាំ មានស្រុកកំណើតនៅភូមិជំនិះ ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង។ បច្ចុប្បន្ន ហ៊ុយ ជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យបាត់ដំបងដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះយល់ឃើញថា «ជាការប្រសើរដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការបណ្តុះបណ្តាលដល់សាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រហើយនេះវាជាព្រឹត្តិការណ៍មួយដែលយើងបានធ្វើការផ្លាស់ប្តូរនូវបទពិសោធន៍ដែលប្រជាជាតិខ្មែរយើងទាំងមូលបានឆ្លងកាត់។ ហ៊ុយ បានបញ្ជាក់ថាពេលគាត់ត្រឡប់ទៅវិញ គាត់នឹងយកឯកសារនិងបទពិសោធន៍ដែលបានសិក្សាពីវគ្គបណ្តុះបណ្តាលទៅចែករំលែកដល់សិស្សមិត្តភក្តិនៅសាលា និងនៅក្នុងសហគមន៍របស់គាត់» ។ ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យក្មេងជំនាន់ក្រោយបានដឹងពីសម័យខ្មែរក្រហមដែលបានកើតឡើងរហូតដល់មានការកាប់សម្លាប់ប្រជាជនឯង។ ហ៊ុយ បានបញ្ជាក់ថា ឪពុកម្តាយគាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហមដោយសារអត់អាហារ ។ ចំណែកជីតាត្រូវខ្មែរក្រហមយកទៅសម្លាប់ ហើយគាត់បានក្លាយជាក្មេងកំព្រាចាប់តាំងពីពេលនោះមក ។

**ចាន់ ថាវិទ្ធិ** អាយុ៤១ឆ្នាំ ជាសាស្ត្រាចារ្យមកពីសកលវិទ្យាល័យស្វាយរៀង មានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលធ្វើទុក្ខលើប្រជាជនកម្ពុជា ការស្លាប់បាត់បង់ជីវិត ភាពជូរចត់នៃរបបនេះ និងដើម្បីទប់ស្កាត់កុំឲ្យរបបកើតឡើងសារជាថ្មីម្តងទៀត។ ការបណ្តុះបណ្តាលនេះបានធ្វើឲ្យគាត់ស្គាល់កាន់ច្រើនពីឯកសារ និងស្គាល់អ្នកនៅរស់ (កម្មាភិបាលខ្មែរក្រហម) ។ ថាវិទ្ធ បន្តថា នៅពេលត្រឡប់ទៅវិញគាត់នឹងឆ្លៀតឱកាស ធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហមប្រាប់ទៅដល់សិស្ស និងការកាប់សម្លាប់នៃរបបនេះថាតើវាប៉ះពាល់អ្វីខ្លះដល់ប្រជាជនកម្ពុជា ។ ថាវិទ្ធិ បានរៀបរាប់ថា គាត់មានស្រុកកំណើតនៅស្រុកឈូក ខេត្តកំពត។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគ្រួសារគាត់ឲ្យទៅនៅកំពង់សោម។ បន្ទាប់ពីរបបនេះដួលរលំ ថាវិទ្ធ បានវិលត្រឡប់មករស់នៅស្រុកកំណើតខាងឪពុកនៅខេត្តស្វាយរៀង។ ថាវិទ្ធ បញ្ជាក់ ថា មីង និង អ៊ំប្រុសរបស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។

អ្នកគ្រូ **វ៉ាន់ បូរី** អាយុ៣៨ឆ្នាំ មានស្រុកកំណើតនៅឃុំកំពង់លាវ ស្រុកព្រៃវែង ខេត្តព្រៃវែង ។ បូរី ជាសាស្ត្រាចារ្យនៅវិទ្យាស្ថានខេមរៈសាស្ត្រ ខេត្តព្រៃវែង។ បូរី យល់ថា «វគ្គបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មានសារសំខាន់ណាស់ ព្រោះធ្វើឲ្យគាត់យល់ដឹងពីប្រវត្តិសាស្ត្រនេះ ហើយរូបគាត់ក៏ដូចជាលោកគ្រូ-អ្នកគ្រូមកពីវិទ្យាស្ថាន និងសាកលវិទ្យាល័យផ្សេងៗដែរដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ នឹងយកចំណេះដឹងទាំងអស់ទៅចែករំលែកដល់សិស្សរបស់ខ្លួនរៀងៗខ្លួន។ ការបណ្តុះបណ្តាលនេះ បានផ្តល់ឲ្យសិស្សនូវការចងចាំ និងយល់ដឹងពីព្រឹត្តិការណ៍ក្នុងរបបនោះ ប៉ុន្តែប្រសិនបើយើងមិននិយាយ និងកត់ត្រាទេ រយៈពេល៣០-៥០ឆ្នាំទៀត ក្មេងជំនាន់ក្រោយនឹងមិនជឿថាមានរបបកើតឡើង និងមានការកាប់សម្លាប់នោះទេ។ បូរី បានសំណូមពរឲ្យធ្វើការបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-៧៩ ទៅដល់គ្រប់គ្រឹះស្ថានសិក្សាទាំងអស់ ពិសេសនៅតាមមជ្ឈមណ្ឌលគរុកោសល្យរបស់រដ្ឋ ។

ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ គឺជាឱកាសមួយដ៏សំខាន់ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជីវិត ការងារ វិធីសាស្ត្របង្រៀន និងការពិភាក្សាពីរបបខ្មែរក្រហមក្នុងចំណោមលោកគ្រូ-អ្នកគ្រូមកពីគ្រឹះស្ថានឧត្តមសិក្សា និងសាកលវិទ្យាល័យទូទាំងប្រទេស ។ ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមិនត្រឹមតែជាការចងចាំ និងការយល់ដឹងពីប្រវត្តិរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៅទៀត ការសិក្សានេះក៏ជាដំណើរការនៃការផ្សះផ្សាសម្រាប់ប្រជាជនដែលបានរស់ជីវិត និងជំរុញឲ្យមានការទទួលខុសត្រូវចំពោះរបបនោះផងដែរ ។ **សោម ប៊ុនថន**

# សំណាងមួយ

ចាន់ ហ៊ុនសួ អាយុ៦០ឆ្នាំ ដែលជាកូនទីពីរនៃសមាជិកគ្រួសារប្រាំមួយនាក់ កំពុងអង្គុយម្នាក់ឯងនៅក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រិតការខេត្តកំពង់ឆ្នាំង ។ ពេលសួរថាតើគាត់រស់នៅទីណា? ហ៊ុនសួ ឆ្លើយថា គាត់រស់នៅក្នុងក្រុងកំពង់ឆ្នាំងក្បែរៗនេះតែម្នាក់ឯងទេ ។ ស្ថិតក្រោមម្លប់ដើមប្រេងខ្យល់ព្រមជាមួយនឹងខ្យល់បក់មករំភើយៗនៅក្នុងបរិវេណសាលា ហ៊ុនសួ បានរៀបរាប់ពីដំណើរជីវិតរបស់ខ្លួនក្នុងរបបខ្មែរក្រហមថា មុនឆ្នាំ១៩៧៥ គាត់និងប្អូនប្រុសម្នាក់ទៀតបានមករៀននៅក្រុងភ្នំពេញដោយស្នាក់នៅម្តុំគីឡូម៉ែត្រលេខ៤ ។ ពេលនោះ ហ៊ុនសួ ជានិស្សិតសកលវិទ្យាល័យកសិកម្មចម្ការដូង ។ នៅឆ្នាំ១៩៧៣ ដោយសារសង្គ្រាមខ្លាំងពេកនៅតាមបណ្តាខេត្តមួយចំនួនទើបឪពុកម្តាយបានផ្លាស់មកនៅក្រុងភ្នំពេញ ។ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហ៊ុនសួ ព្រមទាំងគ្រួសារមានគ្នាប្រាំមួយនាក់ក៏មិនខុសពីប្រជាជនកម្ពុជាដទៃទៀតដែរ ត្រូវខ្មែរក្រហមជម្លៀសចេញពីភ្នំពេញដោយបានប្រាប់ថាចេញតែបីថ្ងៃប៉ុណ្ណោះ ។ គ្រួសារបានធ្វើដំណើរឆ្ពោះទៅផ្លូវជាតិលេខ៥ដើម្បីទៅស្រុកកំណើតនៅកំពង់ឆ្នាំងវិញ តែត្រូវយោធាខ្មែរក្រហមប្រាប់ឲ្យទៅផ្លូវខាងកំពង់ចាមវិញ ។ នៅតាមផ្លូវទៅកំពង់ចាម ហ៊ុនសួ បានជួបនឹងអតីតគ្រូម្នាក់ដែលជាយោធាខ្មែរក្រហម ហើយបានប្រាប់គាត់ថា យើងមិនមានពេលត្រឡប់ចូលភ្នំពេញវិញបានទេ ហើយបានផ្តាំផ្ញើថាមករស់នៅតំបន់រំដោះត្រូវប្រយ័ត្ន ជាពិសេសកុំនិយាយផ្តេសផ្តាស និងត្រូវថែរក្សាអំបិលឲ្យគង់ កុំខ្ជះខ្ជាយឲ្យសោះគឺត្រូវសំឡូវសំចៃអំបិលឲ្យមែនទែន ។

ក្រោយមក ដោយឪពុកជាអ្នករកស៊ីធ្លាប់ចេញចូលនិងស្គាល់ពីភូមិសាស្ត្រនៅទីនោះផង ហ៊ុនសួ ក៏បានជួលទូកអ្នកមូលដ្ឋាននៅទីនោះដើម្បីចម្លងមកខាងកំពង់ឆ្នាំងវិញដោយដូរជាមួយនឹងភួយសំឡីមួយ ។ ទៅដល់កំពង់ឆ្នាំង ហ៊ុនសួ និងក្រុមគ្រួសារបានទៅរស់នៅឃុំប្រេះ ។ នៅទីនោះខ្មែរក្រហមប្រមូលឲ្យទៅនៅផ្ទះធំមួយដែលមានសុទ្ធតែប្រជាជនថ្មី ហើយមានឈ្លបដើរធ្វើស្ថិតិគ្រួសារនីមួយៗ ដើម្បីដឹងពីស្ថានភាពគ្រួសារកាលពីជំនាន់ លន់ នល់ ។ ក្រោយមក ប្រជាជនថ្មីទាំងអស់ត្រូវឲ្យទៅនៅសហករណ៍ត្រពាំងញ្ញោ ដែលស្ថិតក្នុងភូមិត្រពាំងញ្ញោ ដោយឡែកតែគ្រួសារ ហ៊ុនសួ និងមួយគ្រួសារទៀតប៉ុណ្ណោះដែលមិនត្រូវបានជម្លៀសទៅជាមួយប្រជាជនទាំងនោះ គឺខ្មែរក្រហមបានឲ្យទៅនៅភូមិត្រពាំងម្អម ដែលស្ថិតនៅឃុំប្រេះ ជាភូមិមូលដ្ឋានចាស់ ។ ដោយពេលនោះជារដូវវស្សាផង ហ៊ុនសួ និងបងស្រីត្រូវបានអង្គការចាត់តាំងឲ្យធ្វើស្រែ ដកស្ទូងក្នុងសហករណ៍ ដោយឡែកឪពុក និងប្អូនប្រុសម្នាក់ទៀត ត្រូវបានខ្មែរក្រហមឲ្យទៅដាំពោត បោចរំពាក់ ។ នៅទីនោះអាចថាជាសំណាងដែរចំពោះ ហ៊ុនសួ ព្រោះថារាល់របស់របរដែលខ្លួនយកទៅជាមួយមានដូចជា អង្ករ អំបិល ប្រេងកាត នោះគឺមិនមានការរឹបអូសទេ ហើយចំពោះអាហារដែលទទួលបានប្រចាំថ្ងៃគឺម្នាក់អង្ករមួយកំប៉ុង និងអំបិលមួយក្តាប់ដែលសហករណ៍បើកឲ្យប្រចាំថ្ងៃ ។ នៅភូមិនោះមានប្រជាជនថ្មីតែពីរគ្រួសារប៉ុណ្ណោះ គឺគ្រួសារ ហ៊ុនសួ និងគ្រួសារកាត់ចិនអ្នកធ្វើគុយទាវ ។ ចំណែកម៉ោងធ្វើការក៏មិនពិបាកណាស់ណាដែរ គឺធ្វើដូចអ្នកមូលដ្ឋានដែរ មិនមានកំណត់ម៉ោងនោះទេ ហើយក្នុងមួយអាទិត្យអង្គការបើកសិទ្ធិឲ្យដើរសេរីមួយថ្ងៃសម្រាប់ប្រជាជននៅក្នុងសហករណ៍ទាំងអស់ ។

ក្រោយមកទៀត ហ៊ុនសួ ត្រូវបានអង្គការចាត់តាំងឲ្យទៅលើកទំនប់ ហើយឪពុកត្រូវចាត់ឲ្យកាប់ព្រៃ និងប្អូនប្រុសត្រូវចាត់ឲ្យទៅនៅខាងកងចល័តត្រពាំងពោធិ៍ ហើយក៏បានបាត់ដំណឹងពីពេលនោះមក ។ ក្រោយពេលត្រឡប់មកពីធ្វើការលើកទំនប់វិញ គ្រួសារ ហ៊ុនសួ មិនមាននរណាជាជំហរទៀតទេ ដោយសារតែឪពុកឈឺជើងនៅពេលដែលទៅកាប់ព្រៃបានមុតបន្លាចំថ្នើមជើង ប្អូនប្រុសក៏ទៅកងចល័តបាត់ បងស្រីមិនសូវមានកម្លាំង ម្តាយឈឺតាំងតែពីពេលជម្លៀសមកម្ល៉េះ និងប្អូនប្រុសអាយុប្រាំមួយឆ្នាំប៉ុណ្ណោះ ចំណែកឯខ្លួនក៏ធ្លាក់ខ្លួនឈឺគ្រុនញាក់ទៀតនៅពេលទៅលើកទំនប់ ។

បន្ទាប់មកទៀត គ្រួសារ ហ៊ុនស្លួ និងគ្រួសារដែលមកជាមួយនោះ ត្រូវអង្គការជម្លៀសទៅភូមិត្រពាំងញ្ញៀវិញ ។ ពេលទៅដល់ទីនោះ ក៏មិនមានការដកហូតនូវស្បៀងឬអ្វីៗដែលខ្លួនមាននោះទេ គឺដក តែវិទ្យុ កង់ នាឡិកាដៃប៉ុណ្ណោះ ប៉ុន្តែរបស់របរហូបចុកអង្គការមិន ដកហូតទេ ដូចជាមាសជាដើម ។ ពេលដែលទៅដល់ទីនោះដោយសារ គ្រុនមិនទាន់ជាផងនោះ ហ៊ុនស្លួ និងឪពុកមិនបានធ្វើការអីទេ ធ្វើតែ ម្តាយនិងបងស្រីប៉ុណ្ណោះ ហើយរបបអាហារដែលទទួលបាននោះ ថយបន្តិចចំពោះប្រជាជនថ្មីបានតែកន្ទះកំប៉ុងប៉ុណ្ណោះក្នុងមួយថ្ងៃ សម្រាប់ម្នាក់ ។

ក្រោយពីបានជាសះស្បើយពីជំងឺ ហ៊ុនស្លួ និងបងស្រីត្រូវ បានអង្គការចាត់តាំងទៅក្នុងកងចល័តឃុំ បន្ទាប់មកទៅចល័ត ស្រុក ។ ថ្ងៃមួយនោះ ហ៊ុនស្លួ បានជំទាស់នឹងប្រធានកងមិនទៅ ធ្វើការដោយហេតុថាប្រធានកងមិនអនុញ្ញាតឲ្យខ្លួនទៅមើលបង ស្រីឈឺដោយសារពុលមើមក្តួចនៅពេទ្យ ។ នៅពេលយប់នោះ ហ៊ុនស្លួ ត្រូវបានមេកងចាត់តាំងឲ្យទៅកងចល័តតំបន់វិញ ដោយ កងចល័តតំបន់នេះរើសយកតែប្រជាជនថ្មីសុទ្ធសាធ ពេលនោះ ហ៊ុនស្លួ គិតថាប្រហែលជាគេយកខ្លួនទៅសម្លាប់ហើយ ព្រោះកាល ពីថ្ងៃខ្លួនបានប្រឆាំងជាមួយមេកង ។ ពេលនោះមេកងប្រាប់ ហ៊ុនស្លួ ថា «ឯងទៅតំបន់ ដឹងគ្នាហើយ» ។ បន្ទាប់មក ហ៊ុនស្លួ បានធ្វើដំណើរ មកជាមួយក្រុមកងរបស់ខ្លួនដែលមានសមាជិកទាំងប្រុសទាំងស្រី ប្រហែល១០០នាក់ មកដល់ភូមិគ្រួសជើងគ្រៀវ ដោយនៅទីនោះ មានអ្នកដែលមកពីកងផ្សេងៗទៀតក្នុងតំបន់មកប្រជុំគ្នា មានភ្លើង អគ្គិសនី ហើយទ័ពខ្មែរក្រហមទាំងនោះមានការរួសរាយរាក់ទាក់ ទទួល ហើយថែមទាំងបានដាំបាយឲ្យហូបដោយសេរីទៀតផង ។ ហ៊ុនស្លួ គិតក្នុងចិត្តថា បើគេយកមកសម្លាប់ទេ ហេតុអ្វីមកដល់ ហ្នឹងគេបែរជាស្វាគមន៍យើងហើយធ្វើម្ហូបឲ្យញ៉ាំទៅវិញ? ហ៊ុនស្លួ នៅចាំបានថា ពេលនោះគេបានធ្វើខសាច់ជ្រូកឲ្យហូប ហើយមនុស្ស មួយចំនួនបានស្លាប់ដោយសារហល់បាយនៅពេលនោះក៏មាន ។

ក្រោយមក ហ៊ុនស្លួ ត្រូវចាត់ចូលទៅកងរយនៃស្រុក១៨ ដោយនៅទីនោះគេឲ្យធ្វើស្រែ ហើយម៉ោងការងារគឺមានការកំណត់ ផងដែរ ដោយព្រឹកពីម៉ោង៦រហូតដល់ម៉ោង១១និងថ្ងៃម៉ោង ២រសៀលរហូតដល់ម៉ោង៥ល្ងាច ។ ចំពោះការហូបចុកនៅទីនោះ មិនសូវពិបាកនោះទេគឺក្នុងម្នាក់កន្ទះកំប៉ុង ដោយរាល់សម្ភារដូចជា ចាន ស្លាបព្រា ម្ហូបអាហារគឺចុងភៅជាអ្នកចាត់ចែងទាំងអស់ ហើយនៅរដូវដកស្ទូងក៏ហូបបបរទៅពេលដែលច្រូតកាត់ហើយក៏ ហូបបាយទៅតាមខែផងដែរ ។ ចំពោះការងារនៅកងចល័តទៀត គឺមិនមានការបង្ខំ ឬដាក់កំហិតឲ្យធ្វើនោះទេ ត្រូវធ្វើរួមទាំងអស់ គ្នាតែម្តង មិនមែនកំណត់ដូចនៅក្នុងសហករណ៍នោះទេ ។ នៅក្នុង ឆ្នាំ១៩៧៧ កងចល័តរបស់ ហ៊ុនស្លួ ក៏ដូចជាកងចល័តដទៃទៀត ត្រូវបានអង្គការចាត់តាំងទៅនៅខាងចល័តកោះបូរណ៌ ស្រុកកំពង់ លែង ។ នៅទីនោះ មានការដ្ឋានធំមួយគឺធ្វើការលើកកាត់ស្ទឹងជីនិត ដែលភ្ជាប់ពីកំពង់ឆ្នាំងទៅខេត្តកំពង់ធំ ។ ក្រោយពីនៅការដ្ឋាន នោះបានប្រមាណមួយខែ ដោយការងារនៅទីនោះបរាជ័យហើយ ក្រុមកងចល័តតំបន់ត្រូវបានអង្គការតិះទៀនថាធ្វើការខ្ជីខ្ជាមិន គ្រប់តាមផែនការរបស់អង្គការនោះ អង្គការមានផែនការរំសាយ កងចល័តតំបន់ឲ្យចូលសហករណ៍វិញ ហើយ ហ៊ុនស្លួ ត្រូវបាន បញ្ជូនមកនៅខាងកងមាសវិញ ។ ប៉ុន្តែដូចជាសំណាងដែរកង ចល័តរបស់ ហ៊ុនស្លួ មិនត្រូវបានគេរំសាយទេ អង្គការបានដាក់ ឲ្យចូលធ្វើជាកងចល័តស្រុក១៨វិញ ។ នៅទីនោះគេបែងចែកជាពីរ កងទៀតគឺកងធ្វើនៅសហករណ៍កងមាសនិងមួយកងទៀតទៅដាំ ដំឡូងនៅជើងភ្នំដើមផ្កា ។ តាមពិត ហ៊ុនស្លួ នៅសហករណ៍កងមាស ទេ តែដោយសារតែទៅធ្វើការថ្ងៃដំបូង ច្រូតស្រូវក្នុងទឹកត្រូវខ្យង សោករោលដៃឡើងហើម ពេលប្រជុំកងយប់ឡើងដែលមានកង ដាំដំឡូងផងនោះ ហ៊ុនស្លួ ត្រូវបានស្រីម្នាក់ដែលជាអ្នកស្គាល់គ្នា បានហៅឲ្យទៅធ្វើនៅកងគេវិញ ហើយក៏ចូលទៅបន្ទំគេនៅពេល នោះទៅ ។ នៅសហករណ៍ជើងភ្នំដើមផ្កានោះ មានប្រធានកង ឈ្មោះ ពុំ ។

ហ៊ុនស្លួ បាននិយាយថា ពុំ នេះជាមនុស្សល្អ ។ ហ៊ុនស្លួ ធ្លាប់ បានសុំគាត់មកលេងម្តាយបានម្តង មិនត្រឹមតែគាត់អនុញ្ញាតឲ្យទេ ថែមទាំងបានចេញលិខិតដើរផ្លូវទៀតផង ។ ការហូបចុកនៅ សហករណ៍នៅភ្នំដើមផ្កានោះមិនមានការលំបាកទេដោយសារ អាហារហូបចុកគឺសហករណ៍ត្រូវរកដើម្បីផ្គត់ផ្គង់ខ្លួនឯងដែល ពេលនោះគេហៅថា ការធ្វើជាសហករណ៍ស្វយ័ត ។ ដោយពេល នោះមានការបែងចែកជាកងដូចជាបុរសៗទៅឡើងត្នោតដើម្បីធ្វើ

ស្កូរ នារីៗដាំបន្លែ កងទាក់ជ្រូកព្រៃដើម្បីធ្វើម្ហូប និងកងរកថ្នាំដើម្បីទុកព្យាបាលអ្នកនៅសហករណ៍មួយក្រុមទៀតធ្វើស្រែវស្សា និងមួយក្រុមទៀតដាំដំឡូង ហើយ ហ៊ុនស្លួ ស្ថិតនៅក្រុមដាំដំឡូង ។ នៅទីនោះ ក្រុមនីមួយៗធ្វើការតាមទិសដៅរៀងៗខ្លួនដោយមិនមានការបង្ខំអ្វីទេ ហើយនៅពេលយប់ក៏មានការរាំច្រៀងលេងកំសាន្តផង បន្ទាប់ពីសម្រាកពីការងារដែលរយៈកាលនោះក្នុងឆ្នាំ១៩៧៨ ។ នៅឆ្នាំដដែល ពេលដែល ពុំ មិននៅខាងមន្ទីរសន្តិសុខ ក៏បានមកស្នើយកកងរបស់ ហ៊ុនស្លួ ទៅជួយច្រូតស្រូវទំពាំ តាមពិតគឺជាចេតនាយកទៅសម្លាប់ប៉ុណ្ណោះ ។ ពេលនោះ ប្រធានកងហាបានអនុញ្ញាតឲ្យគេយកទៅ តែទៅដល់ទីនោះគេបានឲ្យធ្វើការជាទម្ងន់ដោយឲ្យទៅច្រូតស្រូវក្នុងទឹកនៅព្រៃជ្រៅ ។ មួយរយៈក្រោយមក ពុំ បានដឹងរឿងនេះក៏បានទៅចរចាសុំយកបានមកវិញ ហើយជីវិតរបស់ ហ៊ុនស្លួ និងអ្នកឯទៀតក៏បានរស់រៀនពីពេលនោះមក ។

រហូតដល់ថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ទោះបីជាវៀតណាមបានវាយរំដោះបានទីក្រុងភ្នំពេញនិងមួយភាគធំនៃផ្ទៃប្រទេសក៏ដោយ ប៉ុន្តែនៅតំបន់ដែល ហ៊ុនស្លួ រស់នៅមិនទាន់បានរំដោះនៅឡើយទេ គឺរំដោះបានតែផ្នែកខ្លះប៉ុណ្ណោះ នៅខែមេសា ឆ្នាំ១៩៧៩ ទើបវៀតណាមបានរំដោះបាន ហើយ ហ៊ុនស្លួ ក៏បានមករកគ្រួសារឃើញវិញនៅសាលាលេខ៥ ប៉ុន្តែជាអកុសលឪពុករបស់គាត់បានស្លាប់តាំងពីឆ្នាំ១៩៧៧ មកម៉្លេះដោយសារតែអត់អាហារ និងប្អូនប្រុសបាត់ខ្លួនតាំងពីពេលដែលចូលធ្វើកងចល័តមក ដូច្នេះគ្រួសារ ហ៊ុនស្លួ ពីមុនមានសមាជិកប្រាំនាក់ ពេលនេះនៅសល់តែបួននាក់ប៉ុណ្ណោះ មានម្តាយ បងស្រី ប្អូនប្រុស ។

ចាន់ ហ៊ុនស្លួ ជីវិតរស់នៅក្នុងរយៈបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ អាចចាត់ទុកថាជាសំណាងមួយដោយសារតែមិនសូវជួបប្រទះនឹងការលំបាកវេទនាខ្លាំងពេកនោះទេ ចំពោះការហូបចុក ក៏មិនសូវពិបាក ការងារទៀតសោធក៏មិនធ្ងន់ធ្ងរប៉ុន្មានដែរ បើធៀបនឹងទុក្ខលំបាករបស់ប្រជាពលរដ្ឋខ្មែរដទៃទៀត ជាពិសេសតែងតែជួបមនុស្សដែលល្អៗមានចិត្តមេត្តា ដាក់ស្តែងដូចជាប្រធានកងឈ្មោះ ពុំ ជាដើម ។ តែរឿងរ៉ាវនៃការព្រាត់ប្រាស់គ្រួសារដោយសារតែរបបនេះគឺវាបានស្ថិតនៅក្នុងចិត្ត ហ៊ុនស្លួ ជានិច្ច ។

**ឆាវ សារ:មុនិន្ទ**

# គេហទំព័រឃ្លាំមើលតុលាការខ្មែរក្រហម

គម្រោងឃ្លាំមើលតុលាការខ្មែរក្រហម ផ្តោតទៅលើការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីផ្តល់ឱកាសឲ្យសាធារណជនទូទៅអាចទទួលបានព័ត៌មានថ្មីៗ និងទាន់ហេតុការណ៍ អានឯកសាររបស់សាលាក្តីខ្មែរក្រហម ទស្សនាវីដេអូខ្លីៗ និងតាមដានប្រភពព័ត៌មានផ្សេងទៀតអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.cambodiatribunal.org ផ្ទុកព័ត៌មានអំពីរឿងរ៉ាវដែលបានកើតឡើងនិងកំពុងដំណើរការ នៅសាលាក្តីខ្មែរក្រហម ។ សវនាការបុរេជំនុំជម្រះ ដំណើរការកាត់ទោស និងព័ត៌មានផ្សេងទៀតអាចរកបាននៅក្នុងគេហទំព័រនេះ ។

នាពេលបច្ចុប្បន្ននេះ គម្រោងឃ្លាំមើលតុលាការខ្មែរក្រហមកំពុងធ្វើការជាមួយសាកលវិទ្យាល័យចំនួន៨២ក្នុងរាជធានីភ្នំពេញ ដើម្បីផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងផ្តល់ព័ត៌មានទាន់ហេតុការណ៍ថ្មីៗអំពីដំណើរការសាលាក្តីខ្មែរក្រហមដល់និស្សិត ។ គោលបំណងនៃគម្រោងនេះគឺដើម្បីស្តាប់ប្រតិកម្មពីនិស្សិតទាក់ទងនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងដើម្បីលើកទឹកចិត្តនិស្សិតសាកលវិទ្យាល័យឲ្យកាន់តែសកម្មឡើងក្នុងការជជែកជាមួយឪពុកម្តាយ និងជីដូនជីតារបស់ខ្លួនទាក់ទងនិងរបបខ្មែរក្រហម ។ និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហមគឺនិយាយពីការផ្សះផ្សា អប់រំកូនចៅ អត់ឱន អធ្យាស្រ័យគ្នា ។

ព័ត៌មានបន្ថែមទាក់ទងនឹងកម្មវិធីផ្សព្វផ្សាយតាមសាកលវិទ្យាល័យនានា សូមទាក់ទង វ៉ាន់ថាន់ ពៅដារ៉ា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៤៦ ៥២៦ ។



# អ្នកទោសគុកខ្មែរក្រហម

នៅក្នុងវេទិកាបង្រៀនទាក់ទងនឹងការអប់រំពីអំពើប្រល័យពូជសាសន៍ ស៊ឹម កែវ គ្រេកអរជាខ្លាំងដែលសិស្សានុសិស្សក៏ដូចជាប្រជាជននៅក្នុងភូមិរបស់គាត់បានដឹងពីឆាកជីវិតដែលបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម និងអារម្មណ៍ដែលបានលាក់ទុកជាយូរមកហើយចាប់តាំងពីរបបនេះដួលរលំ ។ កែវ និយាយបណ្តើរយំបណ្តើរពេលនឹកឃើញដល់ទង្វើដែលខ្មែរក្រហមប្រព្រឹត្តមកលើគាត់នៅពេលដែលគាត់សន្លប់បាត់ស្មារតី ។

កែវ រៀនបានត្រឹមថ្នាក់ទី៩នៅសាលាបាក់ទូក រួចក៏បានឈប់រៀន ព្រោះស្រុកកើតចលាចល ។ បន្ទាប់មក កែវ ក៏បានចូលធ្វើការនៅក្នុងរោងចក្រមួយដែលមានកម្មករសរុបទាំងអស់ប្រហែល៧០-៨០នាក់ ដោយគាត់ទទួលបានប្រាក់កម្រៃ២០រៀលក្នុងមួយខែ ។ នៅឆ្នាំ១៩៦៨ កែវ បានរៀបការតាមការរៀបចំរបស់ឪពុកម្តាយ ។ មួយឆ្នាំក្រោយមក កែវ សម្រាលបានកូនប្រុសម្នាក់ ប៉ុន្តែបានស្លាប់ទៅវិញ ដោយសារតែកើតជំងឺ ។ នៅឆ្នាំ១៩៧០ គាត់កើតបានកូនស្រីម្នាក់ទៀត ។

នៅឆ្នាំ១៩៧៣ ដោយសារតែមានការប្រយុទ្ធគ្នាខ្លាំងរវាងកងយោធាខ្មែរក្រហម និង លន់ នល់ ព្រមទាំងរោងចក្របានបិទទ្វារ កែវ បានឈប់ធ្វើការ រួចត្រឡប់មករស់នៅម្តុំស្ពានទូតចិនជាមួយប្តីរបស់គាត់វិញ ។ នៅឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមចូលមកកាន់កាប់ទាំងស្រុង គាត់និងក្រុមគ្រួសារត្រូវបានជម្លៀសឲ្យទៅរស់នៅបឹងស្នោ ។ រស់នៅទីនោះបានមួយខែ គាត់ត្រូវបានជម្លៀសបន្តឲ្យមករស់នៅតាមដងទន្លេវិញ ។ ដោយសារទឹកស្រុកកំណើតខ្លាំងពេក គ្រួសាររបស់ កែវ ក៏នាំគ្នាលួចធ្វើដំណើរត្រឡប់មកវិញ ដោយប្តីរបស់គាត់ធ្វើក្បូនមួយឲ្យគាត់ កូនបីនាក់ និងម្តាយរបស់គាត់ជិះលើក្បូននោះ ចំណែកប្តីគាត់រុញក្បូននោះរហូតដល់ត្រើយ ។ ពេលទៅដល់វត្តមួយ ខ្មែរក្រហមបានចាត់តាំង

ឲ្យគាត់កិនស្រូវនិងធ្វើស្រែ ។ ចំណែកកូនរបស់គាត់ដែលនៅបៅដោះត្រូវបញ្ជូនឲ្យទៅកងយាយៗមើលថែទាំ និងកូនពីរនាក់ទៀតទុកចោលនៅផ្ទះ ។

ដោយសារតែធ្វើការនឿយហត់ និងហូបមិនគ្រប់គ្រាន់មួយរយៈក្រោយមក ម្តាយរបស់គាត់ក៏កើតជំងឺហើមរហូតបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ ពេលនោះ កែវ ក៏មិនដឹងថាម្តាយរបស់គាត់សម្រាកនៅមន្ទីរពេទ្យណានោះដែរ ព្រោះពេលដែលសួរទៅ អង្គការតែងតែប្រាប់ថា យកទៅពេទ្យលើហើយ (រហូតដល់បច្ចុប្បន្ននេះគាត់មិនដឹងថាម្តាយរបស់គាត់ស្លាប់នៅទីណាទេ) ។ ក្រោយមក កែវ បានទទួលដំណឹងពីអ្នកធ្វើការក្នុងកងជាមួយគ្នាថា ម្តាយរបស់គាត់បានសុំអំបិលខ្មែរក្រហមហូប ។ ដោយសារតែខឹងនឹងខ្មែរក្រហមដែលបដិសេធមិនឲ្យអំបិល ម្តាយរបស់គាត់ក៏និយាយទៅបុគ្គលិកពេទ្យថា «ពេទ្យអីក៏ចិត្តអាក្រក់សាហាវឃោរឃៅម្ល៉េះ?» ការដែលហ៊ាននិយាយបែបនេះ ខ្មែរក្រហមក៏បានសម្លាប់គាត់ដោយចាក់ទឹកចូលក្នុងខ្លួនរបស់គាត់ ។

ក្រោយពីម្តាយរបស់ កែវ ស្លាប់មិនទាន់បានប៉ុន្មានផង កូនរបស់គាត់ក៏ស្លាប់ទៀត នៅសល់តែកូនស្រីម្នាក់ប៉ុណ្ណោះ ។ កែវ បានរៀបរាប់ឲ្យដឹងថា កូនស្រីនោះគាត់គ្មានសង្ឃឹមថានឹងបានរស់ទេ ព្រោះពេលដែលក្អកម្តងៗចេញសុទ្ធតែឈាម ។ ខ្មែរក្រហមបានឲ្យថ្នាំអាចម៍ទន្សាយទៅកូនរបស់ កែវ លេប ប៉ុន្តែថ្នាំទាំងនេះមិនបានជួយអ្វីទាំងអស់ ។ ក្រោយមក យាយៗដែលនៅកងជាមួយគាត់បានប្រាប់ឲ្យគាត់យកស្ករឲ្យហូបទើបបានជាសះស្បើយ ។

នៅចុងឆ្នាំ១៩៧៦ ក្រុមគ្រួសាររបស់ កែវ ស្រាប់តែចង់ធ្វើដំណើរទៅរស់នៅតំបន់៣៣វិញ ។ ដោយសារតែតំបន់៣៣ទទួលបាន១៤០គ្រួសារដែលអនុញ្ញាតឲ្យរស់នៅតំបន់នេះហើយ ដូច្នេះឈ្លបខ្មែរក្រហមបានបដិសេធមិនទទួលគ្រួសាររបស់គាត់ឲ្យរស់នៅទេ ត្រូវតែបញ្ជូនគ្រួសារគាត់ឲ្យមករស់នៅតំបន់២៥វិញ ។ ពេលដែលធ្វើដំណើរត្រឡប់មកកងវិញ មេកងក៏បានយកគាត់ ប្តី និងកូនយកទៅដាក់គុក ដោយចោទថាដើរសេរីគ្មានច្បាប់អនុញ្ញាត ។ ពេលនោះ កែវ មានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំង ព្រោះមិនដឹងខ្មែរក្រហមសម្លាប់គាត់ ឬធ្វើទារុណកម្មគាត់បែបណានោះទេ ។ កែវ បានរៀបរាប់ឲ្យដឹងថា គុកនោះមានលក្ខណៈជាផ្ទះក្បឿងមួយផងដីគឈើង គ្មានពន្លឺថ្ងៃទេ ដោយអាចមើលឃើញគ្នាតែព្រលប់ៗប៉ុណ្ណោះ ។ ពេលថ្ងៃ កែវ ត្រូវបានចាត់តាំងឲ្យចេញមកខាងក្រៅដើម្បីដាំខ្ទឹមក្រហម ចំណែកប្តីត្រូវដាក់ច្រវាក់ជើងបណ្តើរចេញទៅធ្វើការតាំងពីព្រឹកព្រលឹម ។ ក្នុងចំណោមអ្នកទោសប្រហែល៣៨-៤០នាក់ ដែលភាគច្រើនត្រូវបានដាក់ច្រវាក់ជើង កែវ ជាអ្នកទោសសំណាងជាងគេ ព្រោះរយៈពេលដប់ថ្ងៃក្រោយមកគាត់ត្រូវបានដោះលែងឲ្យមានសេរីភាពដោយសារតែគាត់ខិតខំធ្វើការបម្រើអង្គការ ទោះបីជាការងារនោះធ្ងន់ដែលស្ត្រីធម្មតាមិនអាចធ្វើបានក៏ដោយ ។ ប៉ុន្តែការខិតខំនេះបានត្រឹមតែឲ្យគាត់រួចខ្លួនប៉ុណ្ណោះ ចំណែកប្តីរបស់គាត់នៅជាប់ឃុំដដែល ។ ដោយសារតែមូលហេតុនេះ កែវ មិនព្រមចាកចេញពីគុកទេ ថែមទាំងតវ៉ាជាមួយប្រធានកងទៀតថា «ទោសកំហុសនេះដាក់លើប្តីខ្ញុំអត់បានទេ ព្រោះខ្ញុំជាអ្នកនាំប្តីរបស់ខ្ញុំរត់ ប្រសិនបើចង់ធ្វើទោសពៃរ៍អី សូមធ្វើមកលើខ្ញុំចុះ» ។ ទោះបីជាតវ៉ាយ៉ាងណាក៏ដោយ ប្រធានកងបានឆ្លើយថា «មិត្តឯងមិនបាច់តវ៉ាទេ សហករណ៍មិត្តឯងទទួលស្គាល់ឲ្យមិត្តឯងចេញទៅ កុំឲ្យមានបញ្ហាអី» ។ ដោយមិនដឹងជាធ្វើយ៉ាងណាដើម្បីឲ្យគាត់ត្រឡប់ទៅកងវិញ កងឈ្លបតូចៗបានចាប់កូនតូចរបស់គាត់យកទៅដាក់សហករណ៍វិញ ។ កែវ មានការពិបាកជាខ្លាំង ព្រោះម្ខាងកូន និងម្ខាងទៀតប្តី ។ បន្ទាប់មកគាត់សម្រេចចិត្តបោះបង់ចោលប្តីសិន រួចត្រឡប់ទៅរកកូននៅសហករណ៍ ។ រយៈពេលប្រាំថ្ងៃក្រោយមកទៀត ប្តីរបស់គាត់ត្រូវបានដោះលែងដែរ ។

រស់នៅជាមួយគ្នាបានមួយរយៈ អង្គការបានបំបែក កែវ ប្តីនិងកូនឲ្យធ្វើការផ្សេងពីគ្នាទៀត ។ កែវ បានរៀបរាប់ទាំងទឹកមុខស្រងូតស្រងាត់ថា «ចាប់តាំងពីប្តីរបស់ខ្ញុំត្រូវបញ្ជូនឲ្យទៅធ្វើការនៅតំបន់ឆ្ងាយ ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ ។ ខ្ញុំបានព្យាយាមសួរប្រធានកងថាតើស្វាមីប្តីរបស់ខ្ញុំទៅណាដែរ ប៉ុន្តែចម្លើយដែលទទួលបានគឺស្មើទៅកាប់ពោតនៅបឹងខ្សាក (យកទៅសម្លាប់)» ។ ក្រោយមក កែវ បានដឹងដំណឹងតាមរយៈមិត្តភក្តិរបស់គាត់ដែលជាប់នៅគុកសង់ទន្លេបាទីបានប្រាប់គាត់ថាស្លាប់បាត់ហើយ ។ ពេលដែលឮហើយ កែវ ពិបាកចិត្តជាខ្លាំង ។ ចំណែកឯកូនវិញ

កែវ ក៏មិនបានទៅមើលថែដែរ ដោយពេលកូនរបស់គាត់រត់មកជួបគាត់ម្តងៗ គាត់មិនដែលមានអ្វីឲ្យកូនហូបនោះទេរហូតដល់ប្រធានកងស្តីបន្ទោសឲ្យគាត់ថា «ចុះមិត្តឯងមិនគិតរកបាយឲ្យកូនហូបផង» ។ ដោយសារតែចង់ឲ្យអង្គការទុកចិត្ត កែវ បានឆ្លើយថា «ទោះបីខ្ញុំជាម្តាយបង្កើតរបស់វាមែនពិត តែកូននេះជាកូនរបស់អង្គការ ប្រសិនបើខ្ញុំហ៊ានលួចបាយឲ្យកូនរបស់អង្គការ ខ្ញុំនឹងមានទោសជាមិនខាន ។ ខ្ញុំធ្វើបែបនេះគឺដើម្បីឲ្យកូនរបស់អង្គការល្អ ខ្ញុំចង់ឲ្យកូនរបស់អង្គការទៅអង្គភាពវិញ» ។

ក្រោយពីប្តីរបស់គាត់ស្លាប់ ខ្មែរក្រហមបានបង្ខំឲ្យគាត់រៀបការជាមួយបុរសដែលគាត់មិនស្គាល់ទាល់តែសោះ ។ ដោយសារតែ កែវ ហ៊ានបដិសេធនឹងការសម្រេចរបស់អង្គការ ប្រធានកងបានដាក់ទណ្ឌកម្មគាត់ឲ្យកាប់ដី និងធ្វើស្រែបីហិកតាតែម្នាក់ឯង ។ ប៉ុន្តែ កែវ មិនត្រឹមតែមិនប្រឆាំងទេ ថែមទាំងប្តេជ្ញាចំពោះអង្គការថា «យើងអ្នកធ្វើការបម្រើអង្គការ កុំថាបីហិកតា ដប់ហិកតាក៏បានដែរ ឲ្យតែអង្គការយល់ព្រម» ។

ដោយសារតែពិបាកចិត្ត និងធ្វើការអស់កម្លាំងខ្លាំងពេក កែវ ក៏បានធ្លាក់ខ្លួនឈឺរហូតដល់សន្លប់នៅកន្លែងធ្វើការ ។ ពេលនោះ អង្គការមិនជឿថាគាត់សន្លប់នោះទេ បែរជាគិតថាគាត់ឈឺពុតទៅវិញ ហើយក៏បានយកលាមកមកញាត់មាត់របស់គាត់រួចចោទថា គាត់មានជំងឺសតិអារម្មណ៍ ។ ដោយសារតែគាត់ពិតជាឈឺមែន អង្គការបានរកថ្នាំមកចាក់ឲ្យគាត់រហូតដល់គាត់ដឹងខ្លួនវិញ ។ កែវ ពិតជាមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងមិនគួរខ្មែរក្រហមធ្វើបែបនេះចំពោះគាត់ទេ ព្រោះគាត់ខិតខំបម្រើអង្គការយ៉ាងអស់ពីកម្លាំងកាយកម្លាំងចិត្ត ប៉ុន្តែបែរជាទទួលបាននូវការប្រព្រឹត្តបែបនេះទៅវិញ ។

កែវ មិនដែលសប្បាយចិត្តទេ ព្រោះពីមួយថ្ងៃទៅមួយថ្ងៃឃើញតែបាត់សមាជិកពីកង បើមិនអ៊ីចឹងទេយកទៅសម្លាប់តែម្តង ដោយគាត់បានឃើញខ្មែរក្រហមសម្លាប់នារីម្នាក់នៅពេលដែលគាត់ទៅកាប់រណ្តៅបេក ។ នារីនោះគឺជាអ្នកចិញ្ចឹមមាន់ ហើយគាត់ត្រូវបានអង្គការយកទៅសម្លាប់ចោល ដោយសារតែបានលួចកាប់មាន់លើសពីមួយដែលអង្គការអនុញ្ញាតឲ្យ ។ ក្រោយពេលដែលនារីនោះស្លាប់ កូនតូចរបស់គាត់ក៏ត្រូវយកទៅសម្លាប់ដែរ ។ ចំណែកអ៊ំស្រីម្នាក់ទៀតឈ្មោះ ស៊ុំ ក៏ត្រូវអង្គការយកទៅសម្លាប់ដែរ ដោយសារតែគាត់ខ្ជិលធ្វើការ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ កែវ រែកអីវ៉ាន់ផង និងដឹកដៃកូនម្នាក់មកជាមួយ ។ ការធ្វើដំណើរនេះគឺពោរពេញទៅដោយភាពសប្បាយចិត្តផងនិងអារម្មណ៍កើតទុក្ខផង ព្រោះនឹកឃើញដល់ម្តាយ ប្តី និងកូន ដែលធ្វើដំណើរទៅមានគ្នាច្រើននាក់ ពេលត្រឡប់មកវិញមានតែពីរនាក់ប៉ុណ្ណោះ ។

បទពិសោធន៍ដែល កែវ បានឆ្លងកាត់បានធ្វើឲ្យគាត់ចងចាំជានិច្ច ហើយតែងតែយករឿងនេះប្រាប់កូនចៅរបស់គាត់ឲ្យដឹង ព្រោះវាជាផ្នែកមួយដែលអាចអប់រំឲ្យកូនរបស់គាត់ ឬក្មេងជំនាន់ក្រោយឲ្យដឹងពីរបបនេះ ហើយនាំគ្នាសិក្សា និងទប់ស្កាត់មិនឲ្យកើតមានរបបប្រល័យពូជសាសន៍ម្តងទៀត តាមរយៈការរៀនអត់ឱន និងអធ្យាស្រ័យគ្នាទៅវិញទៅមកឆ្ពោះទៅរកការកសាងសង្គមដ៏ល្អមួយ ។

**គាត លក្ខិណា**



លោកយាយ ស៊ឹម កែវ មានអារម្មណ៍រំជើបរំជួល

# ញឹក ឈុនឆាត : ក្មេង១៧មេសា

នៅក្នុងត្រកូលកសិករ ញឹក ឈុនឆាត ហៅ ហាក់ ជាកូនប្រុសតែម្នាក់ក្នុងចំណោមបងប្អូនទាំងអស់ដែលបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់ជាងគេ ។ ឆាត មានបងប្អូនប្រាំមួយនាក់ (ស្រីពីរប្រុសបួន) ហើយគាត់ជាកូនពៅគេ ។

ឆាត នៅចាំថា សភាពការណ៍មានការជ្រួលច្របល់យ៉ាងខ្លាំងពេលគាត់កំពុងរៀនថ្នាក់ទីបួននៅអនុវិទ្យាល័យសង្គមរាស្ត្រនិយម ព្រោះកងយោធាខ្មែរក្រហមបានចូលមកដល់ភូមិរបស់គាត់ ។ ប្រជាជនមានការភិតភ័យយ៉ាងខ្លាំង គ្រួសារខ្លះបាននាំគ្នារត់ចូលព្រៃ ហើយខ្លះទៀតបានភៀសខ្លួនទៅនៅភូមិផ្សេង ។

មួយរយៈខ្លីក្រោយមក សភាពការណ៍មានការប្រែប្រួលកាន់តែខ្លាំង ព្រោះយោធាខ្មែរក្រហមបានវាយដណ្តើមកាន់កាប់ទីប្រជុំជន និងស្រុកជាច្រើនដូចជា ស្រុកព្រៃឈរ ជើងព្រៃ និងស្រុកបាធាយ ។ ខណៈនោះ ដោយសារឪពុកម្តាយ ឆាត ស្រឡាញ់ចូលចិត្តអ្នករៀនសូត្រនិងចង់ឲ្យកូនមានចំណេះវិជ្ជាខ្ពង់ខ្ពស់ទើបគាត់ទាំងពីរនាក់ពិភាក្សាគ្នាដើម្បីឲ្យ ឆាត បានរៀនបន្តទៀត ។ បន្ទាប់មក ឪពុកម្តាយ ឆាត ក៏សម្រេចចិត្តបញ្ជូនគាត់ឲ្យទៅបន្តការសិក្សានៅទីក្រុងភ្នំពេញ ។

ឆាត បានចូលរៀននៅវិទ្យាល័យទួលស្វាយព្រៃ ដោយមកស្នាក់នៅជាមួយបងស្រីដែលមានប្តីជាមន្ត្រីនៅក្នុងរបប លន់ នល់ ។ ប៉ុន្តែក្រោយមក ដោយសារជីវភាពគ្រួសាររបស់បងស្រីជួបការលំបាក និងខ្វះខាត ទើប ឆាត សម្រេចចិត្តចេញទៅរស់នៅជាមួយបងស្រីធម៌ម្នាក់ឈ្មោះ ស៊ិន ហៅ ម៉ៅ នៅក្បែរផ្សារក្បាលមាន់ថែ ។ ឆាត បានចូលរៀនថ្នាក់ទី៣ ហើយគាត់បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ។

នៅអំឡុងពេលនោះ ឆាត នៅចងចាំថា យោធាខ្មែរក្រហមបានផ្លោងគ្រាប់ចូលមកភ្នំពេញរៀងរាល់ថ្ងៃ និងគ្រាប់មួយចំនួនធ្លាក់នៅម្តុំបឹងសាឡាងបណ្តាលឲ្យឆេះផ្ទះនិងរបួសប្រជាជនជាច្រើននាក់ ។ ប្រជាជនកាន់តែភ័យខ្លាចថែមទៀត ពេលយោធាខ្មែរក្រហមវាយចូលតាមបណ្តោយផ្លូវជាតិលេខ៤ជិតដល់ទីក្រុងភ្នំពេញហើយ ។ ឆាត ឃើញយុវជនជាច្រើននៅសាលាជួបប្រជុំគ្នានៅសាលធំមួយក្នុងសាលា ហើយរយៈពេលមួយសប្តាហ៍ក្រោយមកក្រុមយុវជនទាំងនោះបាននាំគ្នាធ្វើបាតុកម្ម ។ ឆាត មិនបានចូលរួមក្នុងបាតុកម្មទេ ហើយការរៀនសូត្ររបស់គាត់ក៏មិនបានទៀងទាត់ដែរព្រោះសភាពការណ៍កំពុងច្របូកច្របល់ ។

ឆាត ក៏ដូចជាក្មេងដទៃទៀតដែរអ៊ីដែលមិនអាចបំភ្លេចបានគឺពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥ យុវជននិងយុវនារីលេងបោះអង្គុញនិងចោលឈូងជាមួយបងប្អូននិងមិត្តភក្តិយ៉ាងសប្បាយរីករាយ ។ នៅយប់ថ្ងៃដដែល ឆាត និងសមាជិកគ្រួសារបងស្រីធម៌របស់គាត់បាននាំគ្នាអង្គុយលេងនិងស្តាប់វិទ្យុដែលផ្សព្វផ្សាយពីសភាពការណ៍ក្នុងប្រទេស ។ មួយរយៈក្រោយមក ឆាត បានឮសូរគ្រាប់កាំភ្លើងយ៉ាងកងរំពងពីទិសខាងលិចធ្វើឲ្យគាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ រហូតដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ឆាត ឃើញយន្តហោះជាច្រើនគ្រឿងហោះពីលើទីក្រុងភ្នំពេញបណ្តាលឲ្យស្ថានការណ៍មានចលាចលកាន់តែខ្លាំងឡើងៗ និងមានពាក្យនិយាយតៗថាយន្តហោះទាំងនោះជារបស់កងទ័ពអាកាសអាមេរិក ។ នៅយប់ថ្ងៃដដែលនោះ ឆាត បានទទួលដំណឹងថាមានភ្លើងឆេះសន្ធោសន្ធៅនៅពោធិ៍ចិនតុង និងបានឮសំឡេងគ្រាប់ផ្លោងកាន់តែច្រើនឡើងៗចូលទីក្រុងភ្នំពេញ ។ ឃើញសភាពការណ៍ដូច្នេះ ឆាត ក៏បានពិភាក្សាជាមួយក្រុមគ្រួសារបងស្រីធម៌ដើម្បីចាកចេញពីទីក្រុង ។

លុះដល់ព្រឹកថ្ងៃទី១៧ មេសា ឆាត ឃើញរថក្រោះ និងរថយន្តជាច្រើនគ្រឿងបើកចូលមកទីក្រុងភ្នំពេញដោយមានយោធាខ្មែរក្រហមជិះពេញទាំងអស់ ។ យោធាខ្លះពាក់អាវពណ៌គគីរ និងខ្លះទៀតពាក់ខោអាវខ្មៅដោយមានក្រមាក្រហមពាក់ជាប់នឹងដៃនិងរុំជាប់ក្បាល ។ ចំណែកប្រជាជនដែលរស់នៅទីក្រុងបាននាំគ្នាឈរលើកដៃស្វាគមន៍នៅតាមដងវិថីនានា និងស្រែកអបអរសាទរជាមួយការលើកទង់ជាតិខ្មែរដែលបញ្ជាក់ថា ប្រទេសជាតិនឹងមានសន្តិភាពហើយ ។ ប៉ុន្តែផ្ទុយទៅវិញ រយៈពេលប្រហែលពីរបី

ម៉ោងក្រោយ ឆាត ក៏បានឮវិទ្យុប្រកាសថា «ការចូលកាន់កាប់ទីក្រុងភ្នំពេញនេះ គឺដោយសារការវាយប្រយុទ្ធមិនមែនដោយសារការចរចាគ្នាទេ ហើយយន្តហោះរបស់អាមេរិកនឹងមកទម្លាក់គ្រាប់បែកសងសឹកវិញ ដូច្នេះសូមបងប្អូនចាកចេញពីក្រុងឲ្យបានឆាប់» ។

ពេលទទួលបានដំណឹងនេះភ្លាម ឆាត និងសមាជិកគ្រួសារបងស្រីធម៌បានរៀបចំដាំបាយហូបយ៉ាងប្រញាប់ប្រញាល់ ។ ព្រឹកឡើង ឆាត នាំគ្នារៀបចំ ចាន ឆ្នាំង កន្ទេល អង្ករ និងប្រដាប់ប្រើប្រាស់មួយចំនួនទៀត រួចធ្វើដំណើរកាត់តាមផ្លូវមុខពេទ្យលោកសង្ឃ ។ ឆាត បានឃើញប្រជាជនរាប់ពាន់នាក់មានប្រុសស្រី ក្មេង ចាស់ ប្រជ្រៀតគ្នាធ្វើដំណើរទៅមុខ ។ នៅពេលកំពុងធ្វើដំណើរ ឆាត បានឮសំឡេងក្មេងៗស្រែកយំទ្រហឹងព្រោះវង្វេងឪពុកម្តាយ ហើយពេលគាត់ក្រឡេកទៅមុខឃើញចាស់ៗដែលមានជំងឺត្រូវបានបងប្អូនលើកដាក់លើរទេះរុញចាកចេញយ៉ាងប្រញាប់ប្រញាល់ពីមន្ទីរពេទ្យ ។ ចំណែកគ្រួសារដែលមានរថយន្តមិនហ៊ានជិះទេ ហើយបែរមកនាំគ្នារុញទៅវិញព្រោះពេលនោះផ្លូវចង្អៀតខ្លាំងពេក ។

ឆាត ធ្វើដំណើរកាត់តាមពោធិ៍ចិនតុង និងចោមចៅ រួចវាងមកផ្លូវទំនប់កប់ស្រូវឆ្ពោះទៅផ្លូវជាតិលេខ៥វិញ ស្រាប់តែយុទ្ធនារីខ្មែរក្រហមម្នាក់បញ្ឈប់ឲ្យគាត់ឈប់ រួចហើយសួរថា តើគាត់ធ្វើការអ្វី? ភ្លាមនោះ ឆាត ឆ្លើយថា «ខ្ញុំជាកូនសិស្ស» មួយរយៈក្រោយមកទើប នារីនោះអនុញ្ញាតឲ្យ ឆាត បន្តទៅមុខទៀត ប៉ុន្តែបានប្រាប់ ឆាត ឲ្យជម្រុះចោលគំនិតនិងរបៀបរបបរស់នៅពីរបបចាស់ឲ្យអស់ ។ ឮដូច្នេះ ឆាត និង សមាជិកគ្រួសារបងស្រីធម៌យកគ្រឿងអលង្ការ អត្តសញ្ញាណបណ្ណសំគាល់ខ្លួនសិស្សមួយចំនួនទៅកប់ចោល ។ តមកទៀត ឆាត មានការតក់ស្លុតយ៉ាងខ្លាំងព្រោះគាត់ឃើញសាកសពកងកុម្មង់ដូរបស់ លន់ នល់ ស្លាប់នៅតាមបណ្តោយផ្លូវ ។ ឆាត បានមកដល់ពាមសេដ្ឋា (ម្តុំព្រែកឡៅ) ក៏ឈប់សម្រាកនៅតាមដងទន្លេដើម្បីដាំបាយហូប និងរងចាំសាឡាងមកចម្លង ។ បន្ទាប់ពីហូបបាយរួច ឆាត បានបែកពីគ្រួសារបងស្រីធម៌ព្រោះគាត់ត្រូវឆ្លងទៅរស់នៅភូមិសង្កើច ខេត្តកំពង់ចាម ។

នៅទីនោះ កងឈ្លបបានស៊ើបពីប្រវត្តិគ្រួសារណាដែលមានសមាជិកធ្លាប់ធ្វើទាហាន ឬសាច់ញាតិជាទាហានដើម្បីប្រមូលយកទៅសម្លាប់ ។ នៅឆ្នាំ១៩៧៦ អង្គការបានបញ្ជូន ឆាត ឲ្យទៅនៅកងចល័តភូមិក្រោមការគ្រប់គ្រងឈ្មោះ ជីម ។ នៅពេលនោះ ជីម បានចាត់តាំង ឆាត ឲ្យប្រចាំការវេរនៅការដ្ឋាន និងយាមនៅចម្ការពោត ។ ក្រៅពីការវេរទាំងនោះ ឆាត ត្រូវបានចាត់តាំងឲ្យជាន់រហាត់ទឹកបញ្ចូលស្រែ និងធ្វើជីលាមកមនុស្សបណ្តាលឲ្យគាត់កើតរមាស់ជើងទាំងសងខាង ចំណែករបបអាហារមានតែបបររាវៗប៉ុណ្ណោះ ។

មួយរយៈក្រោយមក អង្គការក៏បានផ្លាស់ ឆាត ឲ្យទៅការដ្ឋានភ្នំជិលដើម្បីលើកទំនប់១៧មេសា ។ នៅទីនោះ អង្គការដាក់ផែនការឲ្យប្រជាជនថ្មីជីកដីឲ្យបានបីម៉ែត្រគូបក្នុងមួយថ្ងៃហើយទោះបីជាមានការនឿយហត់យ៉ាងណាក៏ដោយ ក៏ ឆាត មិនដែលប្រកែក និងជំទាស់នឹងអង្គការឡើយ ។ ឆាត បានធ្វើការរហូតដល់យប់ជ្រៅទើបឈប់ ។ ថ្ងៃមួយដោយសារឃ្លានខ្លាំងពេក ឆាត និងមិត្តភក្តិបានសម្រេចនាំគ្នាទៅលួចកាច់ពោតហូបទោះបីដឹងថាអង្គការនឹងអាចដាក់ទោសគាត់ដល់ស្លាប់ក៏ដោយ ។

នៅចុងឆ្នាំ១៩៧៧ អង្គការក៏បានចាត់តាំងឲ្យ ឆាត ទៅយាមស្រូវនៅខាងកើតវត្តភ្នំជិល ។ ថ្ងៃមួយមានកូនគោមួយក្បាលបានមកស៊ីស្រូវ ខណៈពេលនោះប្រធានកងបានអនុញ្ញាតឲ្យ ឆាត និងមិត្តភក្តិនៅក្នុងកងជាមួយគ្នាគប់គោរហូតដល់ងាប់ដើម្បីវះយកសាច់មកចែកគ្នាហូប ។ បន្ទាប់ពីហូបរួច ឆាត ក៏បានលួចសាច់គោដែលនៅសេសសល់ខ្លះយកទៅលាក់នៅក្នុងកាមែលដើម្បីទុកហូបថ្ងៃក្រោយទៀត ។ ក្រោយមក ប្រធានកងបានឆែករកឃើញរួចហើយចោទ ឆាត ថាក្បត់អង្គការសមូហភាព ។ ឆាត និងមិត្តភក្តិត្រូវកងឈ្លបចាប់យកទៅឃុំឃាំងដោយដាក់ច្រវាក់ជើងទាំងសងខាង ។ រៀងរាល់យប់ ប្រធានសន្តិសុខបានបញ្ជា ឆាត ឲ្យធាក់ឌីណាម៉ូដើម្បីយកភ្លើងមកបើកវិទ្យុស្តាប់ ។ ឆាត ខិតខំធ្វើការវេរយ៉ាងខ្លាំងរយៈពេលបីថ្ងៃក្រោយមកទើបប្រធានសន្តិសុខបានដោះលែង និងបញ្ជូនគាត់ឲ្យទៅព្យាបាលដំបៅជើងនៅមន្ទីរពេទ្យជើងឆ្នុក ខេត្តកំពង់ចាម ។ នៅទីនោះ ឆាត បានស្គាល់អ៊ំប្រុសម្នាក់ដែលរស់នៅភូមិជាមួយគ្នា ហើយគាត់តែងតែជួយព្យាបាលនិងយក

ថ្នាំអាចម៌ទន្សាយឲ្យ ឆាត លេបជាប្រចាំ ។

ក្រោយពី ឆាត ជាសះស្បើយ អង្គការបានផ្លាស់គាត់ឲ្យទៅនៅកងចល័តដាំបន្លែនៅបឹងក្រាំងខ្ចប់វិញ ។ នៅទីនោះ អង្គការស្រឡាញ់ និងទុកចិត្ត ឆាត និងក្រុមរបស់ ឆាត យ៉ាងខ្លាំងព្រោះគាត់ធ្វើការសារហ្មត់ចត់ ចំណែករបបអាហារក៏មានហូបគ្រប់គ្រាន់ដែរ ព្រោះអង្គការអនុញ្ញាតឲ្យកងចល័តទៅរកត្រីនៅក្នុងបឹងមកហូបបាន ។

នៅថ្ងៃមួយ ឆាត និងមិត្តភក្តិបានលួចស្តាប់វិទ្យុស្រាប់តែឮលោក អ៊ុក ប៊ុនជឿន ប្រកាសអំពីការអំពាវនាវឲ្យប្រជាជនទាំងអស់ឡើងតស៊ូវិញ ។ ចាប់តាំងពីពេលនោះមក ឆាត បានដឹងថាយោធាខ្មែរក្រហមកំពុងវាយប្រយុទ្ធជាមួយទាហានវៀតណាមហើយជារឿយៗគាត់បានឮសូរសំឡេងគ្រាប់ផ្លោងចេញពីទិសខាងកើតទីក្រុងកំពង់ចាម ។ ពេលនោះ ឆាត និងគ្រួសារមួយចំនួនបានចាកចេញពីសហករណ៍ធ្វើដំណើរត្រឡប់មកស្រុកកំណើតរៀងៗខ្លួន ។

ឆាត មករស់នៅជួបជុំគ្រួសារនៅឃុំតាំងក្រាំង ស្រុកជើងព្រៃ ខេត្តកំពង់ចាម ហើយបានក្លាយជានាយករងអនុវិទ្យាល័យមួយក្នុងខេត្តកំពង់ចាម ។

**សុិន សុធីតា**

# ដំណឹងស្វែងរកគ្រួសារដែលបាត់ខ្លួននៅសម័យខ្មែរក្រហម

ខ្ញុំបាទឈ្មោះ អូន ផល្លី ហៅ រ៉ា ឬប្រុស សព្វថ្ងៃរស់នៅក្នុងភូមិប្រក់ស្គារ ឃុំវិហារលួង ស្រុកពញាឮ ខេត្តកណ្តាល ។ ខ្ញុំបាទសូមប្រកាសស្វែងរកក្រុមគ្រួសារដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម រួមមាន ១) ឪពុកឈ្មោះ អូន ២) ម្តាយឈ្មោះ ហន (ពៅ) ៣) បងស្រីទីមួយ អូន មុំ ៤) បងស្រីទីពីរ អូន ម៉ាច ៥) ប្អូនស្រីទី៤ អូន ស្រី និង ៦) ប្អូនស្រីពៅឈ្មោះ អូន ស្រស់ ។ ភ្លាមៗបន្ទាប់ពីខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំដែលមានសមាជិកប្រាំពីរនាក់ រួមទាំងខ្ញុំដែរត្រូវបានខ្មែរក្រហមជម្លៀសទៅនៅឃុំព្រែកញ្ញៀ ស្រុកពារាំង ខេត្តព្រៃវែង ។ ពេលទៅដល់នោះបានរយៈពេលប៉ុន្មានខែ សមាជិកគ្រួសាររបស់ខ្ញុំក៏បានបាត់ខ្លួនជាបន្តបន្ទាប់ ដោយមិនដឹងពីមូលហេតុ ។ កាលនោះខ្ញុំក៏មិនបានដឹងពីការបាត់ខ្លួនរបស់គាត់ដែរ ពីព្រោះខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើការនៅកងកុមារឆ្ងាយពីភូមិ ។ បើសិនជាក្រុមគ្រួសាររបស់ខ្ញុំបានឮដំណឹងនេះ ឬបងប្អូនណាបានស្គាល់គាត់ សូមមេត្តាទំនាក់ទំនងមកខ្ញុំបាទតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ឬខ្ញុំបាទផ្ទាល់ តាមរយៈទូរស័ព្ទលេខ ០១២ ៦១២ ១០៦ ឬ ០៩៧ ៩២៥ ១៩៦៩ ។ ***សូមអរគុណ***

# ដំណឹងស្វែងរកក្រុមគ្រួសារ

ខ្ញុំបាទឈ្មោះ សួន វណ្ណថន សព្វថ្ងៃរស់នៅក្នុងភូមិជ័យក្រោម ឃុំរាធរ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ ខ្ញុំបាទសូមប្រកាសស្វែងរកក្រុមគ្រួសារដែលបានបាត់ខ្លួននៅខេត្តពោធិ៍សាត់ ចុងឆ្នាំ១៩៧៨ ។ នៅចុងឆ្នាំ១៩៧៨ ប្អូនស្រីរបស់ខ្ញុំឈ្មោះ សួន ស្រីពៅ (ហៅ ជិន ស្រីពៅ) បានបាត់ខ្លួននៅកងកុមាររបស់សហករណ៍វត្តលួង ដែលស្ថិតនៅក្បែរភូមិទួលព្រះថ្ម ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ កាលនោះ ស្រីពៅ មានអាយុប្រហែល៧ឆ្នាំប៉ុណ្ណោះ ។ ក្រោយពេលបែកគ្នា ខ្ញុំបានឮដំណឹងថា យាយអ៊ឹម និងតាថេម ដែលជាអ្នកស្រុកពោធិ៍សាត់ បានរើសប្អូនស្រីខ្ញុំ (ស្រីពៅ) មកចិញ្ចឹម ។ តែក្រោយមកមិនដែលបានឮដំណឹងអ្វីទាល់តែសោះ ។ ក្រៅពីប្អូនស្រីពៅ បានបាត់ខ្លួន ម្តាយខ្ញុំឈ្មោះ សារឿង ឪពុកឈ្មោះ ជិន ប្អូនប្រុស២នាក់ឈ្មោះ ថា និង ព្រឹង ក៏បាត់ខ្លួននៅខេត្តពោធិ៍សាត់ដែរ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឬបានឃើញ ឬក្រុមគ្រួសារបានឮដំណឹងនេះហើយ សូមមេត្តាទំនាក់ទំនងមករូបខ្ញុំផ្ទាល់តាមរយៈអាសយដ្ឋានខាងលើ ឬតាមទូរស័ព្ទលេខ ០៩៧ ៦៨៨ ១៣២៩ ។ ***សូមអរគុណ***

# ហេតុអ្វីបានជាការអប់រំសំខាន់សម្រាប់ដំណើរការផ្លូវច្បាប់?

ដំណើរការផ្លូវច្បាប់អាចមានភាពស្មុគស្មាញសម្រាប់អ្នកដែលគ្មានអាជីពជាមេធាវី ។ តាមពិតដំណើរការនេះគឺជាផ្នែកមួយដ៏មានសារសំខាន់សម្រាប់សង្គមកំពុងប្រតិបត្តិការដ៏ល្អប្រសើរ ដោយសារតែគោលបំណងរបស់ដំណើរការនេះគឺត្រូវផ្តល់ការការពារដល់បុគ្គលទាំងឡាយណាដែលបានបង្កើតសង្គម ។ ដំណើរការផ្លូវច្បាប់ក៏មានភាពផុយស្រួយដែរ ដោយសារតែពឹងផ្អែកលើប្រជាពលរដ្ឋដើម្បីធ្វើឲ្យដំណើរការនេះប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវ ។ បើគ្មានការចូលរួមយ៉ាងផុសផុលពីសំណាក់ប្រជាពលរដ្ឋនៅក្នុងដំណើរការនេះទេ ដំណើរការផ្លូវច្បាប់មិនអាចបំពេញការងារប្រកបដោយប្រសិទ្ធភាពនោះឡើយ ។ នេះជាហេតុផលដែលការអប់រំមានសារសំខាន់នៅក្នុងដំណើរការផ្លូវច្បាប់ ។ ប្រជាពលរដ្ឋត្រូវតែយល់ដឹងអំពីដំណើរការនេះដើម្បីឲ្យខ្លួនអាចមានលទ្ធភាពចូលរួម និងជួយពង្រឹងដំណើរការនោះទៀតផង ។

### តើដំណើរការផ្លូវច្បាប់អាចការពារប្រជាពលរដ្ឋយ៉ាងដូចម្តេចខ្លះ?

ដំណើរការផ្លូវច្បាប់បញ្ចូលសមាសធាតុសំខាន់ចំនួនពីរគឺ «នីតិរដ្ឋ» និង «ដំណើរការសមស្របតាមផ្លូវច្បាប់» ។ តើពាក្យច្បាប់ទាំងពីរនេះមានអត្ថន័យដូចម្តេចខ្លះ?

១) «នីតិរដ្ឋ» គ្រាន់តែមានន័យថា ច្បាប់ស្ថិតនៅលំដាប់កំពូលនៅក្នុងសង្គម ហើយគ្រប់គ្រងទៅលើការប្រព្រឹត្តរបស់មនុស្សគ្រប់រូបក្នុងរបៀបដូចៗគ្នា ។ នេះមានន័យថា រដ្ឋាភិបាល អ្នកមានទ្រព្យសម្បត្តិ ជនក្រីក្រ មនុស្សល្អនិងមនុស្សអាក្រក់នឹងត្រូវដោះស្រាយប្រកបដោយភាពស្មើភាពគ្នានៅក្នុងដំណើរការផ្លូវច្បាប់ ។ គ្មានការផ្តល់ការដោះស្រាយពិសេសណាមួយសម្រាប់បុគ្គលណាម្នាក់នៅចំពោះមុខច្បាប់ឡើយ ។ ដោយសារតែនីតិរដ្ឋទាមទារថាមនុស្សគ្រប់រូបត្រូវតែដោះស្រាយស្មើៗគ្នាតាមផ្លូវច្បាប់ នេះមានន័យថា មានភាពច្បាស់លាស់ខាងផ្លូវច្បាប់ ។ ដូច្នេះមនុស្សគ្រប់រូបត្រូវដឹងអំពីអ្វីដែលខ្លួនអាចធ្វើ និងមិនអាចធ្វើព្រមទាំងអ្វីជាផលវិបាកដែលនឹងអាចកើតឡើង ប្រសិនបើខ្លួនល្មើសច្បាប់ ។ មនុស្សគ្រប់រូបក៏ត្រូវតែដឹងអំពីសិទ្ធិរបស់ខ្លួនមានអ្វីខ្លះដែលមានចែងនៅក្នុងច្បាប់ ។ ជារួម ច្បាប់ស្ថិតនៅត្រង់ចំណុចមួយដើម្បីនាំមកនូវសណ្តាប់ធ្នាប់សម្រាប់ទំនាក់ទំនងខាងសង្គម ពាណិជ្ជកម្ម និងក្រុមគ្រួសារ ព្រមទាំងការពារប្រជាពលរដ្ឋទាំងអស់ ។ រដ្ឋាភិបាលត្រូវអនុវត្តតាមច្បាប់ ដែលបង្កើតឡើងដោយរដ្ឋសភា និងលក្ខខណ្ឌទាំងឡាយណាដែលច្បាប់ត្រូវបានបង្កើតឡើងឬផ្លាស់ប្តូរនៅក្នុងរដ្ឋសភាក៏ត្រូវអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ដែរ ។ របៀបដែលច្បាប់ត្រូវបានអនុវត្ត ឬបកស្រាយនៅក្នុងតុលាការវិញក៏ត្រូវបានបញ្ញត្តិដោយច្បាប់ដែរ ។ ដោយសារតែមានកត្តានេះហើយ ទើបអ្នកអនុវត្តច្បាប់ទាំងឡាយត្រូវ តែប្រតិបត្តិឲ្យស្របទៅតាមច្បាប់ ។ ចៅក្រមមិនអាចខិតខំកែតម្រូវដើម្បីលុបចោលឬផ្អាកវិធានណាមួយដែលគ្រប់គ្រងលើសកម្មភាពរបស់ខ្លួនឡើយ ។ អំណាចដែលផុសចេញពីការលើកកម្ពស់តាមផ្លូវច្បាប់ត្រូវតែប្រើប្រាស់ឲ្យស្របទៅតាមច្បាប់កំណត់ ។ អំពើពុករលួយជាសត្រូវរបស់នីតិរដ្ឋ ។ វិធានស្តីពីថាតើច្បាប់ត្រូវបានអនុវត្តយ៉ាងដូចម្តេច និងវិធានដែលគ្រប់គ្រងលើដំណើរការផ្លូវច្បាប់ត្រូវបានពិពណ៌នាថាជា



យាយ តាំង គីម រៀបរាប់ពីបទពិសោធន៍ជីវិតទៅកាន់ អេនឌ្រូ ខេលី និងគ្រូបង្រៀននៅខេត្តកំពង់ឆ្នាំង

«ដំណើរការសមស្របតាមផ្លូវច្បាប់» ។

២) «ដំណើរការសមស្របតាមផ្លូវច្បាប់» គឺជាវិធានមួយចំនួនដែលគ្រប់គ្រងលើរបៀបដែលច្បាប់ត្រូវបានអនុវត្តនៅក្នុងករណីណាមួយ ។ តើចៅក្រមអនុវត្តច្បាប់យ៉ាងដូចម្តេច? ដំណើរការផ្លូវច្បាប់ត្រូវតែអនុវត្តប្រកបដោយភាពយុត្តិធម៌ និងស្របទៅតាមនីតិរដ្ឋក្នុងលក្ខណៈដូចៗគ្នាចំពោះមនុស្សគ្រប់រូប ។ ដំណើរការសមស្របតាមផ្លូវច្បាប់ តម្រូវឲ្យមានការវិនិច្ឆ័យទោសប្រកបដោយភាពយុត្តិធម៌ និងផ្តល់សិទ្ធិជូនប្រជាពលរដ្ឋដើម្បីវែកញែកលើផ្លូវច្បាប់ទាក់ទងនឹងសេចក្តីសម្រេចរបស់តុលាការប្រឆាំងមកលើខ្លួន ។ ឧទាហរណ៍ ប្រជាពលរដ្ឋអាចដេញដោលទៅលើការឃុំខ្លួននៅក្នុងការកាត់សេចក្តីលើបទព្រហ្មទណ្ឌ ។

គោលការណ៍សំខាន់ៗរបស់ «ដំណើរការសមស្របតាមផ្លូវច្បាប់» មានដូចជា ៖

ក) សិទ្ធិទទួលបានការកាត់ទោសដែលមិនលម្អៀង ។ ជាពិសេសតុលាការត្រូវតែឯករាជ្យពីរដ្ឋាភិបាល ហើយត្រូវអនុវត្តច្បាប់ដោយគ្មានការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅ ។

ខ) សិទ្ធិទទួលបានការកាត់សេចក្តីពីក្រុមប្រឹក្សាវិនិច្ឆ័យ (ដូចជានៅក្នុងប្រទេសមួយចំនួន រួមមានសហរដ្ឋអាមេរិក កាណាដា និងចក្រភពអង់គ្លេស ដែលការកាត់ទោសត្រូវបានសម្រេចដោយក្រុមប្រឹក្សាវិនិច្ឆ័យ) ។

គ) សិទ្ធិទទួលបាន «ការជូនដំណឹង» ។ នេះសំដៅទៅលើសិទ្ធិដែលទទួលបានដំណឹងពីសេចក្តីសម្រេច ដែលត្រូវបានស្នើឡើងដោយតុលាការ និងហេតុផលនៃសេចក្តីសម្រេចនោះ ។

ឃ) សិទ្ធិទទួលបានឱកាសដើម្បីបង្ហាញហេតុផលស្តីពីថាតើសេចក្តីសម្រេចចិត្តដែលបានលើកឡើងនោះ មិនគួរត្រូវបានធ្វើឡើងនោះឡើយ ។ នេះជាសិទ្ធិរបស់អ្នកក្នុងការលើកឡើងអង្គហេតុផ្ទាល់ខ្លួន ។ សិទ្ធិនេះ រួមមានសិទ្ធិបង្ហាញភស្តុតាងដែលរាប់បញ្ចូលទាំងសិទ្ធិកោះហៅសាក្សីផង ។

ង) សិទ្ធិដឹងឮអំពីភស្តុតាងប្រឆាំងដែលសំដៅទៅលើភស្តុតាងប្រឆាំងនឹងរឿងក្តីរបស់ជនជាប់ចោទ ។

ច) សិទ្ធិត្រួតពិនិត្យឬចោទសួរសាក្សីផ្សេងៗ ។ នេះមានន័យថាជាសិទ្ធិក្នុងការដេញដោលពីសច្ចៈភាពរបស់បុគ្គលណាម្នាក់ដែលផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួន ។

ឆ) សិទ្ធិទទួលបានសេចក្តីសម្រេចមួយដែលធ្វើឡើងដោយតុលាការ ដោយផ្អែកលើភស្តុតាងដែលបានផ្តល់ជូនទៅតុលាការ និងផ្អែកលើលក្ខន្តិកៈ ដែលតុលាការបានរៀបចំសម្រាប់កត់ត្រាខ្លឹមសាររបស់ភស្តុតាងដែលបានផ្តល់ជូន ។

ជ) សិទ្ធិមានមេធាវីធ្វើជាតំណាង ។

ឈ) លក្ខន្តិកៈដែលតុលាការរៀបចំអង្គហេតុ និងមូលហេតុជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើសេចក្តីសម្រេចចិត្ត ។

ដំណើរការផ្លូវច្បាប់ មានលទ្ធភាពខ្ពស់ក្នុងការជះឥទ្ធិពលច្រើនមកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ដូច្នេះហើយបានជាដំណើរការសមស្របតាមផ្លូវច្បាប់ត្រូវតែប្រកាន់ខ្ជាប់ជានិច្ចដើម្បីធានាថាដំណើរការនេះត្រូវបានអនុវត្តដោយត្រឹមត្រូវនិងយុត្តិធម៌ ។

យើងអាចឆ្ងល់ថា ហេតុអ្វីបានជាមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ទទួលបានឱកាសការពារខ្លួន ។ ហេតុអ្វីបានជាដំណើរការផ្លូវច្បាប់ផ្តល់ឱកាសដល់អ្នកទាំងនោះឲ្យបកស្រាយហេតុផលផ្ទាល់ខ្លួន បើទោះបីជាអំពើដែលអ្នកទាំងនោះបានប្រព្រឹត្តមិនអាចលើកលែងក៏ដោយ ប៉ុន្តែយើងត្រូវចងចាំថា មនុស្សគ្រប់រូបត្រូវតែផ្តល់ជូននូវដំណើរការសមស្របតាមផ្លូវច្បាប់ដូចៗគ្នាដើម្បីឲ្យមានភាពយុត្តិធម៌ និងស្មើភាពសម្រាប់យើងទាំងអស់គ្នា ។



សហព្រះរាជអាជ្ញាអន្តរជាតិរបស់សាលាក្តីខ្មែរក្រហម អេនឌ្រូ ខេលី

ប្រសិនបើជនម្នាក់ត្រូវបានរកឃើញថាមានពិរុទ្ធភាពបន្ទាប់ពីទទួលបានការកាត់ទោសដោយយុត្តិធម៌ តុលាការនិងមនុស្សគ្រប់រូបអាចត្រូវបានធានាថា សាលក្រមកាត់ទោសនោះពិតជាស្របច្បាប់ និងត្រឹមត្រូវ ។

ប្រសិនបើដំណើរការសមស្របតាមផ្លូវច្បាប់ប្រព្រឹត្តទៅដោយយុត្តិធម៌ ដំណើរការនេះនឹងមានភាពត្រឹមត្រូវតាមច្បាប់ ។ ដូច្នេះប្រជាពលរដ្ឋទូទៅនឹងជឿជាក់លើដំណើរការនេះ ។ ប្រសិនបើដំណើរការនេះគ្មានយុត្តិធម៌វិញ មនុស្សទូទៅនឹងមិនមានជំនឿទៅលើដំណើរការនេះទេ ។ យើងទាំងអស់គ្នាក៏មិនចូលរួមជាមួយនឹងដំណើរការតាមផ្លូវច្បាប់ដែរ ។ ជាលទ្ធផល ដំណើរការតាមផ្លូវច្បាប់នេះនឹងមានភាពទន់ខ្សោយជាក់ជាពុំខាន ។ ជាទូទៅដំណើរការតាមផ្លូវច្បាប់ទន់ខ្សោយដែលប្រជាពលរដ្ឋទូទៅមិនបានប្រើប្រាស់មិនអាចការពារប្រជាពលរដ្ឋបានទេ ។

### ***តើការអប់រំពង្រឹងដំណើរការផ្លូវច្បាប់យ៉ាងដូចម្តេចខ្លះ?***

ដូចដែលបានចេញផ្សាយនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា «យើងទាំងអស់គ្នាត្រូវតែចែករំលែកមេរៀនអំពីអតីតកាល ដើម្បីស្ថាបនានូវអនាគតដ៏ល្អប្រសើរមួយ ។ ការបង្រៀនអំពីគោលការណ៍ច្បាប់និងសិទ្ធិមនុស្ស នឹងអាចអនុញ្ញាតឲ្យយើងធ្វើកិច្ចការឆ្ពោះទៅរកពិភពលោកមួយដែលគ្មានអំពើប្រល័យពូជសាសន៍» ។

ការអប់រំនឹងជួយឲ្យមនុស្សស្វែងយល់ថាតើប្រព័ន្ធច្បាប់ប្រព្រឹត្តទៅយ៉ាងដូចម្តេច ។ បន្ទាប់មក ប្រជាពលរដ្ឋនឹងអាចយល់ដឹងអំពីដំណើរការផ្លូវច្បាប់និងមូលហេតុដែលវិធានទាំងឡាយនៅក្នុងដំណើរការផ្លូវច្បាប់មានទម្រង់បែបនោះ ។ ការស្វែងយល់ពីដំណើរការផ្លូវច្បាប់មានន័យថា ដំណើរការនេះលែងមានលក្ខណៈស្មុគស្មាញឬចម្លែកទៀតហើយ ហើយការអប់រំនឹងបើកចំហឲ្យសាធារណជនធ្វើការពិនិត្យពិច័យទៅលើដំណើរការផ្លូវច្បាប់ឲ្យកាន់តែច្រើនជាងនេះ ។

គ្មាននរណាម្នាក់អាចស្វែងរកការការពារពីច្បាប់ ឬក៏ការការពារពីដំណើរការតាមផ្លូវច្បាប់បានឡើយ ប្រសិនបើអ្នកទាំងនោះមិនបានដឹងថាការការពារទាំងនោះមានអ្វីខ្លះ ។

វាមានសារសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋទាំងអស់ក្នុងការស្វែងយល់ពីសិទ្ធិរបស់ខ្លួន និងពីរបៀបដែលដំណើរការតាមផ្លូវច្បាប់គួរតែត្រូវបានអនុវត្តដើម្បីអនុញ្ញាតឲ្យប្រជាពលរដ្ឋទាំងអស់ទទួលបានការទទួលខុសត្រូវពីដំណើរការផ្លូវច្បាប់នោះ ។ ប្រសិនបើប្រជាពលរដ្ឋទទួលបានការអប់រំអំពីអ្វីដែលជាផ្នែកសមស្របនៃដំណើរការតាមផ្លូវច្បាប់ អ្នកទាំងនោះនឹងដឹងថាតើត្រូវទាមទារឲ្យមាននីតិរដ្ឋ និងដំណើរការសមស្របតាមផ្លូវច្បាប់យ៉ាងដូចម្តេច ។ ប្រសិនបើប្រជាពលរដ្ឋយល់ដឹងអំពីគោលគំនិតទាំងនោះមានអត្ថន័យយ៉ាងដូចម្តេចនៅក្នុងការអនុវត្តជាក់ស្តែង អ្នកទាំងនោះនឹងអាចកត់សម្គាល់ចំណុចខ្វះខាតនៅក្នុងដំណើរការតាមផ្លូវច្បាប់បាន ។ នៅពេលដែលប្រជាពលរដ្ឋអាចមើលឃើញពីចំណុចខ្វះខាតនៅក្នុងដំណើរការតាមផ្លូវច្បាប់ អ្នកទាំងនោះនឹងអាចក្រោកឈរឡើង ហើយនិយាយតបតវិញ ។ ប្រការនេះមិនល្អសម្រាប់សង្គមរបស់យើងនោះទេ ។ ប្រជាពលរដ្ឋអាចទាមទារបានច្រើនពីដំណើរការតាមផ្លូវច្បាប់ ។ ប្រសិនបើប្រជាពលរដ្ឋទទួលបានការអប់រំ អ្នកទាំងនោះនឹងអាចធ្វើឲ្យដំណើរការតាមផ្លូវច្បាប់មានការទទួលខុសត្រូវ ។ ប្រសិនបើប្រជាពលរដ្ឋមិនទទួលបានការអប់រំដ៏ត្រឹមត្រូវទេ នោះនឹងមិនមានការទទួលខុសត្រូវឡើយ ដោយសារតែអ្នកទាំងនោះមិនបានដឹងអំពីអ្វីដែលខ្លួនស័ក្តិសមនឹងទទួលបានពីដំណើរការតាមផ្លូវច្បាប់នេះ ។

ដំណើរការផ្លូវច្បាប់ដែលអនុវត្តតាមនីតិរដ្ឋ និងដំណើរការសមស្របតាមផ្លូវច្បាប់គឺជាដំណើរការច្បាប់មួយដែលអាចទទួលបានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋ ដោយសារតែដំណើរការនេះជួយការពារប្រជាពលរដ្ឋ ។ កាលណាមានការគាំទ្រមកលើដំណើរការផ្នែកច្បាប់កាន់តែច្រើន ដំណើរការនេះនឹងត្រូវបានយកមកអនុវត្តកាន់តែច្រើនពីសំណាក់ប្រជាពលរដ្ឋដែរ ។ កាលណាដំណើរការតាមផ្លូវច្បាប់ទទួលការគាំទ្រកាន់តែច្រើនពីសំណាក់ប្រជាពលរដ្ឋ ដំណើរការនោះនឹងកាន់តែរឹងមាំជាងមុន ។ ដំណើរការតាមផ្លូវច្បាប់ដ៏រឹងមាំអាចជួយការពារប្រជាពលរដ្ឋ និងធ្វើឲ្យមានសណ្តាប់ធ្នាប់និងស្ថិរភាពដល់សង្គម ។ នេះគឺជាភាពត្រឹមត្រូវ ។ ដំណើរការផ្លូវច្បាប់ដែលមានភាពត្រឹមត្រូវនឹងផ្តល់ភាពស្របច្បាប់ព្រមទាំងទទួលបានការគោរពពីប្រជាពលរដ្ឋជាក់ជាពុំខាន ។

**អេនឌ្រូ ខេលី**

# ការវិភាគលើការទទួលខុសត្រូវខាងព្រហ្មទណ្ឌដ៏សំខាន់របស់អ្នកសារព័ត៌មាន សម្រាប់ការផ្សព្វផ្សាយព័ត៌មានសម្ងាត់របស់សាលាក្ដីខ្មែរក្រហម

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១ កាសែតរបស់សហរដ្ឋអាមេរិកដែលមានឈ្មោះថា គ្រីស្ទៀន សៃអិន ម៉ននីទ័រ បានដកស្រង់ព័ត៌មានយ៉ាងច្រើនចេញពីឯកសារសម្ងាត់របស់ព្រះរាជអាជ្ញាដែលបានចោទសួរពីដំណើរការស៊ើបអង្កេតរបស់តុលាការលើសំណុំរឿង០០៣នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ យោងតាមសារព័ត៌មាននេះ ឯកសារសម្ងាត់ដែលបានកត់សម្គាល់ពីអត្តសញ្ញាណរបស់ជនសង្ស័យពីរនាក់ ឧក្រិដ្ឋកម្មដែលចោទប្រកាន់ និងព័ត៌មានលម្អិតទាក់ទងនឹងការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ជនសង្ស័យទាំងពីរនេះ ។

មួយថ្ងៃក្រោយពេលដែលអត្ថបទនេះត្រូវបានបោះពុម្ពផ្សាយ សហចៅក្រមស៊ើបអង្កេតរបស់សាលាក្ដីខ្មែរក្រហមដែលជាការិយាល័យទទួលបន្ទុកសម្រាប់ការស៊ើបអង្កេតសម្ងាត់របស់អង្គបុរេជំនុំជម្រះបានចេញលិខិតមួយដែលព្រមានថា ជនណាដែលផ្សព្វផ្សាយព័ត៌មានចេញពីឯកសាររបស់សហព្រះរាជអាជ្ញាអាចនឹងប្រឈមមុខនឹងបទចោទប្រកាន់ដែលឋិតនៅក្រោមវិធានផ្ទៃក្នុង៣៥របស់តុលាការខ្មែរក្រហមពីបទ ៖ ជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌ ។ ដោយសារកង្វះខាតនូវគំរូ និងបទដ្ឋានប្រព័ន្ធច្បាប់ច្បាស់លាស់ បើទោះបីជាតុលាការនេះមានអំណាចដាច់មុខដើម្បីដាក់ទណ្ឌកម្មលើការប្រព្រឹត្តប្រមាថមើលងាយក៏ដោយ ក៏មានសំណួរជាច្រើនដែលចោទសួរថាតើវិធានរបស់តុលាការខ្មែរក្រហមអាចនឹងអនុវត្តទៅលើក្រុមអ្នកសារព័ត៌មានបានយ៉ាងដូចម្ដេចដែរ ។

## វិធានផ្ទៃក្នុង៣៥របស់តុលាការខ្មែរក្រហម ៖ ការជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌

### ក) យុត្តាធិការតាមសាច់រឿង

វិធានផ្ទៃក្នុង៣៥ ចែងដោយផ្នែកថា ៖

១) តុលាការខ្មែរក្រហមអាចដាក់ទណ្ឌកម្ម ឬបញ្ជូនរឿងក្ដីនេះទៅឲ្យអាជ្ញាធរសមរម្យណាមួយនៃរឿងក្ដីរបស់ជនដែលជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌ដោយដឹងមុន និងដោយចេតនាដែលក្នុងនោះសំដៅទៅលើជនដែល ៖

ក) បង្ហាញពីព័ត៌មានសម្ងាត់ដែលរំលោភបំពានលើដីការបស់សហចៅក្រមស៊ើបអង្កេត ឬតុលាការ ។

ការប្រព្រឹត្តខាងលើនេះគឺជាការប្រព្រឹត្តមួយនៅក្នុងចំណោមការប្រព្រឹត្តជាច្រើនទៀតដែលត្រូវបានរៀបរាប់នៅក្នុងវិធាន៣៥(១) ហើយក៏ជាការប្រព្រឹត្តដ៏សមរម្យបំផុតដែលតុលាការអាចចោទប្រកាន់អ្នកសារព័ត៌មានពីបទប្រមាថមើលងាយ ។ ខ្លឹមសារនៃវិធាននេះមានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងវិធាន៧៧(ក)(២)របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលបានបង្កើតជាមូលដ្ឋានមួយស្ដីពីការកាត់ទោសពីបទប្រមាថមើលងាយដែលប្រព្រឹត្តឡើងដោយអ្នកសារព័ត៌មាន ។

ខ) នៅក្នុងការអនុវត្តអំណាចដាច់មុខរបស់ខ្លួនតុលាការអាចនឹងចោទប្រកាន់ជនណាម្នាក់ពីបទប្រមាថមើលងាយ ដោយសារជននោះជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌ដែលក្នុងនោះសំដៅទៅលើជនដែល

(២) ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងដំណើរការនីតិវិធីទាំងអស់ដោយបានដឹងពីការធ្វើដូច្នេះអាចនឹងរំលោភបំពានលើដីការបស់តុលាការទាក់ទងនឹងវិធាន៧៧ ចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានសម្រេចថា

អំណាចក្នុងការចេញបទចោទប្រកាន់ពីការប្រមាថមើលងាយមិនត្រូវបានលើកឡើងដោយបើកចំហរនៅក្នុងលក្ខន្តិកៈរបស់តុលាការទេ ប៉ុន្តែអំណាចនេះគឺជាផ្នែកមួយនៃអំណាចរបស់ចៅក្រមក្នុងការដោះស្រាយបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងការបង្កបញ្ហាដែលឋិតនៅក្រោមយុត្តាធិការរបស់ខ្លួន.... ។ អំណាចនេះកកើតឡើងដោយឯករាជ្យចេញពីអំណោះអំណាងដែលបំពេញទៅតាមលក្ខន្តិកៈរបស់តុលាការក្នុងការដាក់ទណ្ឌកម្មលើការ

ប្រព្រឹត្តទាំងឡាយណាដែលរារាំង រើសអើង ឬរំលោភបំពានការគ្រប់គ្រងវិស័យយុត្តិធម៌របស់តុលាការ ។ អំណាចនេះមានសារសំខាន់ក្នុងការធានាថាគ្មានការបង្អាក់ដល់ដំណើរការអនុវត្តយុត្តាធិការរបស់តុលាការ ដើម្បីជំរុញឲ្យមានការការពារតួនាទីរបស់តុលាការជាមូលដ្ឋានត្រូវបានការពារ ។

មកដល់សព្វថ្ងៃនេះ តុលាការខ្មែរក្រហមមិនដែលបានដំណើរការអង្គនីតិវិធីដោយសាររឿងក្តីពីបទចោទប្រកាន់ពីការប្រមាថមើលងាយ ដែលមានចែងនៅក្នុងវិធាន៣៥ ១) ក) ទេ ប៉ុន្តែតុលាការអាចនឹងមានមូលហេតុដូចគ្នាដែលថាតុលាការមានសាច់រឿងដែលជាប់ពាក់ព័ន្ធនឹងប្រភេទឧក្រិដ្ឋកម្មបែបនេះ ។

**១) យុត្តាធិការផ្នែកបុគ្គល : «ជនទាំងឡាយ» អាចនឹងត្រូវបានកាត់ទោសពីបទប្រមាថមើលងាយដល់តុលាការ**

អំណាចដ៏ទូលាយនៃវិធាន៣៥ក្នុងការដាក់ទណ្ឌកម្មលើ «ជនណាម្នាក់» សម្រាប់ការជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌បានអនុញ្ញាតឲ្យតុលាការទទួលបាននូវយុត្តាធិការផ្នែកបុគ្គលដែលគ្មានដែនកំណត់ ។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០១០ក៏ដាក់ទណ្ឌកម្មស្រដៀងគ្នាទៅលើការជ្រៀតជ្រែកមុខងារសាធារណៈរបស់តុលាការដោយខុសច្បាប់ដែរ ។ យ៉ាងណាមិញ មាត្រាដែលជាប់ពាក់ព័ន្ធនឹងបញ្ហានេះមិនបានបញ្ជាក់ថាជនប្រភេទណាដែលអាចត្រូវបានផ្តន្ទាទោសនោះទេ ។ នៅក្នុងរឿងក្តីដំបូងគេបង្អស់ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានចាប់ផ្តើមដំណើរការអង្គនីតិវិធីពីបទប្រមាថមើលងាយរបស់អ្នកសារព័ត៌មានម្នាក់ អ្នកសារព័ត៌មានរូបនោះបានចោទសួរថា «តើតុលាការពិតជាមានអំណាចដើម្បីកាត់ទោសជនណាម្នាក់ឬក៏ក្រុមមនុស្សដែលត្រូវចោទប្រកាន់ពីឧក្រិដ្ឋកម្មនៃការប្រមាថមើលងាយដែរឬទេ» ។ អង្គបុរេជំនុំជម្រះបានសម្រេចថា អំណាចរបស់តុលាការក្នុងការកាត់ទោសជនណាម្នាក់ពីបទប្រមាថមើលងាយ «មិនបានកំណត់ថាអាចកាត់ទោសតែជនដែលជាភាគីពាក់ព័ន្ធនឹងដំណើរការនីតិវិធីនៅចំពោះមុខតុលាការ ឬក្រុមមនុស្សណាមួយនោះទេ» ។ យោងតាមរឿងក្តីពីបទប្រមាថមើលងាយមុនៗដែលសាច់ញាតិរបស់ជនជាប់ចោទបានជ្រៀតជ្រែក សាក្សីចៅក្រមបានសម្រេចថា យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានគូសបញ្ជាក់ថាតុលាការមានអំណាចក្នុងការកាត់ទោសជនណាៗទាំងអស់ ។ ដោយសារតែបទបញ្ញត្តិស្តីពីបទប្រមាថមើលងាយរបស់តុលាការខ្មែរក្រហមនិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីមានខ្លឹមសារស្រដៀងគ្នា នោះតុលាការខ្មែរក្រហមអាចសម្រេចបានថាតុលាការមានយុត្តាធិការផ្នែកបុគ្គលដែលគ្មានព្រំដែនកំណត់លើឧក្រិដ្ឋកម្មប្រភេទនេះ ។

គួរឲ្យកត់សម្គាល់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងតុលាការនៅរ៉្វាន់ដាត្រូវបានបង្កើតឡើងដោយកថាខណ្ឌទី៧នៃអនុសញ្ញាក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហ



អ្នកសារព័ត៌មានជាតិ និងអន្តរជាតិកំពុងធ្វើបទសម្ភាសន៍

ប្រជាជាតិ ហើយមានឯករាជ្យភាពពេញលេញចេញពីប្រព័ន្ធតុលាការជាតិ ។ ផ្ទុយទៅវិញ តុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដោយច្បាប់កម្ពុជា យោងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដោយដើរតួជាតុលាការពិសេសមួយឋិតនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។ ខុសពីតុលាការអន្តរជាតិផ្សេងៗទៀត ជាលទ្ធផលតុលាការខ្មែរក្រហមមិនមានអំណាចគ្រប់គ្រាន់ដើម្បីអនុវត្តឲ្យជនសង្ស័យដែលរស់នៅក្រៅប្រទេសកម្ពុជាចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការបានទេ ។

បើទោះបីជាភាពខុសប្លែកគ្នានេះមិនទាន់បានរារាំងដល់អាណត្តិរបស់តុលាការដោយសារតែជនសង្ស័យទាំងអស់មានទីកន្លែងរស់នៅក្នុងទឹកដីប្រទេសកម្ពុជាក៏ដោយ ក៏លក្ខណៈខុសប្លែកគ្នានេះនឹងដាក់កម្រិតមកលើសមត្ថភាពរបស់តុលាការខ្មែរក្រហមក្នុងការធានាការឃុំខ្លួនរបស់អ្នកសារព័ត៌មានដែលរស់នៅក្រៅប្រទេសកម្ពុជាបាន ។

### គ) លក្ខន្តិកៈនៃ «ដីកាក្រោមវិធាន៣៥(១)(ក)

វិធាន៣៥(១)(ក) ចែងថាការផ្សព្វផ្សាយព័ត៌មានសម្ងាត់គឺជា «ការរំលោភបំពានលើដីការបស់សហចៅក្រមស៊ើបអង្កេត



ឬចៅក្រម» ។ នៅខែមីនា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមបានចោទប្រកាន់លោក ម៉ៃ ឃើល ខណាវ៉ាស់ និង អាង ឧត្តម សហមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ថា បានបង្ហាញព័ត៌មានសម្ងាត់នៅលើគេហទំព័រពីរដែលត្រូវបានបង្កើតឡើងដើម្បីផ្សព្វផ្សាយការស្រាវជ្រាវរកឃើញរបស់ក្រុមមេធាវីការពារក្តីស្តីពីកិច្ចការរបស់តុលាការ ។ បើទោះបីជាការរកឃើញរបស់ក្រុមមេធាវីការពារក្តីដែលនិយាយពីដំណើរការកាត់ទោសមិនត្រូវបានអនុញ្ញាតក៏ដោយ ក៏ចៅក្រមបានសម្រេចថាវាមិនត្រឹមត្រូវទេដែលសហចៅក្រមស៊ើបអង្កេតអាចដាក់ទណ្ឌកម្មមកលើមេធាវីការពារក្តីទាំងពីរបានតាមវិធាន៣៥ នេះ ។ ចៅក្រមបានជឿជាក់ថា សហមេធាវីការពារក្តីឲ្យជនជាប់ចោទបានរំលោភលើការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ ។ យ៉ាងណាមិញ ចៅក្រមបានសម្រេចថាការប្រព្រឹត្តរបស់សហមេធាវីទាំងពីរមិនឋិតនៅក្រោមវិសាលភាពនៃវិធាន៣៥(១)(ក) ទេ ។ ដោយកត់សម្គាល់ថាការបង្កើតឡើងនូវដីកាមួយពិតជាមានសារសំខាន់ដល់តម្រូវការមុនការរកឃើញការរំលោភបំពានច្បាប់នោះចៅក្រមបានសម្រេចថា សារលិខិតរបស់សហចៅក្រមស៊ើបអង្កេតដែលបានព្រមានមេធាវីការពារក្តីជនជាប់ចោទពីលក្ខន្តិកៈរក្សាការសម្ងាត់នៃឯកសារស៊ើបអង្កេតដែលមិនទាន់បានផ្សព្វផ្សាយនៅលើគេហទំព័ររបស់តុលាការខ្មែរក្រហមមិនអាចចាត់ទុកជា «ដីកាតុលាការ» ដែលមានសុពលភាពបានទេ ។

នៅក្នុងការកាត់ទោសអ្នកសារព័ត៌មានពីបទប្រមាថមើលងាយនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានសម្ងាត់ដែលរំលោភបំពានលើវិធានការការការពាររបស់តុលាការ ។ ទាំងនេះគឺជាដីកាមិនត្រូវបានផ្សព្វផ្សាយដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ឬក៏ជាដីកាស្តីពីលក្ខន្តិកៈរបស់សាក្សី ឬជនរងគ្រោះដែលត្រូវបានការពារដោយតុលាការទេ ។ ប៉ុន្តែនៅក្នុងរឿងក្តីរបស់ វី ហាត់ម៉ាន់ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទប្រមាថមើលងាយសម្រាប់ការផ្សព្វផ្សាយព័ត៌មានសំខាន់ដែលរំលោភបំពានលើសេចក្តីសម្រេចពីរដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានចេញជាសម្ងាត់ ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា «ការចេញសេចក្តីសម្រេចជាសម្ងាត់ដោយចៅក្រមបង្កើតដីកាមួយសម្រាប់ការមិនផ្សព្វផ្សាយព័ត៌មានដែលមាននៅក្នុងសេចក្តីសម្រេចនេះ ហើយគ្មានភាគីណាមួយអាចសម្រេចថាតើសេចក្តីសម្រេចសម្ងាត់ណាខ្លះដែលអាចផ្សព្វផ្សាយបានទេ ។

អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តីរបស់ វី ហាត់ម៉ាន់ បានសម្រេចថា ដីកាសម្រេចរបស់ចៅក្រមរួមផ្សំទាំងសេចក្តីសម្រេចរបស់តុលាការនឹងត្រូវចេញដោយសម្ងាត់ ។

នៅតុលាការខ្មែរក្រហម ព័ត៌មានដែលកាសែត គ្រីស្សៀន សៃអិនម៉នីទ័រ បានបង្ហាញកាលពីពេលថ្មីៗនេះមានប្រភពមកពីឯកសាររបស់ព្រះរាជអាជ្ញាដែលបានផ្ញើទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតជាការប្រឆាំងនឹងដីកាឬសេចក្តីសម្រេចរបស់តុលាការ ។ ជាលទ្ធផល ព័ត៌មានសម្ងាត់ដែលត្រូវបានលាតត្រដាងនោះអាចមិនឋិតនៅក្រោម «ដីកាណាមួយរបស់តុលាការ» ទេ បើយោងតាមការបកស្រាយរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ។

យ៉ាងណាមិញ វាគួរឲ្យកត់សម្គាល់ដែលថា វិធានផ្ទៃក្នុង ៥៤របស់តុលាការខ្មែរក្រហមដែលចែងពីការលាក់ការណ៍សម្ងាត់នៃសេចក្តីសន្និដ្ឋានស៊ើបអង្កេតទាំងអស់របស់សហព្រះរាជអាជ្ញានោះត្រូវបានអនុម័តដោយចៅក្រមរបស់តុលាការខ្មែរក្រហមនៅក្នុងអង្គប្រជុំចេញសេចក្តីសម្រេចរបស់ចៅក្រម ។ ដូច្នេះតាមទ្រឹស្តីវិធានផ្ទៃក្នុងទាំងឡាយណាដែលចែងពីការលាក់ការណ៍សម្ងាត់នៃព័ត៌មានរបស់ឯកសារមួយចំនួនអាចនឹងត្រូវចាត់ទុកជា «ដីកា» របស់តុលាការដែលឋិតនៅក្រោមវិធានផ្ទៃក្នុង៣៥(១)(ក) ។

## ឃ) ធាតុផ្សំនៃបទល្មើសប្រមាថមើលងាយ

នៅក្នុងរឿងក្តីពីបទចោទប្រកាន់ព្រហ្មទណ្ឌ ការកាត់ទោសសម្រាប់បទប្រមាថមើលងាយត្រូវតែបញ្ជាក់ពីធាតុផ្សំទាំងអស់នៃបទល្មើសនោះឲ្យហួសពីវិមតិសង្ស័យដែលជាអំពើពិរុទ្ធធាតុផ្សំខាងផ្លូវកាយ និងជាចេតនាឧក្រិដ្ឋធាតុផ្សំខាងផ្លូវចិត្ត ។

### ១) អំពើពិរុទ្ធ

អំពើពិរុទ្ធដែលមានចែងនៅក្រោមជំពូករបស់វិធាន ៣៥(១)គឺសំដៅទៅលើ «ការជ្រៀតជ្រែកការគ្រប់គ្រងវិស័យយុត្តិធម៌» ។ គំរូរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានចែងថាការប្រព្រឹត្តដែលមានចែងនៅក្នុងវិធាន ៧៧(១)ដល់៧៧(៥)គឺជាធាតុផ្សំដោយផ្នែកមួយនៃធាតុផ្សំឯករាជ្យជាច្រើនដែលតម្រូវទៅតាមធាតុផ្សំនៃជំពូករបស់វិធាន ៧៧(១)(៥) ។ ដូច្នេះ ការរំលោភលើធាតុផ្សំដោយផ្នែកណាមួយ «គឺអាចចាត់ទុកជាការជ្រៀតជ្រែក....ការគ្រប់គ្រងវិស័យយុត្តិធម៌» ដូច្នោះដែរ ។ មានការសន្មតដោយស្វ័យប្រវត្តិថាការប្រព្រឹត្តដែលមានចែងនៅក្នុងធាតុផ្សំដោយផ្នែកនីមួយៗអាចចាត់ទុកជាការជ្រៀតជ្រែក ។ អាស្រ័យហេតុនេះ គ្មានការទាមទារឲ្យបង្ហាញភ័ស្តុតាងនៃគ្រោះថ្នាក់ជាក់ស្តែងដែលអាចកើតមានមកលើការគ្រប់គ្រងវិស័យយុត្តិធម៌ទេ ។

សេចក្តីសម្រេចទីពីររបស់អង្គបុរេជំនុំជម្រះនៃតុលាការខ្មែរក្រហមស្តីពីបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ដែលប្តឹងប្រឆាំងនឹងដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពីការស្នើសុំកោះហៅសាក្សីបានអនុម័តយកខ្លឹមសារស្រដៀងគ្នានឹងវិធាន៣៥(១)(ក)-(ង) ។ ក្នុងកាលៈទេសៈបែបនេះ មេធាវីការពារក្តីជនជាប់ចោទបានចោទប្រកាន់ថាការបញ្ចេញមតិយោបល់របស់សមាជិករដ្ឋាភិបាលកម្ពុជា «បានជះឥទ្ធិពលមកលើសមត្ថភាពនិងឆន្ទៈ» របស់សាក្សីដែលជាសមាជិករដ្ឋាភិបាលប្រាំមួយរូបក្នុងការជួបសម្ភាសន៍ជាមួយនឹងសហចៅក្រមស៊ើបអង្កេតរបស់តុលាការខ្មែរក្រហម ។ មេធាវីការពារក្តីជនជាប់ចោទបានទទូចថាសមាជិករដ្ឋាភិបាលគួរតែត្រូវកាត់ទោសឲ្យទទួលខុសត្រូវលើ «ការគំរាមកំហែង ឬប្រមាថមើលងាយ...សាក្សីសំខាន់...ដែលអាចផ្តល់ជាភ័ស្តុតាងនៅក្នុងអង្គនីតិវិធីចំពោះមុខសហចៅក្រមស៊ើបអង្កេតឬចៅក្រម» យោងតាមវិធាន៣៥(១)(ឃ) ។ ដោយសារតែខ្វះខាតនូវគំរូពីតុលាការជាតិនិងតុលាការខ្មែរក្រហមអង្គបុរេជំនុំជម្រះបានពឹងផ្អែកទាំងស្រុងលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដោយទទួលស្គាល់នូវ «ភាពប្រហាក់ប្រហែលគ្នា» រវាងបទបញ្ញត្តិនីមួយៗរបស់តុលាការទាក់ទងនឹងការជ្រៀកជ្រែកការគ្រប់គ្រងវិស័យយុត្តិធម៌ ។

នៅពេលពិភាក្សាពីធាតុផ្សំនៃអំពើពិរុទ្ធដែលឋិតនៅក្រោមវិធាន៣៥ អង្គបុរេជំនុំជម្រះបានពិចារណាតែការប្រព្រឹត្តដែលមានចែងនៅក្នុងវិធាននេះតែប៉ុណ្ណោះ ហើយក៏បានសម្រេចថាគ្មានលក្ខន្តិកៈណាផ្សេងទៀតអាចនឹងតម្រូវទៅតាមធាតុផ្សំខាងផ្លូវកាយទូទៅនៃវិធាននេះដែលស្តីពីជ្រៀតជ្រែកការគ្រប់គ្រងវិស័យយុត្តិធម៌បានទេ ។ ចៅក្រមបានអនុម័តដោយមិនលម្អៀងនូវខ្លឹមសារនៃអំពើពិរុទ្ធសម្រាប់ការដាក់ទណ្ឌកម្មលើបទប្រមាថមើលងាយដែលមានលក្ខណៈស្រដៀងគ្នានឹងវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ ដូច្នេះដោយសារតែការប្រកាន់ខ្ជាប់របស់តុលាការខ្មែរក្រហមក្នុងការដើរតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី

ការប្រព្រឹត្តតាមផ្លូវកាយ ដោយផ្សព្វផ្សាយព័ត៌មានសម្ងាត់ដែលរំលោភបំពានលើដីការបស់តុលាការអាចចាត់ទុកជាការជ្រៀតជ្រែកការគ្រប់គ្រងវិស័យយុត្តិធម៌របស់តុលាការខ្មែរក្រហមហើយអាចគោរពទៅតាមធាតុផ្សំនៃអំពើពិរុទ្ធពីបទប្រមាថមើលងាយបាន ។

### ២) ចេតនាឧក្រិដ្ឋ

ចេតនាឧក្រិដ្ឋដែលតម្រូវឲ្យគោរពតាមវិធានផ្ទៃក្នុង ៣៥(១)របស់តុលាការខ្មែរក្រហមគឺ «ត្រូវតែធ្វើឡើងដោយដឹងមុនហើយដោយចេតនា» ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីក៏ដាក់បញ្ចូលលក្ខខណ្ឌិកៈទូទៅដូចគ្នានឹងវិធាន៧៧(ក) និងធាតុផ្សំខាងផ្លូវចិត្តនៅក្នុងផ្នែក(២) ដែលបកស្រាយយ៉ាងជាក់លាក់ពីការផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយ «ដឹងជាមុន» ។ ដូច្នេះវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីតម្រូវឲ្យមានការកំណត់ចេតនាឧក្រិដ្ឋជាពីរប្រភេទដើម្បីធ្វើការចោទប្រកាន់ពីបទប្រមាថមើលងាយ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានថែងថាចេតនាឧក្រិដ្ឋអាចគោរពទៅតាមវិធាន៧៧(ក) (២) បានប្រសិនបើជនជាប់ចោទបាន «ដឹងថាការផ្សព្វផ្សាយព័ត៌មានសម្ងាត់នោះគឺជាការរំលោភបំពានលើដីការបស់តុលាការ» ។ ដូច្នេះការជ្រៀតជ្រែកការគ្រប់គ្រងវិស័យយុត្តិធម៌ដោយដឹងមុននិងដោយចេតនាគឺកើតចេញពីការផ្សព្វផ្សាយព័ត៌មានសម្ងាត់ ។ ចៅក្រមបានសម្រេចថា ៖

ចៅក្រមមានហេតុផលគ្រប់គ្រាន់ក្នុងការសម្រេចថាការប្រព្រឹត្តដែលអាចចាត់ទុកថាជាការរំលោភបំពានគឺត្រូវតែធ្វើឡើងដោយចេតនាមិនមែនដោយអចេតនាទេ ។ សេចក្តីសម្រេចនេះអាចនឹងទាញចេញពីភ័ស្តុតាងតាមកាលៈទេសៈ ។ នៅពេលដែលមានសេចក្តីសម្រេចថាជនជាប់ចោទបានដឹងពីដីការបស់តុលាការនោះចៅក្រមបានរកឃើញថាជនជាប់ចោទមានចេតនារំលោភបំពានលើដីការបស់តុលាការ ។ ការធ្វើពើមិនដឹងអំពីដីការបស់តុលាការដោយចេតនាឬភាពខុសប្លែកគ្នានៃផលប៉ះពាល់នៃការប្រព្រឹត្តដែលរំលោភលើដីកានោះអាចនឹងចាត់ទុកជាធាតុផ្សំខាងផ្លូវចិត្ត ។ ការមិនអើពើដោយមិនបានគូសបញ្ជាក់ថាតើដីកានោះពិតជាត្រូវបានបង្កើតឡើងឬយ៉ាងណានោះមិនអាចមានហេតុផលគ្រប់គ្រាន់នោះទេ ។

បើទោះបីជាមានការបន្ថែមលក្ខខណ្ឌិកៈស្តីពីចេតនាឧក្រិដ្ឋចូលទៅក្នុងវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះរបស់តុលាការខ្មែរក្រហមនៅក្នុងសេចក្តីសម្រេចលើកទីពីររបស់ខ្លួនក្នុងការកោះហៅសាក្សីគឺដើរស្របតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដូចគ្នាដែរ ។ ចៅក្រមបានសម្រេចថាធាតុផ្សំនៃវិធាន៣៥(១)(ឃ) បានតម្រូវថា «បានប្រព្រឹត្តដោយចេតនាហើយបានដឹងថាការប្រព្រឹត្តរបស់ខ្លួនអាចនឹងត្រូវបានរារាំងឬជះឥទ្ធិពលមកលើសាក្សីនិងសាក្សីសំខាន់» ។ ដូចដែលបានអនុវត្តទៅតាមធាតុផ្សំដោយផ្អែក(ក) នៃចេតនាឧក្រិដ្ឋមុនគឺទំនងថាជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋដោយចេតនាដោយផ្សព្វផ្សាយព័ត៌មានសម្ងាត់ទាំងដឹងថាការប្រព្រឹត្តបែបនេះគឺជាការរំលោភបំពានលើដីការបស់តុលាការ ។

ដូចដែលបានអនុវត្តទៅលើក្រុមអ្នកសារព័ត៌មានតុលាការត្រូវតែបង្ហាញឲ្យឃើញថាជនល្មើសបានដឹងពីដីកាសម្ងាត់ហើយបានរំលោភបំពានលើដីកានោះដោយផ្សព្វផ្សាយព័ត៌មានសម្ងាត់ទៅកាន់សាធារណជន ។ ជាឧទាហរណ៍ អ្នកសារព័ត៌មានដែលទទួលខុសត្រូវចំពោះអត្ថបទនៃកាសែត គ្រីស្សៀន សៃអិន ម័រនីទ័រ ដែលចុះកាលពីថ្ងៃទី៨ ខែមិថុនា ទំនងជាបានដឹងថា ព័ត៌មានដែលមាននៅក្នុងឯកសារនោះជាព័ត៌មានសម្ងាត់ដោយសារតែអ្នកសារព័ត៌មានរូបនោះបានទទួលស្គាល់ពីការសម្ងាត់នៃឯកសារនោះប៉ុន្តែនៅតែផ្សព្វផ្សាយព័ត៌មាននោះដោយចេតនាទៀត ។

## ៣) ការការពារក្តី

### ១) កំហុសផ្អែកច្បាប់

តុលាការខ្មែរក្រហមមិនទាន់បានពិចារណាថាតើកំហុសនៃច្បាប់ក្នុងការការពារក្តីអាចនឹងមានជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់ពីការប្រមាថមើលងាយបានដែរឬយ៉ាងណានោះទេ ។ យ៉ាងណាមិញ រឿងក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីទំនងជាសម្រេចថាកំហុសផ្អែកច្បាប់របស់ជនម្នាក់មិនលើកលែងការប្រមាថមើលងាយទេ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត

យូហ្គោស្លាវី បានសម្រេចថា «ប្រសិនបើកំហុសផ្នែកច្បាប់នោះគឺជាការការពារក្ដីត្រឹមត្រូវមួយនោះ...អំណាចរបស់ចៅក្រមក្នុងការគ្រប់គ្រងដំណើរការនីតិវិធីរបស់ខ្លួនដែលជាអំណាចក្នុងការដាក់ទណ្ឌកម្មពីបទប្រមាថមើលងាយ ដោយផ្អែកនោះអាចនឹងត្រូវបានរឹតត្បិត ។ ហេតុដូចនេះ ដោយមិនគិតពីជំនឿរបស់ជនណាម្នាក់ទាក់ទងនឹងភាពត្រឹមត្រូវតាមផ្លូវច្បាប់របស់ដីកាតុលាការនោះជនទាំងឡាយណាដែលឋិតនៅក្រោមយុត្តាធិការរបស់តុលាការត្រូវតែគោរពតាមដីកានោះ ។ ដូច្នេះអ្នកសារព័ត៌មានដែលត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយរំលោភបំពានលើដីការបស់តុលាការខ្មែរក្រហមមិនអាចអះអាងថាខ្លួនមានការយល់ច្រឡំពីខ្លឹមសារនៃច្បាប់និងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមបានទេ នៅពេលដែលឈរការពារក្ដី ។

## ២) កំហុសអង្គហេតុ

អ្នកសារព័ត៌មានដែលត្រូវបានកាត់ទោសនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានលើកឡើងពីកំហុសអង្គហេតុក្នុងការការពារក្ដីខ្លួនដែលត្រូវបានចោទប្រកាន់ពីបទប្រមាថមើលងាយ ។ បើយើងពិចារណាលើការការពារក្ដីបែបនេះចៅក្រមរបស់តុលាការព្រហ្មទណ្ឌនេះគួរសម្រេចថា តើជនជាប់ចោទ «បានប្រព្រឹត្តក្រោមការជឿជាក់ថាព័ត៌មាននេះ.... (ដែលត្រូវផ្សព្វផ្សាយនោះ) ជាព័ត៌មានសាធារណៈឬយ៉ាងណា» ។ នៅក្នុងរឿងក្ដី រី ហាត់ម៉ាន់ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានកត់សម្គាល់ថា បើទោះបីជាកំហុសអង្គហេតុគឺជាការការពារក្ដីដ៏ត្រឹមត្រូវក៏ដោយ ក៏ជនជាប់ចោទនៃរឿងក្ដីនេះមិនអាចបន្តការពារក្ដីរបស់ខ្លួនដោយផ្អែកលើពាក្យសម្ដីនិងទង្វើខ្លួនឯងបានទេ ។ ជនជាប់ចោទបាននិយាយយ៉ាងច្បាស់នៅក្នុងសៀវភៅដែលគាត់បានបោះពុម្ពថាព័ត៌មាននោះគឺជាព័ត៌មានសម្ងាត់ ហើយបានបញ្ជាក់ពីការដឹងឮរបស់គាត់នៅក្នុងបទសម្ភាសន៍ថា ព័ត៌មាននេះគឺជាព័ត៌មានសម្ងាត់ ប៉ុន្តែអាក់ខានមិនបានប្រឹក្សាជាមួយនឹងតុលាការមុននឹងបោះផ្សាយព័ត៌មានសម្ងាត់នោះ ។ ដូច្នេះ កំហុសរបស់គាត់នៅក្នុងការការពារក្ដីត្រូវទទួលបរាជ័យ ។ បើទោះបីជាមិនត្រូវបានបកស្រាយក៏ដោយ ក៏សេចក្ដីសម្រេចនេះទំនងជាថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានពិនិត្យមើលថាតើជនម្នាក់មានជាប់ពាក់ព័ន្ធនឹងតុលាការដល់កម្រិតណាដើម្បីកំណត់ថាតើមានកំហុសអង្គហេតុកើតមានឡើងនៅក្នុងបទចោទប្រកាន់លើជននោះដែរទេ ។ ដោយសារតែអ្នកសារព័ត៌មាននៅក្នុងរឿងក្ដី រី ហាត់ម៉ាន់ ធ្លាប់ធ្វើជាអ្នកនាំពាក្យនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ចៅក្រមបានសន្មតថាគាត់បានដឹងពីការលាក់ការណ៍សម្ងាត់របស់សេចក្ដីសម្រេចនេះ ។

នៅឯតុលាការខ្មែរក្រហម ការសន្មតពីការសម្ងាត់នៃព័ត៌មាននៅក្នុងអំឡុងការស៊ើបអង្កេតរបស់អង្គបុរេជំនុំជម្រះបានណែនាំថា កំហុសអង្គហេតុក្នុងការការពារក្ដីអាចនឹងគ្មានន័យនៅពេលដែលយកមកអនុវត្ត ។ ឧទាហរណ៍ វិធានផ្ទៃក្នុង៥៨របស់តុលាការខ្មែរក្រហមចែងយ៉ាងច្បាស់ថា សេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបអង្កេតគឺជាឯកសារសម្ងាត់ ។ យ៉ាងណាមិញ ប្រសិនបើតុលាការខ្មែរក្រហមអនុវត្តតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនោះ តុលាការអាចនឹងពិចារណាថាតើអ្នកសារព័ត៌មានបានដឹងពីប្រព័ន្ធច្បាប់របស់តុលាការ និងបានដឹងថា ឯកសារមួយណាជាឯកសារសម្ងាត់ ។

## ៣) ការអនុវត្ត

វិធានផ្ទៃក្នុង៣៥(២) របស់តុលាការខ្មែរក្រហមចែងថា ៖ បើសហចៅក្រមស៊ើបអង្កេត ឬចៅក្រមមានហេតុផលក្នុងការជឿថាជនម្នាក់អាចប្រព្រឹត្តអំពើដែលចែងនៅក្នុងវិធានខាងលើនោះ ចៅក្រមអាច ៖

ក) ដោះស្រាយបញ្ហាដោយយកតាមវិធីសាស្ត្រស្រដៀងគ្នា

ខ) ធ្វើការស៊ើបអង្កេតបន្ថែមដើម្បីគូសបញ្ជាក់ថាចៅក្រមមានហេតុផលគ្រប់គ្រាន់ដើម្បីដំណើរការអង្គនីតិវិធីបានដែរឬទេ ឬ

គ) បញ្ជូនសំណុំរឿងនេះទៅឲ្យអាជ្ញាធររដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ

១) «មូលហេតុដើម្បីជឿ» ថាមាន «មូលហេតុគ្រប់គ្រាន់» ដើម្បីដំណើរការស៊ើបអង្កេត

មុននឹងអង្គនីតិវិធីស្ដីពីបទប្រមាថមើលងាយអាចនឹង

ដំណើរការនៅតុលាការខ្មែរក្រហមបាន សហចៅក្រមស៊ើបអង្កេត ឬចៅក្រមចាំបាច់ត្រូវតែមាន «មូលហេតុក្នុងការជឿ» ថាជននោះអាចប្រព្រឹត្តអំពើដែលមានចែងនៅក្នុងវិធាន៣៥(១) ។ បទដ្ឋាននៃភ័ស្តុតាងនេះតម្រូវឲ្យមានមូលដ្ឋានព័ត៌មាន ឬក៏មូលហេតុដែលមានស្រាប់មួយ» ក្នុងការជឿជាក់ថាការជ្រៀតជ្រែកនេះត្រូវបានប្រព្រឹត្តឡើង ។ ចៅក្រមមិនចាំបាច់ស៊ើបសួរពីលក្ខណៈនៃការចោទប្រកាន់នោះទេ ។ ការពិនិត្យមើលដោយអត្តនោម័តទៅលើបែបផែននៃបទល្មើសមានលក្ខណៈគ្រប់គ្រាន់ហើយ ។ នៅពេលដែលលក្ខខ័ណ្ឌដែលមានកម្រិតទាបនេះត្រូវបានគោរពតាមនោះ សហចៅក្រមស៊ើបអង្កេតឬចៅក្រមត្រូវបានធានាឲ្យចាត់វិធានការបន្ថែមដើម្បីដោះស្រាយបញ្ហានោះភ្លាមដោយធ្វើការស៊ើបអង្កេតបន្ថែម ឬបញ្ជូនសំណុំរឿងនេះទៅឲ្យរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ ។

វិធាន៣៥(២) ចែងថាត្រូវតែមាន «មូលហេតុគ្រប់គ្រាន់» ដើម្បីដំណើរការចោទប្រកាន់ប្រឆាំងពីបទប្រមាថមើលងាយទៅលើជនណាម្នាក់ ។ បើទោះបីជាវិធាននេះមិនត្រូវបានសរសេរឲ្យបានច្បាស់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការខ្មែរក្រហមនៅក្នុងសេចក្តីសម្រេចលើកទីពីររបស់ខ្លួនក្នុងការកោះហៅសាក្សីបានសម្រេចថា «បទដ្ឋាននៃមូលហេតុគ្រប់គ្រាន់ត្រូវតែគោរពតាមដើម្បីដំណើរការអង្គនីតិវិធីដោះស្រាយបញ្ហាតាមវិធីសាស្ត្រស្រដៀងគ្នាឬបញ្ជូនបញ្ហាទៅកាន់អាជ្ញាធរកម្ពុជា ឬអង្គការសហប្រជាជាតិ» ។ ដោយដើរតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី អង្គបុរេជំនុំជម្រះបានបកស្រាយពីបទដ្ឋាននេះដើម្បីទាមទារឲ្យបាននូវការពិតដោយបង្ហាញថា ការប្រមាថមើលងាយត្រូវបានប្រព្រឹត្តឡើង ។ ចៅក្រមចាំបាច់ត្រូវពិចារណាថាតើភ័ស្តុតាងនៅចំពោះតុលាការមានគ្រប់គ្រាន់ហើយឬនៅ ដើម្បីបញ្ជាក់បន្ថែមលើការចោទប្រកាន់នេះមិនមែនដើម្បីកំណត់ជាចុងក្រោយថាតើការជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌ពិតជាត្រូវបានប្រព្រឹត្តឡើងនោះទេ ។

១) «ភ័ស្តុតាងហួសពីវិមតិសង្ស័យ «តម្រូវឲ្យចោទប្រកាន់

តុលាការអន្តរជាតិបានទទួលស្គាល់ថា បទប្រមាថមើលងាយគឺជាបទព្រហ្មទណ្ឌ ។ ជាក់ស្តែង វិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមអនុញ្ញាតឲ្យមានការចាត់វិធានការព្រហ្មទណ្ឌប្រឆាំងនឹងជនណាម្នាក់ផ្តល់សិទ្ធិទទួលបានជំនួយផ្លូវច្បាប់ដល់ជនទាំងឡាយណាដែលតម្រូវឲ្យចូលរួមនៅក្នុងអង្គនីតិវិធី និងដាក់ទណ្ឌកម្មទៅលើជនដែលត្រូវបានចៅក្រមរកឃើញថាបានប្រព្រឹត្តអំពើនោះ ។

ដូច្នេះ ដោយមានលក្ខណៈដូចគ្នានឹងបទព្រហ្មទណ្ឌទាំងឡាយរបស់តុលាការខ្មែរក្រហម «ចៅក្រមត្រូវតែចោទប្រកាន់បទល្មើសនោះឲ្យហួសពីវិមតិសង្ស័យដើម្បីចោទប្រកាន់ជនជាប់ចោទបាន» ។ បទដ្ឋាននៃភ័ស្តុតាងនេះត្រូវតែគោរពតាមមុននឹងចៅក្រមអាចដាក់ទណ្ឌកម្មលើជននោះសម្រាប់ការរំលោភបំពានលើវិធាន៣៥(១)នេះ ។

## ៧) ទណ្ឌកម្ម

កាលណាចៅក្រមបានសម្រេចថា ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចាត់ទុកថាជាការជ្រៀតជ្រែកការគ្រប់គ្រងលើវិស័យយុត្តិធម៌ នោះសហចៅក្រមស៊ើបអង្កេតឬចៅក្រមអាចដាក់ទណ្ឌកម្មលើជនជាប់ចោទនោះបាន ។ យោងតាមវិធាន៣៥(៤) «ច្បាប់កម្ពុជាគួរតែយកទៅអនុវត្តសម្រាប់ការដាក់ទណ្ឌកម្មចំពោះបទចោទប្រកាន់បែបនេះ» ។ ប៉ុន្តែ វិធាននេះមិនបានចែងឲ្យច្បាស់ថាច្បាប់កម្ពុជាមួយណាដែលអាចយកមកអនុវត្តទេ ។ ខ្លឹមសារដែលស្រដៀងគ្នាបំផុតនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាទំនងអាចជាមាត្រា៦៣៤ដែលដាក់ទណ្ឌកម្មលើ «ការជ្រៀតជ្រែកដោយខុសច្បាប់ក្នុងការដើរតួនាទីជាស្ថាប័នរដ្ឋណាមួយដែលមានតែអាជ្ញាធរមានអំណាចតែប៉ុណ្ណោះដែលអាចធ្វើបាន» ។ ការរំលោភនេះអាច «នឹងត្រូវបានដាក់ទណ្ឌកម្មឲ្យជាប់ពន្ធនាគារពីមួយឆ្នាំទៅបីឆ្នាំ និងពិន័យជាទឹកប្រាក់ពីពីរលានរៀលទៅប្រាំមួយលានរៀល» ។ យ៉ាងណាមិញ តុលាការខ្មែរក្រហមមិនទាន់បានអនុវត្តបទបញ្ញត្តិនេះនៅឡើយទេ ហើយវាក៏នៅមិនទាន់មានភាពច្បាស់លាស់ថាតើតុលាការគិតថាបទបញ្ញត្តិនេះមានភាពពាក់ព័ន្ធគ្នានឹងបញ្ហាដែលខ្លួនប្រឈមមុខដែរឬទេ ។

តុលាការខ្មែរក្រហមមានបំណងដាក់ទណ្ឌកម្មដោយយោងតាមវិធាន៣៥តែប៉ុណ្ណោះ ។ នៅពេលដែលមេធាវីការពារក្តីជនជាប់ចោទ ម៉ៃ យើល ខណាវ៉ាស់ និង អាង ឧត្តម បានបង្ហោះ

ឯកសារសម្ងាត់របស់តុលាការនៅលើគេហទំព័ររបស់ខ្លួន អង្គបុរេជំនុំជម្រះបានបន្ថាប់ថា ឯកសារនោះត្រូវដកចេញភ្លាមៗ ហើយចាត់ឲ្យសហមេធាវីការពារក្តីជនជាប់ចោទបញ្ឈប់ការបង្ហោះព័ត៌មានសម្ងាត់បន្ថែមទៀតទាក់ទងនឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២របស់តុលាការនៅលើគេហទំព័រនោះ ។ នៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍អង្គបុរេជំនុំជម្រះមិនបានបកស្រាយពីលក្ខណៈនៃទណ្ឌកម្មដែលបានដាក់នោះទេ ។ បើទោះបីជាសេចក្តីសម្រេចនេះផ្តល់ជាសេចក្តីណែនាំបន្តិចបន្តួចក៏ដោយ ក៏វាបានបន្ថាប់ថា ប្រសិនបើអ្នកសារព័ត៌មានត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទប្រមាថមើលងាយតុលាការនៅចំពោះមុខតុលាការខ្មែរក្រហម នោះទណ្ឌកម្មមួយដែលអាចដាក់ទៅលើអ្នកសារព័ត៌មានអាចជាដីកាដែលតម្រូវឲ្យអ្នកសារព័ត៌មានដកព័ត៌មានដែលខ្លួនបានផ្សព្វផ្សាយហើយបង្គាំងមិនឲ្យអ្នកសារព័ត៌មាននោះផ្សព្វផ្សាយព័ត៌មានសម្ងាត់បន្ថែមផ្សេងទៀតទេ ។

គួរឲ្យកត់សម្គាល់ ចៅក្រមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការពិចារណាលើ «ទម្ងន់នៃការប្រព្រឹត្ត និងការរារាំងមិនឲ្យមានការប្រព្រឹត្តនេះសាជាថ្មីម្តងទៀត និងសកម្មភាពស្រដៀងគ្នានេះដោយជនដទៃផ្សេងទៀត» នៅពេលដែលចៅក្រមបានកំណត់យកទណ្ឌកម្មសមរម្យដើម្បីដាក់ទៅលើរឿងក្តីពីបទប្រមាថមើលងាយនេះ ។ នៅក្នុងរឿងក្តីទាំងអស់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលជាប់ពាក់ព័ន្ធនឹងអ្នកសារព័ត៌មានដែលបានផ្សព្វផ្សាយព័ត៌មានសម្ងាត់ អ្នកសារព័ត៌មានទាំងអស់នោះត្រូវបានពិន័យឲ្យបង់ប្រាក់ពីចំនួន៧០០០ទៅ២០០០០យូរ៉ូ ។ យ៉ាងណាមិញ នៅក្នុងរឿងក្តីរវាងព្រះរាជអាជ្ញានិងជនជាប់ចោទ ម៉ាកហ្សេទីក ក្រៅពីការប្រាក់ពិន័យចៅក្រមបានឃុំខ្លួនជនជាប់ចោទរូបនេះរយៈពេលបីខែដោយសារតែការផ្សព្វផ្សាយឈ្មោះ «ជនដែលត្រូវបានការពារដោយតុលាការជាច្រើនរូប» នៅលើគេហទំព័ររបស់ខ្លួនពីព្រោះចៅក្រមបានចាត់ទុកការមិនបានគិតគូរពីគ្រោះថ្នាក់របស់ជនទាំងអស់នោះ» ថាជាកត្តាដាក់បន្ទុកលើទណ្ឌកម្ម ។

ដោយសារតែវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមមិនបានគូសបញ្ជាក់ថា «ច្បាប់កម្ពុជា» មួយណាដែលគួរតែយកមកអនុវត្តនោះវិធានផ្ទៃក្នុងទាំងអស់នេះទំនងជាអនុញ្ញាតឲ្យមានឆន្ទានុសិទ្ធិទូលំទូលាយនៅក្នុងការជ្រើសរើសច្បាប់ដែលជាប់ពាក់ព័ន្ធនិងក្នុងការកំណត់យកទណ្ឌកម្មដ៏សមរម្យមួយដែលជំរុញឲ្យមានសក្តានុពលភាពសម្រាប់ភាពជាប់ពាក់ព័ន្ធនៃរឿងក្តី ។

## ង) សេចក្តីសន្និដ្ឋាន

បើទោះបីជាវិធាន៣៥(១)(ក)ទំនងជាចែងថាអំណាចរបស់តុលាការខ្មែរក្រហមក្នុងការកាត់ទោសអ្នកសារព័ត៌មានសម្រាប់ការប្រព្រឹត្តបទប្រមាថមើលងាយក៏ដោយ ក៏សមត្ថភាពរបស់តុលាការក្នុងការដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មានដែលមិនមែនរស់នៅក្នុងប្រទេសកម្ពុជាអាចចោទជាបញ្ហាច្រើន ។ បន្ថែមលើនេះ វាមិនមានភាពច្បាស់លាស់ថាតើដីកាមួយណាដែលអាចចាត់ទុកបានថាជាដីកាត្រឹមត្រូវទេ ។ នេះគឺជាការស្រាវជ្រាវមុននឹងចេញសេចក្តីសម្រេចថាមានការរំលោភបំពានលើបទប្រមាថមើលងាយ ។ បើទោះបីជាកំហុសអង្គហេតុត្រូវបានទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីថាជាការការពារក្តីដែលត្រឹមត្រូវក៏ដោយ ក៏វាមិនច្បាស់ថាតើកំហុសអង្គហេតុនេះអាចផ្តល់ជាការការពារខ្លួនដ៏ត្រឹមត្រូវមួយសម្រាប់អ្នកសារព័ត៌មានម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានពីជនសង្ស័យដែលមិនដឹងឈ្មោះ និងទីតាំងឧក្រិដ្ឋកម្មបានដែរឬយ៉ាងណា ។ នេះគឺដោយសារតែការសម្ងាត់នៃការស៊ើបអង្កេតទាំងស្រុងរបស់សហចៅក្រមស៊ើបអង្កេត ។ ជាចុងក្រោយ បើសិនអ្នកសារព័ត៌មានត្រូវបានរកឃើញថាបានផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយចេតនា នោះទម្ងន់នៃទណ្ឌកម្មដែលចៅក្រមអាចដាក់មកលើអ្នកសារព័ត៌មាននៅចំពោះមុខតុលាការខ្មែរក្រហមនៅតែមិនមានភាពច្បាស់លាស់នៅឡើយ ។ ដោយសារតែភាពមិនច្បាស់លាស់ទាំងនេះយើងអាចជជែកដេញដោលសួរថាតើការអនុវត្តវិធានផ្ទៃក្នុង៣៥(១)(ក) អាចដើរតួជាការរារាំងដ៏សមរម្យមួយដើម្បីការពារកុំឲ្យមានការផ្សព្វផ្សាយព័ត៌មានសម្ងាត់ និងដើម្បីការពារគ្រោះថ្នាក់ដែលអ្នកសារព័ត៌មានអាចប្រឈមមុខបានដែរឬទេ តាមរយៈការរារាំងកុំឲ្យមានការពិភាក្សាពីព័ត៌មានសម្ងាត់របស់កម្ពុជាដែលអាចទទួលយកបានជាសាធារណៈតាមរយៈប្រព័ន្ធអ៊ីនធឺណែតនៅទូទាំងពិភពលោក ។ **អាណា ម៉ុមហ្សូត**

# រឿងរ៉ាវពិតរបស់ខ្ញុំ

***(តពីលេខមុន)***

*ខណៈពេលដែលកំពុងតម្រៀបជួរគ្នាអង្គុយ ស្រាប់តែមានភាពជ្រួលច្របល់ជាខ្លាំង ព្រោះម្នាក់ៗឃ្លានបាយស្ទើរដាច់ពោះទៅហើយ ម៉្យាងទៀតមិនដែលឃើញបាយទាំងចានៗអស់រយៈពេលមួយឆ្នាំកន្លងមកហើយ ។ បន្ទាប់មកក៏មានបុរសម្នាក់បានស្ទុះរត់ចូលតុបាយចាប់បាយញាត់មាត់ ។ ភ្លាមនោះ អ្នកមូលដ្ឋានបានអូសបុរសម្នាក់នោះចេញ ហើយនិយាយថារកខ្មាំងឃើញហើយ រួចក៏បានចាប់បុរសនោះចងស្លាបសេកអូសមកខាងមុខជួរមនុស្សកំពុងតែអង្គុយ ហើយវាយគាត់នឹងខ្សែតី និងដំបងរហូតដល់បែកឈាមពេញខ្លួនសន្លប់បាត់ស្មារតី ហើយប្រកាសប្រាប់ថា «មិត្តឯងគឺជាខ្មាំង មិត្តឯងមកពីភ្នំពេញដណ្តើមបាយយើង ។ យើងមិនចង់ឲ្យមិត្តឯងរាល់គ្នាមករស់នៅភូមិនេះដណ្តើមបាយយើងទេ ។ តែនេះដោយសារអង្គការចាត់តាំងទើបយើងត្រូវតែគោរពតាម» ។ ឃើញដូច្នេះ ម្នាក់ៗមិនហ៊ានងាកឆ្វេងឬស្តាំឡើយ ហើយនាំគ្នាអង្គុយភ័យគ្រប់គ្នារង់ចាំស្តាប់អ្នកមូលដ្ឋានបញ្ជា ។*

*មួយសន្ទុះក្រោយមក មានបុរសចំណាស់ម្នាក់ស្លៀកពាក់ឯកសណ្ឋានខ្មៅ ពាក់មួក និងបង់កក្រមាក្រហមចេញមកឈរខាងមុខជួរ ហើយនិយាយណែនាំខ្លួនឯងថា គាត់ជាគណៈភូមិឈ្មោះ លាក់ ទទួលខុសត្រូវនៅភូមិលាវនេះ ។ អង្គការមិនមែនឲ្យមិត្តឯងមកហូបទេ គឺឲ្យមិត្តទាំងអស់មកធ្វើស្រែ មិត្តណាធ្វើការទើបទទួលបានរបបអាហារ ។ ចាប់ពីស្អែកទៅសមមិត្តគ្រប់គ្នាត្រូវគោរពអង្គការចាត់តាំងឲ្យបានសម្រេចដាច់ខាត ។ បន្ទាប់មកគាត់បញ្ជាឲ្យយើងទាំងអស់គ្នាដើរទៅហូបបាយនៅរោងបាយរួម ហើយប្រាប់ថា «សមមិត្តទាំងអស់គ្នាសំណាងហើយ មកនៅក្រោយបានបាយហូបមុនគេ ។ អ្នកពីមុនធ្វើស្រែជិតមួយឆ្នាំហើយ ទើបតែបានបាយនៅថ្ងៃនេះទេ ។ នេះគឺជាថ្ងៃដំបូងដែលខ្ញុំបានហូបបាយអង្ករក្រហមមានរសជាតិផ្អែមឈ្ងុយដូចអំបុក ជាមួយសម្លស្ងោរត្រកួន ដែលមានទឹកមិនឃើញសាច់នោះទេ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏គ្រប់គ្នាសប្បាយចិត្តណាស់ព្រោះយើងខានហូបបាយជាយូរមកហើយ ។ ចុងភៅមិនបានថែមបាយសម្លទេ ដោយមួយវង់មានគ្នាចំនួនបួននាក់ អ្នកណាហូបអស់ត្រូវក្រោកចេញ ទៅហូបទឹកអណ្តូងដោយខ្លួនឯង ។ ក្រោយពីហូបហើយ ខ្ញុំក៏ដើរត្រឡប់មកផ្ទះវិញ ។*

*ភូមិនេះមានកុមារមូលដ្ឋានជាច្រើន ប៉ុន្តែមិនដឹងមកពីទីណាទេបានដើរជុំវិញផ្ទះ អ្នក១៧មេសា ក្នុងនោះក៏មានក្មេងប្រុសម្នាក់មកក្រវែលផ្ទះខ្ញុំដែរ រហូតដល់មេឃងងឹតទើបចាកចេញទៅ ។ ពេលយប់ ភូមិនេះត្រជាក់ខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនខ្វល់ខ្វាយអ្វីទាំងអស់ក្រោយពីហូបបាយរួច ឪពុកម្តាយនិងបងប្អូនខ្ញុំជាច្រើននាក់នាំគ្នាប្រជ្រៀតដេកជាមួយគ្នា ។ ពេលព្រឹកឡើង ខ្ញុំក៏ទៅរកដងទឹកអណ្តូងមកប្រើ ប៉ុន្តែមនុស្សច្រើនពេក ព្រោះអណ្តូងទឹកមានតែមួយ ដូច្នេះខ្ញុំក៏ដើរត្រឡប់មកផ្ទះវិញ ដោយមិនបានដួសទឹកនោះទេ ។ បន្ទាប់មក អ្នកមូលដ្ឋានដើរប្រាប់អ្នក១៧មេសាថាឲ្យរង់ចាំប្រជុំទទួលផែនការពីអង្គការថ្នាក់លើ ។*

*ក្រោយពីហូបបាយថ្ងៃត្រង់រួច ទាំងអស់គ្នានាំគ្នាទៅអង្គុយនៅវាលស្រែក្រោយភូមិរង់ចាំប្រជុំ ។ ខ្ញុំបានទៅដល់ទីនោះមុនជាមួយក្មេងៗផ្សេងទៀត រួចបានគយគន់ភូមិសាស្ត្រវាលស្រែដែលខ្ញុំមិនដែលឃើញវាលស្រែក្រោយពេលប្រូតកាត់ទេ ។ បន្ទាប់មកខ្ញុំបានសួរក្មេងម្នាក់ថាហេតុអ្វីបានជាក្មេងមូលដ្ឋានមកក្រឡឹងផ្ទះអ្នក១៧មេសា? ក្មេងប្រុសនោះឆ្លើយថា ក្មេងមូលដ្ឋានទាំងអស់នោះគឺជាកងឈ្លបមកយកការណ៍ពីអ្នក១៧មេសា ។ កាលណាក្នុងផ្ទះយើងមានផ្សែងហុយ ឈ្លបទាំងនេះនឹងទៅរាយការណ៍ប្រាប់គណៈភូមិ ដូច្នេះយើងនិយាយអ្វីត្រូវតែប្រុងប្រយ័ត្ន បើមិនអ៊ីចឹងទេកងសន្តិសុខនឹងចាប់យកទៅដាក់នៅក្នុងមន្ទីរសន្តិសុខខាងជើងភូមិស្ថិតនៅចម្ងាយប្រហែល៥០០ម៉ែត្រជាមិនខាន ។*

*ពេលមកជុំគ្នាហើយ ទាំងអស់គ្នាបានសួរសុខទុក្ខគ្នា ហើយក៏បានដឹងថា ភូមិនេះជាភូមិចាស់ អង្គការខ្មែរក្រហមរុះរើធ្វើជារោងការដ្ឋាន និងរោងបាយឲ្យហូបបបររាវជាលក្ខណៈសហករណ៍ និងធ្វើការរួម រហូតដល់ខ្លះស្លាប់ដោយសារធ្វើការបាក់កម្លាំងនៅ*

សល់តែកុមារនិងស្រីៗ ។ លើសពីនេះទៅទៀត ម្នាក់ៗមានរូបរាងស្គមស្លេកស្លាំង ក្បាលជន្លង់ធំជាងសាច់ភ្លៅ ខោអាវរយីករយាករហែកមុខរហែកក្រោយ ចំណែកសក់ក្បាលកើតចៃពេញក្បាល ហើយក្មេងៗទាំងប្រុសស្រីមានអាយុ១៣ឆ្នាំឡើងទៅត្រូវក្រិនមិនលូតកម្ពស់ ។

ម៉ោងពីរសៀល ខ្ញុំឃើញគណៈភូមិបានមកដល់ ហើយប្រកាសប្រាប់ថា «ពីព្រឹកទៅទទួលផែនការអង្គការថ្នាក់លើដើម្បីអនុវត្តឲ្យចំទិសដៅរបស់អង្គការមហាលោតផ្លោះ មហាអស្ចារ្យ» ។ ចប់សេចក្ដី គណៈភូមិបានឲ្យអង្គប្រជុំមានចំណាប់អារម្មណ៍និងធ្វើការប្ដេជ្ញាចិត្ត ដែលឮតែពាក្យថា «ដើម្បី...គឺថា...ស៊ើរគ្រប់គ្នា» ។ ម៉ោងប្រហែលជាប្រាំល្ងាច អង្គប្រជុំត្រូវចប់ ដល់ពេលរំសាយទៅហូបបបរជាមួយសៀង ហើយបែកគ្នាទៅផ្ទះរៀងៗខ្លួន ។ ពេលមកដល់ផ្ទះ ស្រាប់តែបង្វិចខោអាវរបស់ម្ដាយខ្ញុំត្រូវរុះរើអស់តែមិនបានបាត់របស់របរអ្វីទេ ។ ដោយមានការងឿងឆ្ងល់ គាត់ក៏បានសួរកូនៗគ្រប់គ្នាតែគ្មាននរណាដឹងទេ លុះស្អែកព្រឹកឡើង ទើបបានគេខ្សឹបគ្នាៗថាឲ្យតែមានប្រជុំអ្នកមូលដ្ឋានតែងតែមកឆែកឆេរអីវ៉ាន់បែបនេះហើយ ។ បន្ទាប់ពីជួបជុំគ្នាហើយ អ្នកមូលដ្ឋានបានដឹកនាំយើងទាំងអស់គ្នាទៅធ្វើការដោយគ្មានការលើកលែងទេ សូម្បីតែកុមារតូចៗពីប្រាំពីរឆ្នាំទៅដប់ពីរឆ្នាំក៏ត្រូវធ្វើជីធម្មជាតិក្នុងភូមិតាៗទៅធ្វើបន្តិចនិងយាយៗមើលកូនដែលមានអាយុក្រោមប្រាំឆ្នាំ ។

## គ្រួសារចាប់ផ្ដើមបែកបាក់គ្នា

អ្នកមូលដ្ឋានបានឲ្យអ្នក១៧មេសាអង្គុយតម្រៀបជួរគ្នាតាមអង្គភាពនីមួយៗ ហើយប្រាប់ថា បើនរណាម្នាក់មិនទៅមានន័យថាប្រឆាំងអង្គការ ហើយអ្នកមានឈ្មោះទាំងប៉ុន្មានគឺគ្មានរបបអាហារនៅភូមិទៀតទេ ។ គ្មាននរណាម្នាក់ហ៊ានតមាត់ ឬសួរសុខទុក្ខគ្នាមុនពេលបែកគ្នាទេ មិនថាប្ដីប្រពន្ធ ឬឪពុកនិងកូនឡើយ លើកលែងតែយាយៗនិងកូនក្មេងអាយុក្រោមប្រាំឆ្នាំប៉ុណ្ណោះ ដែលនៅក្រៅជួរកំពុងយំស្រែកដោយសារឃ្លាន ។ ម៉ោងប្រាំពីរព្រឹក អ្នក១៧មេសាដែលស្ថិតនៅក្នុងជួរទាំងប៉ុន្មានត្រូវចេញដំណើរតាមជួររៀងខ្លួន ក្នុងនោះមានបងប្រុសខ្ញុំពីរនាក់ ប្អូនប្រុសខ្ញុំម្នាក់ ប្អូនស្រីខ្ញុំម្នាក់ ខ្ញុំនិងឪពុកខ្ញុំដែលសូម្បីតែគាត់មានដំបៅជើងក៏ទៅអង្គភាពភ្នួរដែរ ។ ខ្ញុំស្ថិតក្នុងជួរកុមារត្រូវចេញដំណើរក្រោយយុវជននិងចាស់ៗ ដូច្នេះខ្ញុំបានត្រឹមតែអង្គុយមើលបងប្រុសខ្ញុំនិងឪពុកខ្ញុំទៅដោយមិនហ៊ានលាគ្នាទេ ។ បន្ទាប់មកដល់វេនកុមារចេញដំណើរខ្ញុំងាកក្រឡេកមើលម្ដាយខ្ញុំស្រក់ទឹកភ្នែកដោយមិននិយាយស្ដីអ្វីទាំងអស់ ។

ខ្ញុំមិនដឹងថា អង្គភាពកុមារនៅកន្លែងណាទេ ដូច្នេះ ខ្ញុំចេះតែដើរតាមគេ កាត់តាមភូមិដូង ដល់ផ្លូវដីក្រហមកន្លែងយោធាចិញ្ចឹមជ្រូក រួចកាត់តាមភូមិអ្នកមូលដ្ឋាន មានផ្ទះក្បឿងចំណាស់ធំៗសម្បូរដើមឈើហូបផ្លែ ។ នៅទីនោះ ខ្ញុំឃើញអ្នកមូលដ្ឋានភាគច្រើនគឺជាស្រីៗ និងកុមារមានសាច់ឈាមស្រស់ថ្លា ទឹកមុខសប្បាយរីករាយមិនដូចខ្ញុំ និងកុមារក្នុងភូមិលាវ ដែលមានស្បែកដណ្ដប់ឆ្អឹងក្បាលជន្លង់ធំជាងសាច់ភ្លៅទេ ។ បន្ទាប់មកដើរចូលដល់ភូមិមួយទៀតដែលភូមិនេះខុសប្លែកពីភូមិអ្នក១៧មេសាខ្លាំងណាស់ ព្រោះជារដូវក្ដៅសោះ ប៉ុន្តែបែរជាមានទឹកធ្វើស្រែច្រើនៗ ដើរមួយសន្ទុះទៀតផុតស្រែសន្ទូង និងព្រៃគ្នោត ចូលដល់វិហារបាក់បែកមួយមានដើមពោធិ៍ដុះលើគំនរថ្ម ហើយនៅទល់មុខដើមនេះចម្ងាយប្រហែលជា១០០ម៉ែត្រមានសាលាឆាន់ដ៏ធំល្វឹងល្វើយខ្ពស់ផុតពីដី គឺជាអង្គភាពកុមារ ។ នៅទីនេះ មានកុមារមកពីភូមិផ្សេងៗជាច្រើននាក់ ដែលសរុបមានគ្នាប្រហែល១០០០នាក់ មួយកងមានគ្នា១០០នាក់ បែកចែកជាបីក្រុម មានមេកងម្នាក់ៗជាកុមារមូលដ្ឋានជាអ្នកមើលការខុសត្រូវ ។ ខ្ញុំឃើញមេកងគ្រប់រូបមានសភាពក្លៀវក្លា ហ្មត់ចត់ ស្លៀកពាក់ឯកសណ្ឋានខ្មៅក្នុងដៃមានរំពាត់ខ្សែតី និងរំពាត់ផ្ដៅនិយាយគ្នាសើចក្អាកក្អាយយ៉ាងសប្បាយ ។ នៅបរិវេណខាងលិចសាលាឆាន់ មានរៀបចំជាអង្គមីទ្ទិងមួយក្រោយពីចាក់ចម្រៀងបដិវត្តន៍ចប់ អង្គប្រជុំក៏បានចាប់ផ្ដើមដោយអង្គការថ្នាក់លើចាប់ផ្ដើមចាប់អារម្មណ៍ថា របប លន់ នល់ជាអាយ៉ងអាគាំង ។ របបសក្តិភូមិបានជិះជាន់កេងប្រវ័ញ្ចលើពលកម្មកុមារដោយចាត់ទុកកុមារជាទាសករ ។ ឥឡូវនេះកុមារត្រូវបានរំដោះចេញផុតពីនឹមអាណានិគមសក្តិភូមិក្លាយទៅជាកូនល្អរបស់អង្គការ ។ ឪពុកម្ដាយមិនអាចជិះជាន់លើកុមារបានទៀតឡើយ អង្គការលើកស្ទួយកុមារហើយប្រែក្លាយកុមារឲ្យទៅជាកុមារឈានមុខ ជាកម្លាំងចលករដ៏រឹងមាំរបស់លិទ្ធិកុម្មុយនីស្តមហាលោតផ្លោះ មហាអស្ចារ្យ ។ មុនពេលបិទការប្រជុំ ប្រធាន

កងបានដាក់បទបញ្ជា និងវិន័យផ្សេងសម្រាប់អង្គភាពដូចជា ហាមលួចរត់ទៅជួបឪពុកម្តាយហាមដើរហើរសេរីដោយគ្មានការអនុញ្ញាត ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានកុមារមួយចំនួនលួចរត់ទៅផ្ទះ ហើយចាប់បានត្រូវទទួលទណ្ឌកម្មពីអង្គការដោយវាយរំពាត់ខ្សែតីដែរ ។

ប្រធានកងឈ្មោះ ឆយ បានប្រជុំជីវភាពថា «ពេលទទួលអាហាររួចត្រូវយកចាន និងស្លាបព្រាដែលសមមិត្តបរិភោគទៅលាងសម្អាតដោយខ្លួនឯង និងទុកកន្លែងដើម អ្នកហូបក្រោយគេត្រូវយកចានសម្ភៅទៅលាង ។ ដល់ម៉ោងហូបអាហារថ្ងៃត្រង់ កុមារគ្រប់គ្នាត្រូវមកតម្រង់ជួរម្តងទៀត ហើយទៅអង្គុយតាមចានបបរដែលគេបានរៀបទុកជាស្រេច ។ ក្រោយពេលបបរថ្ងៃត្រង់រួច ម៉ោងមួយរសៀលត្រូវចាប់ផ្តើមធ្វើការបន្ត ។ ខ្ញុំធ្វើសួនបន្លែជម្រះស្មៅជុំវិញទីធ្លាអង្គភាព កាប់រានដីស្រែជុំវិញបរិវេណវត្តស្រែខ្ទុង ។ ចាប់តាំងពីថ្ងៃនោះមក កុមារត្រូវបែកជាកងផ្សេងៗ ឬជាក្រុមតូចៗ ទៅកាប់ព្រៃ គាស់គល់ឈើក្នុងស្រែ លើកភ្លឺ ជីកប្រឡាយ ជញ្ជូនកណ្តាប់ និងសន្ទូង ហើយពេលយប់ត្រូវហាត់រៀនសម្តែងសិល្បៈបដិវត្តន៍ទៀត ។

## អបិយជំនឿ

នៅម្តុំខាងកើតមានចេតិយបែកបាក់ ដើមស្វាយធំៗ និងដើមហូបផ្លែផ្សេងៗទៀតសម្បូរពាស់គ្រប់ប្រភេទ គ្មាននរណាហ៊ានទៅម្តុំនោះទេ សូម្បីតែអ្នកមូលដ្ឋានក៏ដោយ ។ ពេលព្រលប់ថ្ងៃលិចកុមារភាគច្រើនរមែងឃើញដុំភ្លើង មានពណ៌ជាច្រើនដូចជា ក្រហម លឿង ខៀវ បៃតង ហោះមកពីទិសផ្សេងៗ ជួបជុំគ្នាលើដើមពោធិ៍ដែលតំណាងជារូបមនុស្សក្នុងសម្លៀកបំពាក់ជំនាន់បុរាណ ។ ពេលនោះ កុមារទាំងអស់ខ្លាចរអាលមិនហ៊ានទៅម្តុំនោះទេ ទោះបីជាពេលថ្ងៃក៏ដោយ ។ ហួសពីដើមពោធិ៍ទៅខាងកើតទៀត គឺជាទំនប់ទឹកដ៏ធំមួយ មានទំហំប្រហែលមួយគីឡូម៉ែត្របួនជ្រុង ខែប្រាំងមានទឹកពេញអាង ខែភ្លៀងវិញទឹកភ្លៀងហូរធ្លាក់ពីជ្រលងអូរ ។ នៅទីនោះ គ្រួសារកម្មាភិបាលនៅភូមិខាងជើងវត្តបានយកទឹកនេះធ្វើស្រែមួយឆ្នាំបីដង ដោយអ្នកទាំងនេះសម្បូរចំណីអាហារបរិភោគណាស់ ឯផ្លែឈើវិញទុំជ្រុះពេញដី ។ ខ្ញុំក៏ធ្លាប់ទៅលួចរើសផ្លែឈើ និងបាយកកដែលគេទុកឲ្យជ្រូក និងឆ្កែរបស់គេឲ្យទៅឪពុករបស់ខ្ញុំពីរបីដងដែរ ។ ទំនប់អាងទឹកនេះហៅថាទឹកក្បាលហុងដែលទីវាលក្បែរជុំវិញទំនប់គឺជាព្រៃខ្មោចអ្នក១៧មេសាត្រូវគេយកទៅវាយចោលនៅម្តុំទំនប់ ។ នៅពេលព្រលប់ងងឹតជារឿយៗ ខ្ញុំបានឃើញពន្លឺភ្លើងពិល (កុមារពេលយប់ដេកលើសាលាឆាន់) ពីលើសាលាឆាន់ ដែលពន្លឺពិលនោះនាំមនុស្សទៅសម្លាប់ ព្រោះក្រោយពីបាត់ពន្លឺពិល មួយស្របក់ក៏បានឮសូរសំឡេងថ្ងូរ អូយ! អូយ! ល្ហើយៗ លាន់ឮគ្រលួច គួរឲ្យព្រឺព្រួចខ្លួន ។

ចំណែកខាងលិច និងខាងត្បូងឆៀងខាងលិច គឺជាស្ទឹងក្រពើស មានស្ពានថ្មចាស់ទ្រុឌទ្រោមមួយមានក្រាលក្តារសម្រាប់ឆ្លងទៅភូមិក្រពើរោទ៍ ។ ស្របខាងកើតស្ទឹងគឺជាព្រៃចម្ការក្រូចដែលជាកន្លែងគ្រួសារខ្ញុំ និងអ្នក១៧មេសាមកពីឃុំពងទឹក ស្រុកខត្តុង្គរស់នៅកាលពីប្រាំទៅប្រាំមួយខែមុនឆ្នាំ១៩៧៥ ហើយទើបតែត្រឡប់មកពីភូមិជនជាតិព័របានបីថ្ងៃប៉ុណ្ណោះ ដែលខ្ញុំត្រូវបញ្ជូនមកអង្គភាពកុមារនៅក្បែរកន្លែងនោះ ។ នៅខាងជើងឆៀងខាងលិច គឺជាផ្លូវដីឥដ្ឋកាលពីខ្ញុំដើរត្រឡប់មកភូមិ ។ ចំណែកនៅតំបន់ដំណាក់ឈើក្រមគឺជាកន្លែងយុវជនលើកទំនប់ទប់ស្ទឹង រួចយកទឹកធ្វើស្រែមួយឆ្នាំបីដង ដែលផែនការនេះធ្វើឲ្យយុវជនយុវនារីស្លាប់ជាច្រើននាក់ ។ បងប្រុសខ្ញុំម្នាក់ទៀតឈ្មោះ លី ប៊ុនយឹម ក៏បានកំពុងលើកទំនប់ និងជីកប្រឡាយនៅតំបន់នោះដែរ ។

## កំហុសលួចផ្លែក្រូចត្រូវកុមារមូលដ្ឋានវាយធ្វើទារុណកម្ម

មានកុមារីមួយចំនួនបានរត់ទៅផ្ទះជួបឪពុកម្តាយ ពេលត្រឡប់មកវិញក៏ត្រូវមេកង និងប្រធានក្រុមយកខ្សែតី ឬដងរែកវាយរហូតបែកឈាមពេញខ្លួន រួចចងផ្តោបដើមឈើឲ្យអង្ក្រងខាំ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏កុមារទាំងអស់មិនរាងចាលដែរ ព្រោះនឹកឪពុកម្តាយខ្លាំងពេក រហូតដល់កុមារខ្លះត្រូវបានយកទៅកម្ទេចចោលតែម្តង ព្រោះខ្ញុំឃើញអង្គការយកសម្លៀកបំពាក់របស់កុមារដែលបានបាត់ខ្លួនយកមកចែកឲ្យកុមារក្នុងភូមិពាក់វិញ ដែលខោអាវខ្លះមានស្នាមប្រឡាក់ឈាមបោកមិនជ្រះទៀតផង ។ នៅអង្គភាពកុមារ ទាំងកុមារាកុមារីគឺត្រូវឆ្លៀតទៅងូតទឹកប្រឡាយទាំងខោអាវ ហើយស្លៀកពាក់ទាំងសើមរហូតដល់ស្ងួតដើម្បីធ្វើការ ដូច្នេះហើយខោអាវឆាប់ពុកផុយណាស់ ហើយខ្លួនក៏កើតស្រែង ឬ បូរមាស់ទៀត ។ ចំណែករូបរាងក៏ស្គមស្លេកស្លាំង

តែបបរពាវ រហូតដល់រដូវច្រូតទើបហូបបបរគោក ។

មានថ្ងៃមួយ ខ្មែរក្រហមបានរៀបចំអន្ទង់ធំនៅផ្លូវជីក្រហម ដោយមានលើកជាផ្ទាំងបដា ពណ៌ក្រហមសរសេរពាក្យស្លោកផ្សេងៗថា សន្និបាតឆ្នាំ១៩៧៧ ។ ក្រោយពីទាំងអស់គ្នាមកជួបជុំគ្នានៅកន្លែងអន្ទង់មីទ្ទិង អង្គការបានបញ្ចាំងខ្សែភាពយន្តឯកសារឲ្យមើល ហើយធ្វើបន្ថែមនំកូរឲ្យហូប ។ ថ្ងៃក្រោយមកទៀត អង្គការបានដឹកក្រូចជាច្រើនមកទុកនៅកន្លែងកុមារ ។ នៅយប់នោះ ខ្ញុំឃ្លានខ្លាំងពេកក៏បានលួនទៅលួចយកក្រូចបានចំនួនពីរផ្លែ រួចហែកក្រូចនោះហូបទាំងយប់ទើបខ្ញុំត្រឡប់មកវិញ ។ លុះព្រឹកឡើង ប្រធានកងក៏បានដឹងថា បាត់ក្រូចច្រើន ហើយបញ្ជាឲ្យកុមារតម្រៀបជួរគ្នា និងដើរទៅមុខដើម្បីចាំហិតក្លិនដៃ ថាតើមានក្លិនក្រូចដែរឬទេ ។ ដោយសារតែខ្ញុំដើរទៅដល់ភ័យញ័រជើង ញ័រដៃ ខ្ញុំក៏សារភាពថា ខ្ញុំបានលួចផ្លែក្រូចចំនួនពីរផ្លែ ។ បន្ទាប់មក មេកងបានបញ្ជាឲ្យខ្ញុំដេកផ្កាប់មុខនៅលើដី រួចវាយខ្ញុំទុកជាគំរូ ដើម្បីកុំឲ្យកុមារដទៃយកតម្រាប់តាម ។ ដោយសារតែមិនអាចទ្រាំនឹងការវាយបាន ខ្ញុំក៏សន្លប់បាត់ស្មារតី ។ ក្រោយពីដឹងខ្លួន ប្រធានបានយកទឹកមកជះដាក់ខ្ញុំ រួចអូសខ្ញុំទៅចងភ្ជាប់នឹងដើមឈើក្បែរអង្គភាពទុកឲ្យអង្រ្កងខាំ ។ ប្រធានអង្គភាពបានសម្រេចថា ខ្ញុំធ្វើខុសចំនួនពីរដងហើយ មិនត្រូវឲ្យមានជាលើកទីបីទេ បើមិនអ៊ីចឹងទេនឹងត្រូវធ្វើជីដាក់ស្រែជាមិនខាន (មានន័យថាយកខ្ញុំទៅកម្ទេចចោល) ។ ចាប់តាំងពីពេលនោះមក ខ្ញុំទៅធ្វើការមិនដែលហ៊ានឈប់ទេ ទោះបីជាខ្ញុំឈឺទ្រុឌទ្រោមយ៉ាងណាក៏ដោយ ។

ដោយសារតែការហូបចុកមិនគ្រប់គ្រាន់ ខ្ញុំក៏នឹកឃើញមធ្យោបាយមួយគឺថា ពេលខ្ញុំត្រឡប់មកពីធ្វើការ ខ្ញុំទៅរកខសមកធ្វើចុងភៅ ។ បានមួយរយៈ ចុងភៅក៏បានដួសបបរខាប់ឲ្យខ្ញុំ ។ មិនយូរប៉ុន្មានស្រាប់តែមានការផ្លាស់ ឆយ ចេញ រួចឲ្យ កា អ្នក១៧ មេសាដូចគ្នាបានឡើងជំនួសវិញ ។ កា ចូលចិត្តប្រណៃន និងរករឿងខ្ញុំណាស់ ព្រោះខ្ញុំបានបបរគោករាល់ពេល ។ មានថ្ងៃមួយ មេក្រុមក្រោយម្នាក់នេះក៏ចោទខ្ញុំថាជិះជាន់កម្លាំងពលកម្មរបស់អ្នកដទៃ ដោយយកម៉ោងការងាររួមធ្វើការងារឯកជន ។ ដោយសារតែចំពេលថ្ងៃត្រង់ជិតដល់ពេលត្រឡប់មកអង្គភាពវិញ គាត់ក៏បានលើកកាំបិតប្រុងកាប់ខ្ញុំទម្លាក់ប្រឡាយទឹក ។ ពេលនោះ ខ្ញុំក៏លើកកាំបិតរងទាន់ពេល ហើយច្រានមេក្រុមនេះពេញមួយទំហឹងធ្វើឲ្យរអិលជើងធ្លាក់ប្រឡាយទឹក ។ ដោយសារតែខ្ញុំភ័យខ្លាំងពេក ហើយគិតថាជាកំហុសលើកទីបីហើយ បើនៅជួយពិតជាត្រូវស្លាប់ជាមិនខាន ដូច្នេះ ឆ្លៀតពេលដែលកុមារក្នុងក្រុមជាមួយគ្នាបានចុះជួយស្រង់គាត់ ខ្ញុំក៏រត់ចោលអង្គភាពលែងត្រឡប់មកវិញ ។

## ការរត់ចោលអង្គភាពដើម្បីឲ្យរួចជីវិត

ថ្ងៃនោះ ខ្ញុំបានដើរកាត់តាមភ្លឺស្រែឆ្លងវាល ឆ្លងស្ទឹង សំដៅទៅតំបន់ដំណាក់ឈើក្រមដែលជាកន្លែងខ្ញុំធ្លាប់បានរង្វេងកាលពីមុន ។ នៅទីនោះ មិនមែនមានតែខ្ញុំទេដែលរត់ចូលព្រៃ ព្រោះខ្ញុំបានឃើញយុវជន យុវនារី និងកុមារនៅក្នុងព្រៃដូចជាខ្ញុំដែរ ។ ប៉ុន្តែយើងមិនដែលហ៊ានមើលមុខគ្នា និងនិយាយរកគ្នាទេ គ្រាន់តែឃើញគ្នាពីចម្ងាយក៏គេចមុខគ្នារៀងៗខ្លួន ។ ពេលថ្ងៃ ខ្ញុំរកដំឡូង បេះផ្លែឈើ និងចាប់ត្រីក្នុងលក្ខណៈប្រុងប្រយ័ត្នមើលមុខមើលក្រោយ ពេលយប់លួចទៅបូតស្រូវនៅម្ខាងស្ទឹង រួចត្រឡប់មកដេកនៅលើដើមឈើ ដើម្បីចិញ្ចឹមជីវិតជារៀងរាល់ថ្ងៃ ។

## គុណបុណ្យឪពុកម្តាយជួយឲ្យខ្ញុំរស់

ក្នុងរយៈពេលដែលខ្ញុំបានរត់ចោលអង្គភាព និងពួនសម្ងំនៅក្នុងព្រៃក្បែរទំនប់ដំណាក់ឈើក្រម មិនបានយូរប៉ុន្មានខ្ញុំក៏ឈប់ខ្លាចព្រោះមិនឃើញមានមេកងមករកខ្ញុំទេ ។ ដូច្នេះហើយ ខ្ញុំក៏ចេញពីព្រៃឆ្លងស្ទឹងមកក្បែរអង្គភាពលួចមើលការដ្ឋានពីចម្ងាយ ហើយក៏បានឃើញកុមារទាំងអស់ធ្វើតាមធម្មតា តែខ្ញុំមិនហ៊ានទៅជិតកុមារទាំងនេះទេ ។ បន្ទាប់មក ខ្ញុំទៅជួបម្តាយខ្ញុំដើម្បីសួរថា តើមាននរណាគេមករកខ្ញុំទេ? គាត់បានឆ្លើយថា គ្មាននរណាគេមករកទេ ។ ដោយឃើញម្តាយខ្ញុំមានទឹកមុខស្លៀងស្លល់ ខ្ញុំក៏ប្រញាប់លាគាត់ ហើយប្រាប់ថាខ្ញុំមកធ្វើការនៅម្តុំនេះទើបឆ្លៀតចូលលេង ។ បន្ទាប់មក ខ្ញុំបានស្កាត់ទៅរកឪពុកខ្ញុំម្តង ដោយខ្ញុំបានឃើញគាត់មានដំបៅនៅលើខ្នងជើងខាងស្តាំ ដែលធ្វើឲ្យគាត់ក្រោកឈរ និងដើរលំបាកជាខ្លាំង ។ គាត់មានរូបរាងស្គមស្លេកស្លាំង ស្បែកខ្មៅ បាក់ពោះយ៉ាងជ្រៅកំពុងអង្គុយត្បាញបង្កី ។ ខ្ញុំបានលបមើលគាត់ពីគុម្ពោតព្រៃក្បែររោងបង្កី រួចសម្រក់ទឹកភ្នែកម្នាក់ឯង ព្រោះអាណិតគាត់ខ្លាំងពេក ។ ខ្ញុំត្រឡប់ទៅភូមិអ្នកមូលដ្ឋានវិញក៏ដើរលបៗក្បែរគុម្ពចេកសំដៅរកទ្រុងជ្រូក ។ ជា

សំណាងល្អជ្រូកកំពុងស៊ីបាយ ខ្ញុំក៏កើបបាយដែលជ្រូកកំពុងស៊ីដាក់ថ្នក់ក្រមាយកមកជូនឪពុកខ្ញុំពិសា (បាយជ្រូកជំនាន់ខ្មែរក្រហមគឺគេដាក់ទាំងដុំៗ ជួនកាលបាយក្រហមក្តៅខណ្ណក៏មានកន្ទក់ ដោយកន្ទក់ និងត្រកួនសដាក់ឲ្យជ្រូកស៊ីដោយឡែក ទឹកដោយឡែក) ។

ចាប់ពីថ្ងៃខ្ញុំបានជួបឪពុកខ្ញុំមក ពេលថ្ងៃខ្ញុំតែងតែដើរលួចបាយជ្រូក និងអ៊ីផ្សេងទៀតដែលអាចហូបបានដូចជា ក្បាលត្រីអាំងជាដើមយកទៅជូនឪពុកខ្ញុំ ហើយបេះស្លឹកល្ហុងស្ងោរបិតដំបៅឲ្យគាត់ ព្រមទាំងឆ្លៀតយករបស់ដែលលួចបានទៅជូនម្តាយខ្ញុំផងដែរ ។ រយៈពេលប្រហែលជាង១០ថ្ងៃ ចាស់ៗនៅអង្គភាពជាមួយគ្នាបានជួយលាក់ការណ៍រឿងខ្ញុំទៅជួយឪពុកខ្ញុំរហូតដល់ដំបៅឪពុកខ្ញុំដុះសាច់ក្រហមថ្លាពណ៌ផ្កាឈូកជិតជាសះស្បើយ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ថ្ងៃមួយស្រាប់តែប្រធានអង្គភាពឃើញខ្ញុំកំពុងបិតដំបៅឲ្យគាត់ ធ្វើឲ្យខ្ញុំភ័យខ្លាចជាខ្លាំង ។ ប៉ុន្តែប្រធានអង្គភាពនោះបានដើរហួសទៅធ្វើដូចជាមើលមិនឃើញ និងមិនដឹងរឿងអ្វីនោះទេ ។ ដើម្បីកុំឲ្យគាត់យករឿងនេះទៅនិយាយប្រាប់អង្គការថ្នាក់លើ ឪពុកខ្ញុំបានជូននាឡិកាដៃ Citizen Automatic ដែលគាត់បានលាក់ទុកជាយូរមកហើយឲ្យទៅប្រធានអង្គភាពរបស់គាត់ ។ ក្រោយពីខ្ញុំបានមើលថែដំបៅជើងឪពុកខ្ញុំរហូតដល់ជាសះស្បើយ ខ្ញុំក៏បានទៅផ្ទះនៅឯភូមិ ហើយប្រាប់គាត់ថា ខ្ញុំរត់ចោលអង្គភាពកុមារ ហើយខ្ញុំរស់នៅរបៀបនេះបានប្រហែលជាជាងកន្លះខែមកហើយ ។

ចំណែកម្តាយខ្ញុំត្រូវបានប្រធានភូមិចាត់តាំងឲ្យធ្វើជាអ្នករកបន្លែសម្រាប់ផ្គត់ផ្គង់ការដ្ឋានរោងបាយ ។ ដូច្នេះ ជារៀងរាល់ថ្ងៃគាត់ត្រូវដើររកបន្លែនៅខាងក្រៅភូមិក្បែរមាត់បឹង តាមភ្លឺស្រែនិងទីទួលផ្សេងមានដូចជាត្រកួន ព្រលិត ដៃកំប្លោក ស្លឹកឈើព្រៃផ្សេងៗដែលអាចហូបបាន ប្រសិនបើរកមិនបានគ្រប់ចំនួនទេនឹងត្រូវបង្អត់របបអាហារជាមិនខាន ។ ដោយសារគាត់ចុះត្រាំទឹកជារៀងរាល់ថ្ងៃដើម្បីរកបន្លែ ទើបនៅតាមប្រឡោះម្រាមដៃម្រាមជើងរបស់គាត់ត្រូវទឹកស៊ីឡើងហើមស្អុយរលួយ ។

ឯប្អូនស្រីរបស់ខ្ញុំពីរនាក់ ម្នាក់៩ឆ្នាំនិងម្នាក់ទៀត៧ឆ្នាំ ត្រូវធ្វើការដូចមនុស្សធំពេញវ័យ គឺកាប់ដីដឹបូក ដើមទន្ទ្រានខែត្រនិងដើររើសអាចម៍គោ អាចម៍ក្របីយកទៅធ្វើជីធម្មជាតិ ក្រោមការដឹកនាំរបស់មនុស្សចាស់ម្នាក់ និងប្អូនប្រុសពៅរបស់ខ្ញុំម្នាក់វ័យ៥ឆ្នាំមិនត្រូវបានគេឲ្យធ្វើការទេ ។ ប្អូនៗរបស់ខ្ញុំទាំងបីនាក់មានរូបរាងស្គមស្លេកស្លាំង ឃើញតែឆ្អឹងជំនី ក្បាលពោះធំប៉ោងសរសៃខៀវ ស្បែកពោះស្តើង ប្រសិនបើមុតអ្វីបន្តិចហ្នឹងធ្លាយពោះចេញពោះវៀនជាមិនខាន ។ ចំណែកកដៃជើងស៊ិតសាច់អស់ឃើញតែឆ្អឹង ក្បាលជង្គង់ធំជាងភ្លៅ ឯភ្នែកវិញខូងជ្រៅ ខ្លួនកើតរមាស់ និងបែ ។

ផ្ទះទាំងអស់ក្នុងភូមិដែលអ្នក១៧មេសារស់នៅគឺធ្វើពីដើមឫស្សីទាំងអស់ ដំបូលប្រក់ស្លឹកនិងស្បូវ ឯរនាបឫស្សីក្រងផ្តៅ ដែលផ្ទះនេះមិនមែនកម្មសិទ្ធិរបស់នរណាម្នាក់ឡើយ គឺជារបស់សមូហភាព ។ អង្គការតែងតែផ្លាស់ប្តូរផ្ទះរបស់ប្រជាជនជារឿយៗ ដោយមិនអនុញ្ញាតឲ្យរស់នៅជិតដិតនឹងគ្នាបានយូរខែទេ ។

**(នៅមានត)**

**ឡៃ ហួត**

# សេចក្តីប្រកាសរកបងថ្លៃ

នាងខ្ញុំឈ្មោះ សុខ រុំ សព្វថ្ងៃរស់នៅក្នុងភូមិស្តេចគង់ខាងត្បូង ឃុំតាផុន ស្រុកបន្ទាយមាស ខេត្តកំពត ។ នាងខ្ញុំសូមសួររកបងថ្លៃ ឈ្មោះ អ៊ីវ សៀន ដែលបានបាត់ខ្លួននៅសម័យខ្មែរក្រហម ។ មុនខ្មែរក្រហមឡើងកាន់អំណាច សៀន រស់នៅក្នុងឃុំក្បែរខ្ញុំដែរ នៅភូមិស្រឡៅ ឃុំស្តេចគង់ខាងជើង ស្រុកទូកមាស ខេត្តកំពត ដោយគាត់មានអាយុប្រហែលជា២០ឆ្នាំ ។ ក្រោយបែកភ្នំពេញនៅឆ្នាំ១៩៧៥ បងថ្លៃរបស់ខ្ញុំក៏បានស្ម័គ្រចិត្តចូលធ្វើជាទាហានខ្មែរក្រហម ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់សោះ ។

ប្រសិនបើជាបង អ៊ីវ សៀន នៅរស់ ឬក៏បងប្អូនណាដែលស្គាល់ ឬដឹងពីដំណឹងពីឈ្មោះខាងលើនេះ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទ ០៣៣ ៦៦ ៣៣ ៣៣១ ឬមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ⬥ Preah Sihanouk Blvd ⬥ Phnom Penh ⬥ Cambodia ⬥ Tel: (855) 23 211 875 ⬥ Fax: (855) 23 210 358 ⬥ dccam@online.com.kh ⬥ www.dccam.org.


A magazine of the Documentation Center of Cambodia: Searching for the truth. ⬥ Number 141, September 2011 ⬥ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.